ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា “កម្ពុជា រី”

Cambodian Reinsurance Company “Cambodia Re”

ដៃគូដើម្បីស្ថិរភាព និងភាពជោគជ័យ

Partner for Stability and Success

របាយការណ៍

ប្រចាំឆ្នាំ២០២៥

ក្រុមហ៊ុនធានារ៉ាប់រងឡើងវិញកម្ពុជា "កម្ពុជា រ៉េ"
CAMBODIA RE

មាតិកា

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ០១-០២

សេចក្តីថ្លែងរបស់អគ្គនាយក ០៣-០៥

១. ទិដ្ឋភាពទូទៅនៃអាជីវកម្ម ០៦

១.១. ទិន្នន័យហិរញ្ញវត្ថុសង្ខេប ០៧

២. ព័ត៌មានអាជីវកម្ម ១១

២.១. អំពីក្រុមហ៊ុន ១២

២.២. ផលិតផលធានារ៉ាប់រង ១៥

៣. រចនាសម្ព័ន្ធក្រុមហ៊ុន និងរបាយការណ៍អភិបាលកិច្ច ១៦

៣.១. រចនាសម្ព័ន្ធក្រុមហ៊ុន ១៧

- ក្រុមប្រឹក្សាភិបាល ១៧
- គណៈគ្រប់គ្រង ២១

៣.២. របាយការណ៍របស់គណៈកម្មាធិការ ២៥

- គណៈកម្មាធិការសវនកម្ម ២៥
- គណៈកម្មាធិការវិនិយោគ ២៦

៣.៣. របាយការណ៍អំពីអភិបាលកិច្ចសាជីវកម្ម ២៧

៤. ស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម ២៨

៤.១. ដើមទុន និងកម្រិតសោធនភាព ២៩

៤.២. ការវិនិយោគ	២៩
៤.៣. ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង	២៩
៤.៤. លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម	៣០
៤.៥. ធានារ៉ាប់រងបន្ត	៣០
៤.៦. ការគ្រប់គ្រងហានិភ័យ	៣១
៤.៧. ព័ត៌មានអំពីចីរភាព	៣៣-៤០
៥. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល	៤១-៤៨
៦. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម	៤៩-១៣៤

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះ ភាគហ៊ុនិក ដៃគូពាណិជ្ជកម្ម និងភាគីពាក់ព័ន្ធទាំងអស់

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបន្តវឌ្ឍនភាពរបស់ខ្លួន ទោះបីជាស្ថិតក្នុងបរិបទសាកល ដែលមានការប្រឈមខ្លាំងក៏ដោយ ដោយសម្រេចបាននូវកំណើន ៦,០% ក្នុងឆ្នាំ២០២៤ និង ៥,៣% ក្នុងឆ្នាំ២០២៥។ កំណើននេះត្រូវបានរំពឹងថានឹងថមថយមកនៅត្រឹមប្រមាណ ៤,២% ក្នុងឆ្នាំ២០២៦ ប៉ុន្តែត្រូវបានព្យាករថានឹងងើបឡើងវិញដល់ ៥,០% ក្នុងឆ្នាំ២០២៧។

ប្រទេសកម្ពុជាបានបន្តរក្សាភាពធន់ ដែលគាំទ្រដោយពាណិជ្ជកម្ម ការវិនិយោគ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការរួមចំណែកពីវិស័យឯកជន ព្រមទាំងបន្តដំណើរឆ្ពោះទៅរកការចាកចេញពីស្ថានភាពជាប្រទេសចំណូលមធ្យមកម្រិតទាប ដើម្បីឈានទៅសម្រេចបាននូវ ឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ខណៈដែលកម្ពុជាស្វែងរកការទាក់ទាញការវិនិយោគក្នុងស្រុក និងបរទេសឱ្យបានកាន់តែច្រើន ការអភិវឌ្ឍយន្តការកាត់បន្ថយហានិភ័យវិនិយោគប្រកបដោយប្រសិទ្ធភាព បានក្លាយជាកិច្ចការកាន់តែមានសារៈសំខាន់។ ក្នុងបរិបទនេះ ការធានារ៉ាប់រង និងធានារ៉ាប់រងបន្ត ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ទំនុកចិត្តរបស់អ្នកវិនិយោគ ការការពារទ្រព្យសកម្មរបស់ធុរកិច្ច ការសម្របសម្រួលលទ្ធភាពទទួលបានហិរញ្ញប្បទាន និងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែង។ ការវិវត្តទាំងនេះបានគូសបញ្ជាក់បន្ថែមអំពីសារៈសំខាន់នៃវិស័យហិរញ្ញវត្ថុ រួមទាំងឧស្សាហកម្មធានារ៉ាប់រងដ៏រឹងមាំ និងមានភាពធន់ ដែលមានសមត្ថភាពគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

ក្នុងឆ្នាំ២០២៥នេះ ទីផ្សារធានារ៉ាប់រងបានដំណើរការក្នុងបរិយាកាសប្រកួតប្រជែងកាន់តែខ្លាំង។ ទោះបីជាទីផ្សារបានបន្តរីកចម្រើន ប៉ុន្តែអត្រាកំណើនមានការថយចុះ ហើយសម្ពាធលើការវាយតម្លៃហានិភ័យធានារ៉ាប់រងបានកើនឡើង។ ការទាមទារសំណងលើប្រភេទផលិតផលធានារ៉ាប់រងសំខាន់ៗមួយចំនួនមាន កម្រិតកាន់តែខ្ពស់ ដែលនាំឱ្យមានការកើនឡើងនូវសម្ពាធលើប្រាក់ចំណេញនៅទូទាំងឧស្សាហកម្មទាំងមូល។ លក្ខខណ្ឌបែបនេះបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការវាយតម្លៃហានិភ័យធានារ៉ាប់រងប្រកបដោយវិន័យ ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និងចីរភាពនៃការអភិវឌ្ឍទីផ្សាររយៈពេលវែង។

ទោះជាយ៉ាងណា **ក្រុមហ៊ុន កម្ពុជា រី** នៅតែអាចរក្សាបាននូវភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ស្ថិរភាពប្រតិបត្តិការ និងទំនុកចិត្តពីអតិថិជននិងដៃគូពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យប្រកបដោយវិន័យ ការអនុវត្តអភិបាលកិច្ចសាជីវកម្មល្អ ការពង្រឹងអនុលោមភាពច្បាប់និងបទប្បញ្ញត្តិ និងការប្តេជ្ញាចិត្តក្នុងការបង្កើតតម្លៃរយៈពេលវែងសម្រាប់ភាគីពាក់ព័ន្ធទាំងអស់។

ជាលទ្ធផល ក្រុមហ៊ុនសម្រេចបានបុព្វលាភធានារ៉ាប់រងបន្តដុលសរុបចំនួន២០,៩៦ លានដុល្លារអាម៉េរិក ដែលកើនឡើង៥,២% ធៀបនឹងឆ្នាំ២០២៤។ លទ្ធផលនេះបង្ហាញពីភាពជឿជាក់របស់ទីផ្សារចំពោះសមត្ថភាព និងតួនាទីរបស់**ក្រុមហ៊ុន កម្ពុជា រី** ក្នុងការផ្តល់នូវដំណោះស្រាយផ្ទេរហានិភ័យប្រកបដោយប្រសិទ្ធភាព និងការគាំទ្រដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា។ ជាមួយគ្នានេះ ក្រុមហ៊ុនបានរក្សាកម្រិតសោធនភាពខ្ពស់ច្រើនជាងកម្រិតកំណត់អប្បបរមាច្រើនដង។ សមិទ្ធផលនេះឆ្លុះបញ្ចាំងពីមូលដ្ឋានហិរញ្ញវត្ថុដ៏រឹងមាំ សមត្ថភាពទទួលហានិភ័យ និងការត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយតបទៅនឹងភាពមិនប្រាកដប្រជានានា ដែលអាចកើតមានក្នុងបរិយាកាសអាជីវកម្ម។

ក្រៅពីលទ្ធផលហិរញ្ញវត្ថុ ក្រុមហ៊ុនបានបន្តបំពេញតួនាទីយុទ្ធសាស្ត្ររបស់ខ្លួនយ៉ាងសកម្មក្នុងការគាំទ្រដល់ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងនៅកម្ពុជា តាមរយៈការគាំទ្រការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈធានារ៉ាប់រង ការចែករំលែកចំណេះដឹងបច្ចេកទេស ការគាំទ្រដល់ការរក្សាទុកហានិភ័យធានារ៉ាប់រងនៅក្នុងប្រទេស និងការចូលរួមក្នុងគំនិតផ្តួចផ្តើមនានាដែលមានគោលបំណងលើកកម្ពស់ស្ថិរភាព ភាពធន់ និងភាពប្រកួតប្រជែងរបស់វិស័យធានារ៉ាប់រងទាំងមូល។

ក្នុងដំណើរឆ្ពោះទៅមុខ យើងនៅតែរំពឹងថាប្រតិបត្តិការទីផ្សារធានារ៉ាប់រងនៅកម្ពុជានៅតែស្ថិតក្នុងបរិយាកាសប្រកួតប្រជែងខ្លាំងដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ដល់ការពង្រឹងវិន័យនៃការវាយតម្លៃហានិភ័យធានារ៉ាប់រង និងគុណភាពសេវាកម្ម ដែលជាមូលដ្ឋានរឹងមាំនៃអភិវឌ្ឍនិងពង្រឹងទំនុកចិត្តចំពោះទីផ្សារធានារ៉ាប់រងប្រកបដោយចីរភាព។ ទោះបីជាយ៉ាងណាក៏ដោយ មូលដ្ឋានគ្រឹះសេដ្ឋកិច្ចរយៈពេលវែងរបស់កម្ពុជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ លំហូរវិនិយោគដែលកំពុងកើនឡើង និងការយល់ដឹងកាន់តែច្រើនឡើងអំពីការការពារហានិភ័យ នឹងនៅតែបន្តផ្តល់ឱកាសវិជ្ជមានសម្រាប់វិស័យធានារ៉ាប់រង។ **ក្រុមហ៊ុន កម្ពុជា រី** នៅតែបន្តប្តេជ្ញាចិត្តក្នុងការគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចិរភាពនៃឧស្សាហកម្មនេះ ព្រមទាំងផ្តល់តម្លៃរយៈពេលវែងជូនដល់ភាគហ៊ុនិក និងភាគីពាក់ព័ន្ធនានាដូចៗគ្នា។

ជាទីបញ្ចប់ ក្នុងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ រាជរដ្ឋាភិបាលកម្ពុជា និយ័តករធានារ៉ាប់រងកម្ពុជា ភាគទុនិក គណៈគ្រប់គ្រងនិងបុគ្គលិកគ្រប់លំដាប់ថ្នាក់ អតិថិជន ដៃគូពាណិជ្ជកម្ម និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ទំនុកចិត្ត កិច្ចសហការ និងការគាំទ្រយ៉ាងខ្ជាប់ខ្ជួនដល់ **ក្រុមហ៊ុន កម្ពុជា រី** ក្នុងរយៈពេលកន្លងមក។ ការគាំទ្ររបស់លោកអ្នក គឺជាកម្លាំងជំរុញដ៏សំខាន់ដែលអនុញ្ញាតឱ្យយើងបន្តសម្រេចបាននូវភាពជោគជ័យ និងបន្តបង្កើតតម្លៃជូនសង្គម និងសេដ្ឋកិច្ចជាតិ។

ដោយក្តីគោរព

រស់ សីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

សេចក្តីថ្លែងរបស់អគ្គនាយក

ជូនចំពោះ ភាគហ៊ុនិក អតិថិជន និងដៃគូអាជីវកម្មទាំងអស់

ក្នុងនាមគណៈគ្រប់គ្រងនៃ**ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"** ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២៥ ដែលឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែង សមិទ្ធផល និងវឌ្ឍនភាពសំខាន់ៗដែលក្រុមហ៊ុនសម្រេចបានក្នុងអំឡុងឆ្នាំកន្លងមក។

ឆ្នាំ២០២៥ ត្រូវបានកត់សម្គាល់ដោយកំណើនទីផ្សារដែលមានភាពយឺតយ៉ាវជាងបណ្តាឆ្នាំកន្លងមក និងការកើនឡើងនូវបញ្ហាប្រឈមក្នុងការវាយតម្លៃហានិភ័យធានារ៉ាប់រង នៅក្នុងទីផ្សារធានារ៉ាប់រងទាំងមូល។ ការកើនឡើងនៃការទាមទារសំណងកាន់តែខ្ពស់ ជាពិសេសនៅក្នុងប្រភេទផលិតផលធានារ៉ាប់រងទូទៅចម្បងៗ ការប្រកួតប្រជែងកាន់តែខ្លាំងនៅក្នុងទីផ្សារ ការប្រែប្រួលនៃបរិយាកាសសេដ្ឋកិច្ច និងការកើនឡើងនៃហានិភ័យថ្មីៗ បានបន្តដាក់សម្ពាធលើប្រាក់ចំណេញនៅទូទាំងទីផ្សារទាំងមូល។

ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ **ក្រុមហ៊ុន កម្ពុជា រី** សម្រេចបាននូវបុព្វលាភធានារ៉ាប់រងដុលចំនួន ២០,៩៦ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៥ កើនឡើង ៥,៣% ធៀបនឹងឆ្នាំមុន និងខ្ពស់ជាងកំណើននៃទីផ្សារធានារ៉ាប់រងទូទៅ ដែលជាផ្នែកគ្របដណ្តប់លើសំពៀតអាជីវកម្មរបស់**ក្រុមហ៊ុន កម្ពុជា រី**។ លទ្ធផលនេះបង្ហាញឱ្យឃើញពីសមត្ថភាពរបស់**ក្រុមហ៊ុន កម្ពុជា រី** ក្នុងការផ្តល់សេវាកម្មប្រកបដោយគុណភាព និងការឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារបានយ៉ាងមានប្រសិទ្ធភាព។ ទន្ទឹមនេះ **ក្រុមហ៊ុន កម្ពុជា រី** មានចំណែកទីផ្សារ ២៣,៣% ធៀបនឹងទីផ្សារធានារ៉ាប់រងបន្តសរុប ខណៈដែលអនុបាតរក្សាទុកបុព្វលាភរបស់ក្រុមហ៊ុនមានកម្រិត ៧៨,២% ដែលឆ្លុះបញ្ចាំងពីទំនុកចិត្តទៅលើគុណភាព និងការធ្វើពិពិធកម្មនៃសំពៀតអាជីវកម្មរបស់ខ្លួន។

ខណៈពេលដែលកំណើនបុព្វលាភធានារ៉ាប់រងនៅតែមានភាពវិជ្ជមាន លទ្ធផលនៃវាយតម្លៃហានិភ័យធានា-រ៉ាប់រង ត្រូវបានប៉ះពាល់ដោយសារការកើនឡើងនៃប្រកួតប្រជែងខ្លាំង ក៏ដូចជាការកើនឡើងនៃចំនួននិងទំហំនៃការទាមទារសំណង ដែលភាគច្រើនជាសំណងដែលកើតឡើងនៅក្នុង ប្រភេទធានារ៉ាប់រងសុខភាព និងវេជ្ជ-សាស្ត្រធានារ៉ាប់រងអគ្គិភ័យនិងធានារ៉ាប់រងយានយន្ត។ ទោះស្ថិតក្នុងបរិយាកាសប្រតិបត្តិការដ៏លំបាកនេះក៏ដោយ ក្រុមហ៊ុននៅតែរក្សាបាននូវប្រាក់ចំណេញវិជ្ជមាន ប៉ុន្តែមានការថមថយ ពោលគឺ ប្រាក់ចំណេញពីការធានារ៉ាប់រងសុទ្ធបានធ្លាក់ចុះមកនៅត្រឹម ២,១៨ លានដុល្លារអាម៉េរិក ហើយប្រាក់ចំណេញសុទ្ធសម្រាប់ធ្លាក់មកនៅត្រឹមចំនួន ០,៨៨ លានដុល្លារអាម៉េរិក។

លទ្ធផលការងារវិនិយោគបានបន្តផ្តល់នូវស្ថិរភាព និងការគាំទ្រដល់លទ្ធផលសរុបរបស់ក្រុមហ៊ុន ដោយការគ្រប់គ្រងមូលនិធិវិនិយោគរបស់យើងបានផ្តល់អត្រាទិន្នផលប្រមាណ ៦,២% ដែលលើសពីកម្រិតស្តង់ដារទីផ្សារបច្ចុប្បន្ន ខណៈដែលកម្រិតហានិភ័យ នៃការវិនិយោគនៅតែរក្សាបានសមស្របតាមបទប្បញ្ញត្តិជាធរមាន។ ជាមួយគ្នានេះ ស្ថានភាពសាធនភាពរបស់ក្រុមហ៊ុនបានបន្តស្ថិតក្នុងកម្រិតមួយខ្ពស់ជាងច្រើនដងនៃកម្រិតតម្រូវដោយច្បាប់ ដែលបង្ហាញពីភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ជាពិសេសការទូទាត់សំណងបានរហ័ស សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការទទួលយកហានិភ័យ ការស្រូបយកភាពមិនប្រាកដប្រជា និងការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធគ្រប់ពេលវេលា។

ក្រៅពីលទ្ធផលការងារហិរញ្ញវត្ថុ យើងបានបន្តពង្រឹងទំនាក់ទំនងជាមួយក្រុមហ៊ុនធានារ៉ាប់រងជាអតិថិជន និងដៃគូពាណិជ្ជកម្មទាំងអស់ ដោយបានរៀបចំវេទិកាថ្នាក់ដឹកនាំក្នុងឧស្សាហកម្ម សិក្ខាសាលាបច្ចេកទេស និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ការចែករំលែកចំណេះដឹង ការបង្កើតថ្មី និងការអភិវឌ្ឍទីផ្សារប្រកបដោយចីរភាព។ គំនិតផ្តួចផ្តើមទាំងនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើង មិនត្រឹមតែក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តប៉ុណ្ណោះទេ ប៉ុន្តែក៏ក្នុងនាមជាដៃគូដ៏គួរឱ្យទុកចិត្តក្នុងការជំរុញការអភិវឌ្ឍវិស័យធានារ៉ាប់រងរបស់កម្ពុជាផងដែរ។

ឧត្តមភាពប្រតិបត្តិការនៅតែជាអាទិភាពចម្បង។ ក្រុមហ៊ុនបានបន្តវិនិយោគលើការអភិវឌ្ឍមូលធនមនុស្ស លើកកម្ពស់វប្បធម៌ការងារប្រកបដោយវិជ្ជាជីវៈ ពង្រឹងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសហគ្រាស ពង្រឹងអនុ-លោមភាពនិងការត្រួតពិនិត្យផ្ទៃក្នុង និងកែលម្អប្រសិទ្ធភាពប្រតិបត្តិការ ដើម្បីធានាថាក្រុមហ៊ុននៅតែមានភាពធន់ និងត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត។

ក្នុងនាមជាក្រុមហ៊ុនដែលមានការទទួលខុសត្រូវចំពោះសង្គម **ក្រុមហ៊ុន កម្ពុជា រី** បានបន្តចូលរួមគាំទ្រសកម្មភាពសង្គម ការអប់រំ និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងគំនិតផ្តួចផ្តើមផ្សេងៗដែលរួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ។ យើងជឿជាក់ថា ភាពជោគជ័យរបស់ក្រុមហ៊ុនត្រូវដើរទន្ទឹមគ្នាជាមួយការរួមចំណែកវិជ្ជមានដល់សហគមន៍ និងសង្គម។

ឆ្ពោះទៅមុខ ឆ្នាំ២០២៦និងឆ្នាំបន្តបន្ទាប់នឹងបន្តនាំមកនូវការផ្លាស់ប្តូរ និងបញ្ហាប្រឈមថ្មីៗ។ ក្រុមហ៊ុននឹងបន្តផ្តោតលើ ការពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យ ការខិតខំប្រឹងប្រែងកែលម្អការវាយតម្លៃហានិភ័យធានារ៉ាប់រង ការពង្រឹងគុណភាពសំពៀតហានិភ័យធានារ៉ាប់រង ការអភិវឌ្ឍផលិតផលនិងសេវាកម្ម ការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ និងការបង្កើនប្រសិទ្ធភាពប្រតិបត្តិការជាបន្តបន្ទាប់។ យើងនៅតែបន្តប្តេជ្ញាចិត្តក្នុងការគាំទ្រដល់អតិថិជនរបស់យើង ពង្រឹងភាពធន់របស់ទីផ្សារ និងបំពេញតួនាទីរបស់យើងជាក្រុមហ៊ុនធានារ៉ាប់រងបន្តជាតិរបស់កម្ពុជា។

យើងនៅតែមានជំនឿយ៉ាងមុតមាំថា **ក្រុមហ៊ុន កម្ពុជា រី** មានសមត្ថភាព និងមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការបន្តបង្កើតគុណតម្លៃជូនភាគហ៊ុនិក អតិថិជន និងភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងបន្តបំពេញតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រង និងសេដ្ឋកិច្ចជាតិ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះក្រុមប្រឹក្សាភិបាល ដែលបានផ្តល់នូវការដឹកនាំ និងទិសដៅជាយុទ្ធសាស្ត្រ និង ការគាំទ្រពេញទំហឹង ចំពោះគណៈគ្រប់គ្រងនិងបុគ្គលិកគ្រប់លំដាប់ថ្នាក់។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ អតិថិជន ដៃគូពាណិជ្ជកម្ម ភាគហ៊ុនិក បុគ្គលិកគ្រប់លំដាប់ថ្នាក់ និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ទំនុកចិត្ត និងកិច្ចសហការយ៉ាងល្អប្រសើរដល់ **ក្រុមហ៊ុន កម្ពុជា រី**។ សមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០២៥ គឺជាលទ្ធផលនៃការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងរួមគ្នា។

ដោយក្តីគោរព

ហ៊ុយ វ៉ាថារ៉ូ

អគ្គនាយក

១

ទិដ្ឋភាពទូទៅនៃអាជីវកម្ម

១.១.ទិន្នន័យហិរញ្ញវត្ថុសង្ខេប

របាយការណ៍លទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០២៥ វិស័យធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជាបានបន្តបង្ហាញនូវកំណើនវិជ្ជមាន ដោយបុព្វលាភធានារ៉ាប់រងដុលសរុបរបស់ទីផ្សារសម្រេចបានប្រមាណ ៣៦៦,៧ លានដុល្លារអាម៉េរិក កើនឡើងពី ៣៥៧,១ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤។ ក្នុងនោះ បុព្វលាភធានារ៉ាប់រងទូទៅមានចំនួន ១៥១,៧ លានដុល្លារអាម៉េរិក និងបុព្វលាភធានារ៉ាប់រងអាយុជីវិតមានចំនួន ២០៣,៨ លានដុល្លារអាម៉េរិក ដែលឆ្លុះបញ្ចាំងពីការបន្តពង្រីកសក្តានុពល និងការកើនឡើងនៃការយល់ដឹងរបស់សាធារណជនចំពោះសេវាធានារ៉ាប់រង **[1]** ។

ស្របពេលជាមួយគ្នានេះ **ក្រុមហ៊ុន កម្ពុជា រ៉ី** បានបន្តរក្សានូវស្ថិរភាពហិរញ្ញវត្ថុ និងសមត្ថភាពប្រតិបត្តិការយ៉ាងរឹងមាំ ទោះបីជាបរិយាកាសអាជីវកម្មប្រឈមនឹងសម្ពាធនៃការទាមទារសំណងកើនឡើងក៏ដោយ។ ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនសម្រេចបានបុព្វលាភធានារ៉ាប់រងដុលសរុបចំនួន ២០,៩៦ លានដុល្លារអាម៉េរិក កើនឡើង ៥,៣% បើធៀបនឹងឆ្នាំ២០២៤។ ប្រាក់ចំណេញពីការធានារ៉ាប់រងសម្រេចបាន ២,១៨ លានដុល្លារអាម៉េរិក ខណៈប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំមានចំនួន ០,៨៨ លានដុល្លារអាម៉េរិក។

ទោះបីជាកញ្ចប់ប្រាក់សំណងដុលដែលបានទូទាត់សរុបមានចំនួន ៨,៩៩ លានដុល្លារអាម៉េរិកថយចុះពី ១១,០១ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤ ក៏ដោយ ប៉ុន្តែសំណងសុទ្ធបានកើនឡើងពី ៨,០២ លានដុល្លារ-អាម៉េរិក មកដល់ ៩,៤៦ លានដុល្លារអាម៉េរិក។ ការកើនឡើងនេះបណ្តាលមកពីការកើតមានសំណងទំហំតូចៗជាញឹកញាប់ជាងមុន ជាពិសេសក្នុងប្រភេទអាជីវកម្មមួយចំនួន ដែលបន្តដាក់សម្ពាធលើលទ្ធផលធានារ៉ាប់រងរបស់ក្រុមហ៊ុន។

ឯកតាគិតជាលានដុល្លារអាម៉េរិក	២០២៣ បានធ្វើសវនកម្ម	២០២៤ បានធ្វើសវនកម្ម	២០២៥ បានធ្វើសវនកម្ម
ទិន្នន័យហិរញ្ញវត្ថុជាច់ដោយឡែកសង្ខេប			
បុព្វលាភធានារ៉ាប់រងដុលសរុប	១៩,០១	១៩,៩១	២០,៩៦
ប្រាក់ចំណេញពីការធានារ៉ាប់រង	៣,៤៧	២,៤៥	២,១៨
ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ	២,៤៨	១,៣៧	០,៨៨
ទ្រព្យសកម្មសរុប	៤៧,៩៣	៤៩,៥៤	៤៨,០៦
មូលធនសរុប	២៧,៧៧	២៧,៦៩	២៧,៧៧
បំណុលកិច្ចសន្យាធានារ៉ាប់រង	១១,៨៦	១១,៥៥	១៣,១៦
កម្រិតសាធនភាព	៣៩៦%	៣៩៥%	៣៩៦%

[1]៖ សមាគមធានារ៉ាប់រងកម្ពុជា

ឯកតាគិតជាលានដុល្លារអាម៉េរិក	២០២៣ បានធ្វើសវនកម្ម	២០២៤ បានធ្វើសវនកម្ម	២០២៥ បានធ្វើសវនកម្ម
ទិន្នន័យហិរញ្ញវត្ថុមសង្ខេប			
បុព្វលាភធានារ៉ាប់រងដុលសរុប	១៩,០១	១៩,៩១	២០,៩៦
ប្រាក់ចំណេញពីការធានារ៉ាប់រង	៣,៤៧	២,៤៥	២,២៨
ប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ	២,៤៨	១,១២	០,៥២
ទ្រព្យសកម្មសរុប	៤៨,១៧	៤៩,៥៦	៤៧,៩១
មូលធនសរុប	២៨,០១	២៧,៦៧	២៧,៤០
បំណុលកិច្ចសន្យាធានារ៉ាប់រង	១១,៨៦	១១,៥៥	១៣,២២
កម្រិតសាធនភាព	៣៩៩%	៣៩៤%	៣៩០%

ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ក្រុមហ៊ុនមានទ្រព្យសកម្មសរុបចំនួន ៤៨,០៦ លានដុល្លារអាម៉េរិក មូលធនសរុបចំនួន ២៧,៧៧ លានដុល្លារអាម៉េរិក និងបំណុលកិច្ចសន្យាធានារ៉ាប់រងចំនួន ១៣,១៦ លាន-ដុល្លារអាម៉េរិក។ រចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅតែមានភាពរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការគាំទ្រដល់កំណើនអាជីវកម្ម និងការទទួលខុសត្រូវចំពោះកាតព្វកិច្ចធានារ៉ាប់រងនាពេលអនាគត។

ក្នុងអំឡុងឆ្នាំ២០២៥ ទំហំវិនិយោគរបស់ក្រុមហ៊ុនបានថយចុះមកត្រឹម ២៦,៧២ លានដុល្លារអាម៉េរិក បើធៀបនឹង ២៩,៤២ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤។ ការផ្លាស់ប្តូរនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់ និងការរៀបចំរចនាសម្ព័ន្ធទ្រព្យសកម្មឱ្យស្របតាមតម្រូវការប្រតិបត្តិការ និងគម្រោងវិនិយោគរយៈពេលវែងរបស់ក្រុមហ៊ុន។ ជាមួយគ្នានេះ គណនីត្រូវទទួលពីប្រតិបត្តិការធានារ៉ាប់រងបានថយចុះមកត្រឹម ៧,១២ លានដុល្លារអាម៉េរិក ពី ៩,១៧ លានដុល្លារអាម៉េរិក ដែលបង្ហាញពីការពង្រឹងប្រសិទ្ធភាពនៃការប្រមូលបំណុល និងការគ្រប់គ្រងដើមទុនប្រតិបត្តិការ។

ទន្ទឹមនឹងនេះ អចលនទ្រព្យ និងបរិក្ខាររបស់ក្រុមហ៊ុនបានកើនឡើងយ៉ាងគួរឱ្យកត់សម្គាល់ ដល់ចំនួន ៩,៣៣ លានដុល្លារអាម៉េរិក បើធៀបនឹង ៦,៣៦ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤។ ការកើនឡើងនេះមកពីការវិនិយោគលើគម្រោងសាងសង់អគារការិយាល័យថ្មី និងការទិញឧបករណ៍ បរិក្ខារ និងសម្ភារៈបច្ចេកទេសនានា ដើម្បីគាំទ្រដល់ការពង្រឹងសមត្ថភាពប្រតិបត្តិការ និងការអភិវឌ្ឍអាជីវកម្មក្នុងរយៈពេលវែង។

ស្ថានភាពហិរញ្ញវត្ថុ (ត)

ជាពិសេស ក្រុមហ៊ុនបានបន្តរក្សាកម្រិតសោធនភាព នៅកម្រិត ៣៩៦% ដែលខ្ពស់ជាងលក្ខខណ្ឌតម្រូវអប្បបរមាតាមបទប្បញ្ញត្តិ។ សូចនាករនេះ បង្ហាញយ៉ាងច្បាស់ពីភាពរឹងមាំនៃមូលធនសមត្ថភាពទទួលយកហានិភ័យ និងស្ថិរភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ វាក៏ជាកត្តាសំខាន់ដែលជួយពង្រឹងទំនុកចិត្តរបស់ភាគទុនិក អតិថិជន ដៃគូអាជីវកម្ម ចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ច និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់វិស័យធានារ៉ាប់រងកម្ពុជានាពេលអនាគត។



អនុបាត និងសូចនាករហិរញ្ញវត្ថុសំខាន់ៗ

	២០២៣ បានធ្វើសវនកម្ម	២០២៤ បានធ្វើសវនកម្ម	២០២៥ បានធ្វើសវនកម្ម
អនុបាត និងសូចនាករសំខាន់ៗ			
អនុបាតសាធនភាព	៣៩៦%	៣៩៥%	៣៩៦%
អនុបាតរក្សាទុកសុទ្ធ	៧៨,១%	៧៩,៣%	៧៨,២%
ចំណែកនៃការធានារ៉ាប់រងបន្តទូទៅ ធៀបនឹង បុព្វលាភធានារ៉ាប់រងដុល	៩៥,៩%	៩៦,៧%	៩៨,២%
ចំណែកនៃការធានារ៉ាប់រងបន្តអាយុជីវិត ធៀបនឹង បុព្វលាភធានារ៉ាប់រងដុល	៤,១%	៣,៣%	១,៨%

ទីផ្សារធានារ៉ាប់រងកម្ពុជា

ទីផ្សារធានារ៉ាប់រងរបស់ប្រទេសកម្ពុជាបានបន្តពង្រីកវិសាលភាពរបស់ខ្លួនបន្ថែមទៀតក្នុងឆ្នាំ២០២៥ ដោយបុព្វលាភធានារ៉ាប់រងដុលសរុប បានកើនឡើងដល់ ៣៦៦,៧ លានដុល្លារអាម៉េរិក ពីចំនួន ៣៥៧,១ លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៤ ដែលឆ្លុះបញ្ចាំងពីអត្រាកំណើនប្រចាំឆ្នាំចំនួន ២,៧ ភាគរយ ខណៈដែលអត្រាកំណើនប្រចាំឆ្នាំសម្រាប់រយៈពេល៥ឆ្នាំ គិតចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ គឺមានកម្រិត ៦,២ ភាគរយ។ ក្នុងនោះ ទីផ្សារធានារ៉ាប់រងទូទៅ សម្រេចបាន ១៥១,៧ លានដុល្លារអាម៉េរិក (កើនឡើង ២,៥ ភាគរយ) និង ទីផ្សារធានារ៉ាប់រងអាយុជីវិត សម្រេចបាន ២០៣,៨ លានដុល្លារអាម៉េរិក (កើនឡើង ១,៨ ភាគរយ)។

ទីផ្សារធានារ៉ាប់រងនៅកម្ពុជា

ឯកតាគិតជាលានដុល្លារអាម៉េរិក	២០២៤	២០២៥
បុព្វលាភធានារ៉ាប់រងដុលសរុប	៣៥៧,១	៣៦៦,៧
បុព្វលាភធានារ៉ាប់រងទូទៅ	១៤៨,០	១៥១,៧
បុព្វលាភធានារ៉ាប់រងអាយុជីវិត	២០០,២	២០៣,៨
សំណងធានារ៉ាប់រងទូទៅដែលបានទូទាត់	៥៦,០	៤៨,៣
សំណងធានារ៉ាប់រងអាយុជីវិតដែលបានទូទាត់	៣២,៧	៣១,៥

ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

ទំហំសំណងដែលបានទូទាត់ក្នុងការធានារ៉ាប់រងទូទៅបានថយចុះពី ៥៦ លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៤ មកត្រឹម ៤៨,៣លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៥ ខណៈដែលសំណងដែលបានទូទាត់ក្នុងការធានារ៉ាប់រងអាយុ-ជីវិត បានធ្លាក់ចុះពី ៣២,៧ លានដុល្លារអាម៉េរិក មកត្រឹម ៣១,៥ លានដុល្លារអាម៉េរិក។ ការធានារ៉ាប់រងសុខភាពបានបង្ហាញពីអត្រាកំណើនបុព្វលាភរ៉ាប់រងខ្លាំងជាងគេនៅក្នុងផ្នែកធានារ៉ាប់រងទូទៅ ដោយឡែកការធានា-រ៉ាប់រងលើអចលនទ្រព្យ នៅតែជាប្រភេទផលិតផលធំជាងគេបង្អស់ ហើយផលិតផលធានារ៉ាប់រងទាយជ្ជទាន (ការពារ និងសន្សំ) នៅតែបន្តដើរតួនាទីលេចធ្លោជាងគេនៅក្នុងផ្នែកធានារ៉ាប់រងអាយុជីវិត។

២

ព័ត៌មានអាជីវកម្ម

២.១. អំពីក្រុមហ៊ុន

ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ("ក្រុមហ៊ុន កម្ពុជា រី") ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០២ ក្នុងទម្រង់ជាក្រុមហ៊ុនរដ្ឋ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រងរបស់ប្រទេសកម្ពុជាដែលទើបនឹងចាប់ផ្តើមរូបរាងឡើង។ ចាប់ពីឆ្នាំ២០០៤មក **ក្រុមហ៊ុន កម្ពុជា រី** បានផ្លាស់ប្តូរទម្រង់ទៅជាក្រុមហ៊ុនចម្រុះដែលមានភាគកម្មសាធារណៈជាចំនួនភាគច្រើន ព្រមទាំងមានវិនិយោគិនយុទ្ធសាស្ត្រផ្សេងទៀតចូលរួមជាមួយ។

ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់ជាតិ ដែលមានវត្តមានរយៈពេលវែង នៅក្នុងទីផ្សារធានារ៉ាប់រងនៅកម្ពុជា **ក្រុមហ៊ុន កម្ពុជា រី** បានបង្គរនូវចំណេះដឹងល្អៗ និងស្ថិតិស្តីអំពីប្រភេទ និងប្រវត្តិហានិភ័យនានានៅក្នុងទីផ្សារ។ យើងបានផ្តល់ជូននូវ ដំណោះស្រាយផ្ទេរហានិភ័យសមស្របដើម្បីរំលែកហានិភ័យនានានិងគាំទ្រវឌ្ឍនភាពអាជីវកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងដើម។

ក្រុមហ៊ុន កម្ពុជា រី ផ្តល់ជូននូវសេវាកម្មធានារ៉ាប់រងបន្តយ៉ាងទូលំទូលាយសម្រាប់គ្រប់ប្រភេទហានិភ័យទាំងផ្នែកធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិត ដោយឈរលើគោលការណ៍វិជ្ជាជីវៈ នវានុវត្តន៍ ប្រសិទ្ធភាព និងការឆ្លើយតបយ៉ាងរហ័សទៅនឹងតម្រូវការរបស់អតិថិជន។ ក្រុមហ៊ុនបន្តអភិវឌ្ឍផលិតផល និងដំណោះស្រាយថ្មីៗ ដើម្បីជួយដល់ដៃគូអាជីវកម្មក្នុងការគ្រប់គ្រងហានិភ័យកាន់តែមានប្រសិទ្ធភាព ស្របតាមស្តង់ដារអន្តរជាតិ និងបរិបទទីផ្សារកម្ពុជា។

ចក្ខុវិស័យ

ក្រុមហ៊ុន កម្ពុជា រី មានចក្ខុវិស័យវែងឆ្ងាយក្នុងការក្លាយខ្លួនជាដៃគូយុទ្ធសាស្ត្រក្នុងការផ្តល់ដំណោះស្រាយធានារ៉ាប់រងបន្ត ប្រកបដោយការពេញចិត្ត និងទំនុកចិត្ត ដោយដើរតួនាទីយ៉ាងសំខាន់ក្នុង ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងប្រកបដោយភាពធន់ ការបង្កើនសមត្ថភាពទទួលយកហានិភ័យ និងការពង្រីក វត្តមានរបស់ខ្លួនទៅទីផ្សារក្រៅប្រទេសដើម្បីរួមចំណែកដល់ ការរក្សាស្ថិរភាពហិរញ្ញវត្ថុនៅក្នុងតំបន់។

បេសកកម្ម

ក្រុមហ៊ុន កម្ពុជា រី ប្តេជ្ញាបំពេញបេសកកម្មរបស់ខ្លួនក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តជាតិ តាមរយៈការអនុវត្តគោលដៅសំខាន់ៗដូចខាងក្រោម៖

- លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មធានារ៉ាប់រង និងធានារ៉ាប់រងបន្ត និងវិជ្ជាជីវៈនិយម
- ផ្តល់នូវដំណោះស្រាយធានារ៉ាប់រងបន្តសមស្រប ទុកចិត្តបាន និងប្រកបដោយនវានុវត្តន៍
- ជាមជ្ឈមណ្ឌលសម្រាប់ប្រមូលផ្តុំ និងចែករំលែកទិន្នន័យអំពីហានិភ័យទីផ្សារ
- បង្កើនតម្លៃរបស់ភាគហ៊ុនិក និងអ្នកពាក់ព័ន្ធ រួមទាំង អតិថិជន ដៃគូអាជីវកម្ម និងនិយោជិត
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍទីផ្សារធានារ៉ាប់រង និងការគ្រប់គ្រងហានិភ័យ នៅក្នុងប្រទេស រួមទាំងការកាត់បន្ថយលំហូរមូលធនទៅក្រៅប្រទេសដោយសារតែទីផ្សារក្នុងស្រុក មិនទាន់មានការអភិវឌ្ឍល្អ និងសមត្ថភាពរក្សាទុកបុព្វលាភមានកម្រិត។

គុណតម្លៃ

សុច្ចរិតភាព

ក្រុមហ៊ុនប្រកបអាជីវកម្ម ប្រកបដោយឥរិយាបថវិជ្ជាជីវៈ និងក្រមសីលធម៌ស្របតាមស្តង់ដារខ្ពស់ ដើម្បីធានាបាននូវកេរ្តិ៍ឈ្មោះ និងការជឿទុកចិត្តកម្រិតខ្ពស់

កត្តាមនុស្ស

ក្រុមហ៊ុនមានមោទនភាពក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងស្រុកឱ្យមានទេពកោសល្យខ្ពស់ ដោយបន្តលើកទឹកចិត្តពួកគេឱ្យស្ថិតនៅលើមាគ៌ានៃស្វ័យកែលម្អ និងភាពរីកចម្រើននៃអាជីព និងលើកកម្ពស់វប្បធម៌ភាពជាក្រុមហ៊ុនល្អ ដោយផ្សារភ្ជាប់ការលើកសរសើរ ទៅនឹងសមិទ្ធផលរបស់បុគ្គល និងលទ្ធផលអាជីវកម្ម

ការផ្តោតលើអតិថិជន

ក្រុមហ៊ុនមានការប្តេជ្ញាខ្ពស់ក្នុងការផ្តល់ជូនអតិថិជននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នវានុវត្តន៍ និងស្របតាមតម្រូវការ

កិច្ចសហការណ៍

ក្រុមហ៊ុនមានការប្តេជ្ញាខ្ពស់ ធ្វើការជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធនានាដើម្បី កំណើន និងការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យធានារ៉ាប់រង

សមិទ្ធផលសំខាន់ៗ

- **ការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់ទីផ្សារ៖** យើងប្តេជ្ញាផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍជំនាញវិជ្ជាជីវៈក្នុងវិស័យធានារ៉ាប់រង ដើម្បីធានាបាននូវចំនួនបុគ្គលិកវិជ្ជាជីវៈគ្រប់គ្រាន់សម្រាប់បម្រើដល់កំណើន និងនវានុវត្តន៍នៃទីផ្សារធានារ៉ាប់រងនាពេលអនាគត។ ក្នុងរយៈពេល ៩ ឆ្នាំចុងក្រោយ យើងបានផ្តល់ឱកាសជូនបុគ្គលិក ដែលកំពុងបម្រើការនៅក្នុងវិស័យធានារ៉ាប់រងចំនួន២៩១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈធានារ៉ាប់រង ក្រោមកម្មវិធីរបស់វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (MII)និង (LOMA)។

- **ការពង្រីកអាជីវកម្ម៖ ក្រុមហ៊ុន កម្ពុជា រី** បានពង្រីកសេវាកម្មគាំទ្រដល់វិស័យធានារ៉ាប់រងនៅកម្ពុជា ដោយបានបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធមួយឈ្មោះថា **ក្រុមហ៊ុន កម្ពុជា រី ប៊្លូវេនឈ័រ ឯ.ក** ។ ក្រុមហ៊ុននេះគឺជាការបណ្តាក់ទុនរួមគ្នាជាមួយដៃគូជំនាញលើការផ្តល់សេវាកម្មគ្រប់គ្រងការទាមទារសំណង ដើម្បីផ្តល់សេវាឯកទេសក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រង។ ក្រុមហ៊ុនបុត្រសម្ព័ន្ធនេះនឹងផ្តោតសំខាន់លើការគ្រប់គ្រងសំណងធានារ៉ាប់រងសុខភាព ដើម្បីចូលរួមចំណែកគាំទ្រដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជាឱ្យកាន់តែរីកចម្រើន។

អនុលោមភាពសារពើពន្ធកម្រិត "មាស"
ផ្តល់ដោយអគ្គនាយកដ្ឋានពន្ធដារ
៣លើក ជាប់គ្នា មួយលើក ២ឆ្នាំ ចាប់ពីឆ្នាំ២០២២ រហូត ដល់ឆ្នាំ ២០២៧

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

Phnom Penh, 2025

អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

វិញ្ញាបនបត្រ
អនុលោមភាពសារពើពន្ធ

លេខអត្តសញ្ញាណកម្មសារពើពន្ធ ៖ L001-100057942
ទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ ៖ មាស

CERTIFICATE OF TAX COMPLIANCE
(Prakas No 1536 MEF/PK dated 23rd December 2016)

GENERAL DEPARTMENT OF TAXATION certifies that :

Company's name : CAMBODIAN REINSURANCE COMPANY " CAMBODIA RE "

Tax Identification Number (TIN) : L001-100057942

Under : Department of large Taxpayers Date of Information Update : 03 Feb 2016

Business activity(ies) : Reinsurance

Tax Compliance Type awarded : GOLD

Validity period of 2 years for the tax year of 2026 and 2027.

Minister Attached to the Prime Minister
Delegate of the Royal Government
In charge as Director General of General Department of Taxation

គង់ វិបុល

ពានរង្វាន់ និងការទទួលស្គាល់
សម្រាប់ឧត្តមភាពសាជីវកម្ម

INTERNATIONAL FINANCE

INTERNATIONAL FINANCE
AWARDS 2019

★ ★ ★ ★ ★ ★

This is to certify that

Cambodian Reinsurance Company
"Cambodia Re"

Has been awarded

Best Education and Training Provider
- Insurance

Cambodia

★ ★ ★ ★ ★ ★

International Finance Publications Ltd.

Sunil Bhat, Director
International Finance

ពានរង្វាន់ផ្នែកអប់រំ
និងបណ្តុះបណ្តាលល្អបំផុត
សម្រាប់គាំទ្រទីផ្សារធានារ៉ាប់រង
ផ្តល់ដោយស្ថាប័ន International Finance

ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង

ការិយាល័យកណ្តាល៖ អគារលេខ១៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

អ៊ីម៉ែល៖ cambodiare@cambodiare.com.kh

ទូរស័ព្ទ៖ ០២៣ ៨៨០ ២២២ / ០១៧ ២២២ ៩៤៧

២.២.ផលិតផលធានារ៉ាប់រង

ក្រុមហ៊ុន កម្ពុជា រី ផ្តល់ការគាំទ្រនូវសមត្ថភាពធានារ៉ាប់រងបន្តនៃហានិភ័យផ្សេងៗក្នុងទម្រង់ជា **កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តគោល** និង**ការធានារ៉ាប់រងបន្តក្រៅកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តគោល** លើគ្រប់ផ្នែកនៃធានារ៉ាប់រង រួមមាន ធានារ៉ាប់រងទូទៅ ធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច។

ក្រុមហ៊ុន កម្ពុជា រី ទទួលយកគ្រប់ប្រភេទហានិភ័យនៃអាជីវកម្មធានារ៉ាប់រងទូទៅ មានដូចជា អគ្គីភ័យ យានយន្ត សុខភាព វិស្វកម្ម ការដឹកជញ្ជូន និង គ្រោះថ្នាក់ផ្សេងៗ។

ក្រុមហ៊ុន កម្ពុជា រី ផ្តល់ដំណោះស្រាយធានារ៉ាប់រងបន្តអាយុជីវិត លើហានិភ័យមរណភាព (Mortality) និង ជម្ងឺផ្សេងៗ (Morbidity) សម្រាប់ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិតនានា រួមមាន ធានារ៉ាប់រងអាយុជីវិតជាក្រុម ធានារ៉ាប់រងអាយុជីវិតជាបុគ្គល គ្រោះថ្នាក់ និង សុខភាព ។ល។

អាជីវកម្មរបស់**ក្រុមហ៊ុន កម្ពុជា រី** ត្រូវបានជំរុញជាចម្បងដោយការធានារ៉ាប់រងបន្តទូទៅ ដែលមានទំហំស្មើនឹង ៩៨,២ភាគរយ នៃបុព្វលាភធានារ៉ាប់រងសរុប ក្នុងឆ្នាំ២០២៥ ខណៈដែលការធានារ៉ាប់រងបន្តអាយុជីវិតចូលរួមចំណែកត្រឹម ១,៨ភាគរយ។ ការធានារ៉ាប់រងទ្រព្យសម្បត្តិ សុខភាព និងយានយន្ត នៅតែជាផលិតផលធានារ៉ាប់រងចម្បងនៃសំពៀតធានារ៉ាប់រងរបស់**ក្រុមហ៊ុន កម្ពុជា រី**។

៣

រចនាសម្ព័ន្ធក្រុមហ៊ុន និងរបាយការណ៍អភិបាលកិច្ច

៣.១.រចនាសម្ព័ន្ធក្រុមហ៊ុន

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល គឺជាស្ថាប័នគ្រប់គ្រងកំពូលរបស់ក្រុមហ៊ុន ដែលមានតួនាទី និងការទទួលខុសត្រូវក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ អនុម័តគោលនយោបាយសំខាន់ៗ ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់គណៈគ្រប់គ្រង ព្រមទាំងធានាថាក្រុមហ៊ុនប្រតិបត្តិការស្របតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍អភិបាលកិច្ចល្អ។

ក្រុមប្រឹក្សាភិបាលមានភារកិច្ចក្នុងការការពារ និងលើកកម្ពស់ផលប្រយោជន៍រយៈពេលវែងរបស់ក្រុមហ៊ុន ភាគហ៊ុនិក អតិថិជន និងភាគីពាក់ព័ន្ធទាំងអស់ តាមរយៈការត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងហិរញ្ញវត្ថុ ការវិនិយោគ ការអភិវឌ្ឍអាជីវកម្ម និងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។ដោយមានសមាសភាពពីថ្នាក់ដឹកនាំដែលមានបទពិសោធន៍ និងជំនាញចម្រុះពីទាំងវិស័យសាធារណៈ វិស័យហិរញ្ញវត្ថុ វិស័យធានារ៉ាប់រង និងវិស័យឯកជន ក្រុមប្រឹក្សាភិបាលរបស់ **ក្រុមហ៊ុន កម្ពុជា រី** បានផ្តល់នូវភាពជាអ្នកដឹកនាំប្រកបដោយចក្ខុវិស័យ តុល្យភាព និងគណនេយ្យភាពខ្ពស់ ក្នុងការជំរុញកំណើនប្រកបដោយចីរភាព និងការបង្កើនតម្លៃជូនភាគហ៊ុនិក និងអ្នកពាក់ព័ន្ធទាំងអស់។

ក្នុងឆ្នាំ២០២៥ ក្រុមប្រឹក្សាភិបាលបានបន្តបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មតាមរយៈការពិនិត្យ និងអនុម័តលើផែនការយុទ្ធសាស្ត្រ ផែនការអាជីវកម្ម ថវិកាប្រចាំឆ្នាំ គោលនយោបាយសំខាន់ៗ ការវិនិយោគ និងបញ្ហាយុទ្ធសាស្ត្រផ្សេងៗ ដើម្បីធានាថាក្រុមហ៊ុនអាចសម្រេចបាននូវគោលដៅអាជីវកម្ម ខណៈរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ កម្រិតសោធនភាពរឹងមាំ និងការអនុលោមតាមតម្រូវការរបស់អាជ្ញាធរនិយតកម្ម។

សមាសភាពក្រុមប្រឹក្សាភិបាលរបស់**ក្រុមហ៊ុន កម្ពុជា រី** គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានដូចខាងក្រោម៖

ឯ.ឧ រស់ សីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

ឯ.ឧ រស់ សីលវ៉ា ជាប្រធានក្រុមប្រឹក្សាភិបាលរបស់**ក្រុមហ៊ុន កម្ពុជា រី** តាំងពីឆ្នាំ២០១២មក។ ឯកឧត្តមបានរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍន៍ក្រុមហ៊ុននេះ ជាពិសេស ការជួយធ្វើឲ្យកាន់តែប្រសើរឡើងនៃប្រព័ន្ធអភិបាលកិច្ច និង តម្រង់ទិសយុទ្ធសាស្ត្រ របស់ក្រុមហ៊ុន។ ឯកឧត្តម បានចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ១៩៩៤ ហើយត្រូវបានតម្លើងតួនាទីជាហូរហែ រួមទាំងធ្លាប់ធ្វើជាទីប្រឹក្សាឲ្យ នាយកប្រតិបត្តិរបស់ធនាគារពិភពលោក នៅទីស្នាក់ការកណ្តាលផងដែរ។ បច្ចុប្បន្ន ឯកឧត្តម ជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជាកន្លែងដែលឯកឧត្តមបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និង ដឹកនាំអនុវត្ត គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ របស់រាជរដ្ឋាភិបាលកម្ពុជា។

ឯកឧត្តម ទទួលបានសញ្ញាប័ត្របរិញ្ញាបត្រ វិទ្យាសាស្ត្រសង្គម មកពីវិទ្យាស្ថាន Penza's Institute of Pedagogy អតីតសហភាពសូវៀត និង សញ្ញាប័ត្របរិញ្ញាបត្រជាន់ខ្ពស់ កិច្ចការអន្តរជាតិ ផ្នែកគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ច មកពីសាកលវិទ្យាល័យ កូឡុំប៊ី នៅទីក្រុងញូយ៉ក សហរដ្ឋអាមេរិក។

លោកជំទាវ នួន សុណេតា

សមាជិកាក្រុមប្រឹក្សាភិបាល

លោកជំទាវ នួន សុណេតា ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ **ក្រុមហ៊ុន កម្ពុជា រី** ក្នុងឆ្នាំ២០២៣ លោកជំទាវ នួន សុណេតា បាននាំមកនូវជំនាញផ្នែកច្បាប់យ៉ាងទូលំទូលាយមកកាន់ក្រុមហ៊ុន។ លោកជំទាវគឺជាសមាជិកនៃក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី និងបម្រើការជាប្រធាននាយកដ្ឋានច្បាប់កិច្ចការផ្ទៃក្នុង និងបរទេស។ លើសពីនេះ លោកជំទាវក៏ជាសមាជិកខុទ្ទកាល័យរបស់ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីផងដែរ។ លោកជំទាវទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ (ឆ្នាំ២០១៦) និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងសាធារណៈ(ឆ្នាំ២០១៩)ពីសាកលវិទ្យាល័យកម្ពុជា។

ឯកឧត្តម សាំង តូនិច

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម សាំង តូនិច ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៃ**ក្រុមហ៊ុន កម្ពុជា រី** នៅក្នុងឆ្នាំ២០២៥។ ឯកឧត្តមមានបទពិសោធន៍ជាង ៩ឆ្នាំ នៅក្នុងវិស័យច្បាប់នៅប្រទេសកម្ពុជា បន្ទាប់ពីបានបញ្ចប់ការសិក្សាពីសហរដ្ឋអាមេរិក។ ឯកឧត្តមគឺជាសមាជិកនៃគណៈមេធាវីរដ្ឋញូវយ៉ក និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន ឯកឧត្តម បម្រើការជាអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌។

ឯកឧត្តម សាំង តូនិច ទទួលបានសញ្ញាបត្រ Juris Doctor (បណ្ឌិតច្បាប់) ក្នុងឆ្នាំ២០១៦ និងសញ្ញាបត្របរិញ្ញាបត្រផ្នែកវិទ្យាសាស្រ្តនយោបាយ និងសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៣ ពីរដ្ឋញូវយ៉កសហរដ្ឋអាមេរិក។

លោក ធេឌី ហៃទ្បាំសាស

សមាជិកក្រុមប្រឹក្សាភិបាល

លោក ធេឌី ហៃទ្បាំសាស ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល **ក្រុមហ៊ុន កម្ពុជា រី** តាំងពីឆ្នាំ២០០៤មក ដែលជាតំណាងដៃគូរភាគីយុទ្ធសាស្រ្ត។ គាត់មានបទពិសោធន៍ក្នុងវិស័យធានា-រ៉ាប់រងរយៈ ពេលជាង ៤០ ឆ្នាំមកហើយ នៅប្រទេសឥណ្ឌូនេស៊ី។ នៅក្នុងថ្នាក់តំបន់គាត់បានចូលរួមយ៉ាងសកម្ម នៅក្នុងសកម្មភាពរបស់ Asian Insurance Congress និងASEAN Insurance Council ចាប់តាំងពីឆ្នាំ ១៩៩៩មក។

លោក ធេឌី ហៃទ្បាំសាស បានបញ្ចប់បរិញ្ញាបត្រពីមហាវិទ្យាល័យ South East Asia Union Colleges នៃប្រទេសសិង្ហបុរី។

លោកស្រី ហង្ស ចន្ទ
សមាជិកាក្រុមប្រឹក្សាភិបាល

លោកស្រី ហង្ស ចន្ទ ត្រូវបានតែងតាំងជាសមាជិកាក្រុមប្រឹក្សាភិបាល នៃ**ក្រុមហ៊ុន កម្ពុជា រី** ក្នុងឆ្នាំ២០២៥។ បច្ចុប្បន្ន លោកស្រីបម្រើការជាអគ្គនាយិកាប្រតិបត្តិ នៃក្រុមហ៊ុន តារា អ៊ិនស្ហួរិន ម.ក ដែលជាក្រុមហ៊ុនធានារ៉ាប់រងទូទៅ។ លោកស្រី ចន្ទ មានបទពិសោធន៍ការងារវិជ្ជាជីវៈជាង ១៩ឆ្នាំ ក្នុងវិស័យធានារ៉ាប់រង និងហិរញ្ញវត្ថុ។ ពេញមួយអាជីពរបស់លោកស្រី បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍយុទ្ធសាស្ត្រនៃស្ថាប័នហិរញ្ញវត្ថុ ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងការជំរុញលទ្ធផលវិនិយោគប្រកបដោយចីរភាព។

លោកស្រីទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ឯកទេសហិរញ្ញវត្ថុ (រួមមាន៖ ហិរញ្ញវត្ថុសាជីវកម្ម, ការគ្រប់គ្រងការវិនិយោគ និងទីផ្សារមូលធន) ពីសាកលវិទ្យាល័យ Gloucestershire ចក្រភពអង់គ្លេស។ លោកស្រីក៏ទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ឯកទេសហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាផងដែរ។ ក្រៅពីការសិក្សាថ្នាក់សាកលវិទ្យាល័យ លោកស្រីក៏ទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈកម្រិតខ្ពស់ពីស្ថាប័នអន្តរជាតិល្បីៗជាច្រើន រួមទាំងវិញ្ញាបនបត្រពីស្ថាប័ន ANZIIF ផងដែរ។

លោក ហ៊ុយ វ៉ាថារ៉ូ
សមាជិកក្រុមប្រឹក្សាភិបាល

លោក ហ៊ុយ វ៉ាថារ៉ូ ជាអគ្គនាយក និងសមាជិកក្រុមប្រឹក្សាភិបាលនៃ**ក្រុមហ៊ុន កម្ពុជា រី** ហើយក៏ជា ប្រធានសមាគមធានារ៉ាប់រងកម្ពុជា តាំងពីឆ្នាំ២០១៤ មក។ គាត់មានបទពិសោធន៍ជិត២៥ឆ្នាំ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជនដែលមានបទពិសោធន៍ការងារ ទាំងវិស័យហិរញ្ញវត្ថុ និងវិស័យមិនមែនហិរញ្ញវត្ថុ។ គាត់បានចាប់ផ្តើមអាជីពក្នុងវិស័យធានារ៉ាប់រង ដោយបម្រើការនៅស្ថាប័ននិយ័តករធានារ៉ាប់រង នៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មុនការចូលរួមនៅក្នុងវិស័យធានារ៉ាប់រង គាត់បានរួមចំណែកជាច្រើននៅក្នុងដំណើរការបង្កើតទីផ្សារមូលបត្រជាលើកដំបូងនៅកម្ពុជា។

លោកមានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍អន្តរជាតិ មកពីសាកលវិទ្យាល័យអន្តរជាតិជប៉ុន នៃប្រទេសជប៉ុន។

លោក វ័ត្ន វាសនា

សមាជិកក្រុមប្រឹក្សាភិបាល

លោក វ័ត្ន វាសនា បានចូលបម្រើការងារនៅ **ក្រុមហ៊ុន កម្ពុជា រី** ខែមេសា ឆ្នាំ២០០២ តួនាទីប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ហើយបច្ចុប្បន្នត្រូវបានជ្រើសរើសជាសមាជិកក្រុមប្រឹក្សាភិបាល តំណាងឱ្យនិយោជិត។ ជាមួយបទពិសោធន៍ជាងពីរទសវត្សរ៍ក្នុងវិស័យធានារ៉ាប់រង លោកមានជំនាញ និងចំណេះដឹងយ៉ាងទូលំ-ទូលាយលើផ្នែកគណនេយ្យហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ អភិបាលកិច្ចសាជីវកម្មនិងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។ ក្រៅពីតួនាទីស្នូលនៅ **ក្រុមហ៊ុន កម្ពុជា រី** លោកបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យធានារ៉ាប់រងជាតិ តាមរយៈការដឹកនាំគណៈកម្មាធិការសំខាន់ៗរបស់សមាគមធានារ៉ាប់រងកម្ពុជារួមមាន៖ ប្រធានគណៈកម្មាធិការគណនេយ្យ៖ ដឹកនាំ និងសម្របសម្រួលការរៀបចំគោលការណ៍ណែនាំ ព្រមទាំងការត្រៀមខ្លួនរបស់វិស័យធានា-រ៉ាប់រង ក្នុងការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (ជាពិសេស CIFRS/CIFRS ៤ និងការត្រៀមលក្ខណៈអនុវត្ត CIFRS ១៧) ដើម្បីលើកកម្ពស់តម្លាភាព និងសហគ្រាសភាពធៀបជាមួយទីផ្សារអន្តរជាតិ។ ប្រធានគណៈកម្មាធិការដោះស្រាយសំណងយាន-យន្ត៖ ដឹកនាំការរៀបចំ និងអភិវឌ្ឍនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) និងកិច្ចព្រមព្រៀងស្តីពីភារកិច្ចទទួលខុសត្រូវលើសំណងយានយន្តរវាងក្រុមហ៊ុនធានារ៉ាប់រង ដែលជាយន្តការគន្លឹះក្នុងការពង្រឹងប្រសិទ្ធភាពដោះស្រាយសំណង កាត់បន្ថយវិវាទ និងលើកកម្ពស់សណ្តាប់ធ្នាប់ទីផ្សារ។

កម្រិតវប្បធម៌ និងការអភិវឌ្ឍវិជ្ជាជីវៈ៖ លោកបានបញ្ចប់ការសិក្សាថ្នាក់បញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង (UTM) ក្នុងឆ្នាំ២០០៨។ ទន្ទឹមនឹងនេះ លោកបានឆ្លងកាត់ការបណ្តុះបណ្តាល និងទទួលបានវិញ្ញាបនបត្រជំនាញជាន់ខ្ពស់ជាបន្តបន្ទាប់ពាក់ព័ន្ធនឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ការគ្រប់គ្រងហានិភ័យ, ការវិនិយោគសាជីវកម្ម និងការគ្រប់-គ្រងហិរញ្ញវត្ថុក្នុងវិស័យធានារ៉ាប់រង។

គណៈគ្រប់គ្រង

អគ្គនាយក

លោក ហ៊ុយ វ៉ាថារ៉ូ

លោក ហ៊ុយ វ៉ាថារ៉ូ មានភាពជាអ្នកដឹកនាំបែបយុទ្ធសាស្ត្រ និងកំណត់ទិសដៅរួម ដើម្បីធានាបាននូវកំណើន និងស្ថិរភាពរបស់ក្រុម-ហ៊ុនរយៈពេលវែងរួមបញ្ចូលទាំងការដឹកនាំនិងការត្រួតពិនិត្យមុខងារសំខាន់ៗរួមមានការវាយតម្លៃហានិភ័យធានារ៉ាប់រង ការគណនាបុព្វលាភធានារ៉ាប់រង ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងការអភិវឌ្ឍធុរកិច្ច។ ក្នុងពេលជាមួយគ្នា លោកមានការប្រមើលមើលវែងឆ្ងាយ ក្នុងការជំរុញនិវន្តរភាពដើម្បីប្រសិទ្ធភាពប្រតិបត្តិការ និងធុរកិច្ចក្នុងយុគសម័យឌីជីថល។ លោកតែងប្រកាន់ខ្ជាប់នូវអនុលោមភាពច្បាប់ហើយបានចូលរួមយ៉ាងសកម្មជាមួយបុគ្គលពាក់ព័ន្ធ ដូចជានិយ័តករធានារ៉ាប់រងកម្ពុជា ដៃគូក្រុមហ៊ុនធានារ៉ាប់រង និងសមាគមធានារ៉ាប់រងកម្ពុជា ដើម្បីពង្រឹងកិច្ចសហការក្នុងការពង្រឹងវិស័យធានា-រ៉ាប់រងដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

នាយកប្រតិបត្តិការ

លោក ទី អាទិត្យ ទទួលខុសត្រូវចំពោះការរៀបចំ និងអនុវត្តយុទ្ធ-សាស្ត្រធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុន ដោយផ្ដោតលើការសម្រេចបាននូវកំណើនរយៈពេលវែង ប្រកបដោយនិរន្តរភាព និងប្រាក់ចំណេញ។ ក្នុងតួនាទីរបស់លោក លោកផ្ដល់នូវភាពជាអ្នកដឹកនាំប្រកបដោយយុទ្ធសាស្ត្រក្នុងកិច្ចប្រតិបត្តិការវាយតម្លៃហានិភ័យ ត្រួតពិនិត្យលើការរៀបចំនិងការអនុវត្តលើក្របខ័ណ្ឌវាយតម្លៃហានិភ័យ។ លោក ទិត្យ ធ្វើការយ៉ាងជិតស្និទ្ធជាមួយមុខងារផ្សេងៗដើម្បីវិភាគនិន្នាការទីផ្សារ វាយតម្លៃហានិភ័យដែលទទួលយក និងរៀបចំដំណោះស្រាយធានារ៉ាប់រងបន្ត អោយស្របតាមតម្រូវការរបស់អតិថិ-ជននិងគោលបំណងរបស់ក្រុមហ៊ុន។ កិច្ចខិតខំប្រឹងប្រែងរបស់លោកមានសារៈសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពធានារ៉ាប់រងបន្ត ដើម្បីធានាថាកិច្ចប្រតិបត្តិការលើការវាយតម្លៃនិងទទួលយកហានិភ័យទទួលបាននូវភាពប្រកួតប្រជែង ភាពធន់ទៅនឹងការប្រែប្រួលទីផ្សារ និងស្របតាមចក្ខុវិស័យធុរកិច្ចយ៉ាងទូលំទូលាយរបស់ក្រុមហ៊ុន។ ក្នុងយុទ្ធសាស្ត្រ សម្លឹងឆ្ពោះទៅមុខនិងប្រកបដោយបេសកកម្ម លោករួមចំណែកក្នុងការរក្សាជំហរក្រុមហ៊ុនក្នុងទីផ្សារធានារ៉ាប់រងបន្តដែលកំពុងវិវត្ត និងមានភាពស្មុគស្មាញ។

លោក ទី អាទិត្យ

នាយកហិរញ្ញវត្ថុ

លោក វ័ត្ន វាសនា

លោក វ័ត្ន វាសនា ជានាយកហិរញ្ញវត្ថុ ដែលមានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងវិស័យធានារ៉ាប់រង គណនេយ្យ និងហិរញ្ញវត្ថុ។ លោកគឺជាអ្នកដឹកនាំជាន់ខ្ពស់ដែលមានជំនាញ និងបទពិសោធន៍ទូលំទូលាយលើការគ្រប់គ្រងហិរញ្ញវត្ថុ អភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ ការវិនិយោគ និងការរៀបចំយុទ្ធសាស្ត្រហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់កំណើនប្រកបដោយចីរភាព និងភាពធន់របស់ក្រុមហ៊ុន។

លោកត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ចំពោះជំនាញវិជ្ជាជីវៈក្នុងការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៅកម្ពុជា និងការពង្រឹងអភិបាលកិច្ចហិរញ្ញវត្ថុស្របតាមឧត្តមានុវត្តអន្តរជាតិ។ក្រោមការដឹកនាំរបស់លោក ក្រុមហ៊ុន បានរក្សាបាននូវគុណភាពខ្ពស់នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងទទួលបានមតិសវនកម្មឯករាជ្យដោយគ្មានការកែតម្រូវជាសារវន្ត (Unmodified Audit Opinion) ជាបន្តបន្ទាប់អស់រយៈពេលជាងពីរទសវត្សរ៍ ដែលឆ្លុះបញ្ចាំងពីភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យផ្ទៃក្នុង និងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

បន្ថែមពីនេះ លោកបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជា តាមរយៈការដឹកនាំ និងការចូលរួម ក្នុងគណៈកម្មាធិការបច្ចេកទេសសំខាន់ៗនៃសមាគមធានារ៉ាប់រងកម្ពុជា ជាពិសេសលើការជំរុញការអនុវត្តស្តង់ដារគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារអន្តរជាតិ ព្រមទាំងការលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងវិស័យធានារ៉ាប់រង។ជាមួយនឹងជំនាញខ្ពស់ក្នុងការគ្រប់គ្រងសវនកម្ម ការគ្រប់-គ្រងហានិភ័យ ហិរញ្ញវត្ថុ និងការគ្រប់គ្រងសំពៀតវិនិយោគ លោកបានដឹកនាំការវិនិយោគប្រកបដោយភាពប្រុង-ប្រយ័ត្ន និងប្រសិទ្ធភាព ដែលបានរួមចំណែកពង្រឹងស្ថិរភាពហិរញ្ញវត្ថុ បង្កើនផលត្រឡប់ពីការវិនិយោគ និងគាំទ្រដល់ការបង្កើតតម្លៃរយៈពេលវែងសម្រាប់ភាគទុនិក និងភាគីពាក់ព័ន្ធទាំងអស់។

ប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម

ក្នុងនាមជាប្រធានផ្នែកអភិវឌ្ឍន៍អាជីវកម្ម **លោកស្រី ជូ សុរម្យនាថ** បានដឹកនាំអភិវឌ្ឍន៍និងអនុវត្តយុទ្ធសាស្ត្រ ដែលផ្តោតលើអតិថិជន ដោយកំណត់ឱកាសទីផ្សារថ្មី ពង្រឹងនិងពង្រីកទំនាក់ទំនងល្អជាមួយអតិថិជនសក្តានុពល និង បង្កើនវត្តមានរបស់ក្រុមហ៊ុនក្នុងទីផ្សារ។ លោកស្រី បានសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារវាយ-តម្លៃហានិភ័យធានារ៉ាប់រង អ្នកគណនាបុព្វលាភធានារ៉ាប់រង និងការកំណត់នូវហានិភ័យច្បាស់លាស់ ដើម្បីឆ្លើយតបតាមតម្រូវការធានា-រ៉ាប់រងបន្តរបស់អតិថិជន និងផ្តល់នូវដំណោះស្រាយធានារ៉ាប់រង-បន្តសមស្របប្រកបដោយវិជ្ជាជីវៈ។ ដើម្បីផ្តល់នូវដំណោះស្រាយទាំងនេះ ស្របតាមគោលដៅអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុន លោកស្រី សុរម្យនាថ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនអាជីវកម្មប្រកបដោយនិរន្តរភាព និងធានាថាក្រុមហ៊ុនមានភាពប្រកួតប្រជែងនៅក្នុងទីផ្សារ។

លោកស្រី ជូ សុរម្យនាថ

ប្រធានផ្នែកហិរញ្ញវត្ថុ

កញ្ញា ចាន់ លក្ខិណា

កញ្ញា ចាន់ លក្ខិណា ទទួលបន្ទុកក្នុងការត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ការធានាឱ្យមានរបាយការណ៍ហិរញ្ញវត្ថុច្បាស់លាស់ និងការគាំទ្រដល់ការសម្រេចចិត្តជាយុទ្ធសាស្ត្រ។ តួនាទីរបស់កញ្ញារួមមានការគ្រប់គ្រងការរៀបចំថវិកា ការព្យាករណ៍ ការវិភាគលើ ការវិនិយោគ និងការរៀបចំផែនការហិរញ្ញវត្ថុ ដើម្បីជំរុញឱ្យមានប្រាក់ចំណេញ និងចីរភាពរយៈពេលវែង។ កញ្ញាធានាឱ្យមានការអនុលោមតាមបទប្បញ្ញត្តិពន្ធដារ និងស្តង់ដារគណនេយ្យដែលពាក់ព័ន្ធ ជាពិសេសការគ្រប់គ្រងលើការអនុវត្ត និងការធ្វើរបាយការណ៍ CIFRS ១៧ និង CIFRS ៩។ តាមរយៈចំណេះដឹងហិរញ្ញវត្ថុដ៏ស៊ីជម្រៅ ការសម្របសម្រួលជាមួយដៃគូខាងក្រៅ និងការប្តេជ្ញាចិត្តចំពោះការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំ កញ្ញាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញគោលដៅយុទ្ធសាស្ត្រ របស់ក្រុមហ៊ុន និងពង្រឹងភាពធន់នៃប្រតិបត្តិការរបស់ស្ថាប័ន។

ប្រធានផ្នែកវិភាគហានិភ័យធានារ៉ាប់រងអាយុជីវិត និងសុខភាព

លោកស្រី ពេជ្រ សុគន្ធារី ប្រធាន វិភាគហានិភ័យធានារ៉ាប់រងអាយុជីវិត និងសុខភាព, មានតួនាទីយ៉ាងសំខាន់ក្នុងការវាយតម្លៃហានិភ័យ និងការសម្រេចចិត្តទទួលយកហានិភ័យលើធានារ៉ាប់រងអាយុជីវិត និងសុខភាព។ លោកស្រីទទួលខុសត្រូវក្នុងការវាយតម្លៃហានិភ័យនៃការធានារ៉ាប់រង និងធ្វើការសម្រេចចិត្តប្រកបដោយវិជ្ជាជីវៈដែលផ្អែកលើផ្តល់ការធានារ៉ាប់រងជាមួយនឹងការ គ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។ ការងារសំខាន់ៗរបស់លោកស្រី ធានាថាហានិភ័យត្រូវបានកំណត់ច្បាស់លាស់ តម្លៃ និងអាចគ្រប់គ្រងបាន ស្របតាមកម្រិតការទទួលយកហានិភ័យរបស់ក្រុមហ៊ុន ដើម្បីធានាបាននូវប្រាក់ចំណេញ និងនិរន្តរភាពអាជីវកម្មធានារ៉ាប់រងបន្ត។

លោកស្រី ពេជ្រ សុគន្ធារី

ប្រធានផ្នែកព័ត៌មានវិទ្យា

លោក ឡៃ លីម

លោក ឡៃ លីម ប្រធានផ្នែកព័ត៌មានវិទ្យា ជាមួយបទពិសោធន៍ជាង ៩ឆ្នាំ ក្នុងវិស័យព័ត៌មានវិទ្យានៅក្នុងវិស័យធានារ៉ាប់រង។ លោកមានជំនាញពិសេសក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធបណ្ដាញ ការពារសន្តិសុខសាយប័រ និងការអភិវឌ្ឍកម្មវិធីប្រព័ន្ធគ្រប់គ្រងអាជីវកម្មធានារ៉ាប់រងបន្ត។ លោកបានបង្ហាញពីសមត្ថភាពក្នុងការសហការរវាង អង្គភាពព័ត៌មានវិទ្យា និងនាយកដ្ឋានផ្សេងៗ ដើម្បីផ្ដល់ដំណោះស្រាយបច្ចេកវិទ្យាដែលសមស្របនឹងតម្រូវការអាជីវកម្ម។ លើសពីនេះទៀត លោក លីម ក៏មានជំនាញខ្ពស់ក្នុងការគ្រប់គ្រងថវិកា ការបែងចែកធនធាន និងការបង្កើតទំនាក់ទំនងល្អជាមួយអ្នកផ្គត់ផ្គង់ ដែលជួយពង្រឹងប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុន និងជំរុញការផ្លាស់ប្ដូរទៅជាឌីជីថល។

ប្រធានផ្នែកសវនកម្មផ្ទៃក្នុង

ក្នុងនាមជាអ្នកគ្រប់គ្រងផ្នែកសវនកម្មផ្ទៃក្នុង **លោក ចេង ភ័ក្ត្រវ័ន្ត** ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុចរិតភាព ភាពធន់ និងការត្រួតពិនិត្យជាយុទ្ធសាស្ត្រនៅក្នុងក្រុមហ៊ុន។ លោកដឹកនាំការវាយតម្លៃដោយឯករាជ្យលើការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងការអនុវត្តអភិបាលកិច្ច ដើម្បីធានាឱ្យមានការអនុលោមភាព និងលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ។ តាមរយៈការរួមបញ្ចូលគ្នានូវសវនកម្មដ៏ហ្មត់ចត់ ជាមួយនឹង ការដោះស្រាយបញ្ហាដោយកិច្ចសហការ លោកបានជំរុញឱ្យមានការកែលម្អជាបន្តបន្ទាប់តាមរយៈ អនុសាសន៍ជាក់ស្តែងដែលទទួលបានពីការងារសវនកម្មរបស់លោក និងពង្រឹងគណនេយ្យភាពនៅទូទាំងស្ថាប័ន។ អភិក្រមបុរេសកម្មរបស់លោកជួយកំណត់អត្តសញ្ញាណហានិភ័យដែលអាចកើតមានមុនពេលដែលវាវិវត្តទៅជាបញ្ហាធំ ខណៈដែលការប្តេជ្ញាចិត្តរបស់លោកចំពោះតម្លាភាពជួយកសាងទំនុកចិត្តយ៉ាងរឹងមាំក្នុងចំណោមភាគីពាក់ព័ន្ធ។

លោក ចេង ភ័ក្ត្រវ័ន្ត

៣.២. របាយការណ៍របស់គណៈកម្មការ

ដើម្បីពង្រឹងប្រសិទ្ធភាពអភិបាលកិច្ចសាជីវកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងការសម្រេចចិត្តប្រកបដោយតម្លាភាព ក្រុមប្រឹក្សាភិបាលបានប្រគល់សិទ្ធិ និងភារកិច្ចមួយចំនួនទៅឱ្យគណៈកម្មការជំនាញនានា។ ស្របតាមលក្ខន្តិកៈក្រុមហ៊ុន និងបទប្បញ្ញត្តិពាក់ព័ន្ធ គណៈកម្មការទាំងនេះមានតួនាទីចម្បងៗលើការសិក្សា ពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលលើបញ្ហាសំខាន់ៗ ទៅតាមការទទួលខុសត្រូវរៀងៗខ្លួន។

គិតត្រឹមឆ្នាំ២០២៥ ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មការអចិន្ត្រៃយ៍ចំនួនពីរ រួមមាន៖ **គណៈកម្មការសវនកម្ម និងគណៈកម្មការវិនិយោគ**។ គណៈកម្មការនីមួយៗបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម តាមរយៈការរៀបចំកិច្ចប្រជុំជាប្រចាំ ការពិនិត្យរបាយការណ៍ពាក់ព័ន្ធ និងការផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលសម្រាប់ការពិចារណា និងសម្រេចចិត្ត។ លទ្ធផលការងារ និងអនុសាសន៍សំខាន់ៗទាំងនេះ ត្រូវបានរាយការណ៍ជូនក្រុមប្រឹក្សាភិបាលជាប្រចាំ ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងការអនុវត្តការងារស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្ម គឺជាគណៈកម្មការអចិន្ត្រៃយ៍មួយរបស់ក្រុមប្រឹក្សាភិបាលនៃ**ក្រុមហ៊ុន កម្ពុជា រី** ដែលមានតួនាទីជួយគាំទ្រដល់ក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យ និងផ្តល់អនុសាសន៍លើសុចរិតភាពនៃរបាយការណ៍ហិរញ្ញវត្ថុ ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ ការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យ។

ក្នុងឆ្នាំ២០២៥ គណៈកម្មការសវនកម្មបានរៀបចំកិច្ចប្រជុំជាប្រចាំ ដើម្បីពិនិត្យ និងវាយតម្លៃរបាយការណ៍ហិរញ្ញវត្ថុ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត។ ការពិនិត្យនេះផ្តោតលើភាពត្រឹមត្រូវ ភាពពេញលេញ និងភាពជឿជាក់នៃព័ត៌មានហិរញ្ញវត្ថុ ព្រមទាំងការអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

គណៈកម្មការក៏បានត្រួតពិនិត្យលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន ដោយពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្នុង និងរបាយការណ៍សវនកម្មឯករាជ្យ ព្រមទាំងតាមដានការអនុវត្តផែនការកែលម្អរបស់ថ្នាក់គ្រប់គ្រង។

រាល់ការរកឃើញក្នុងឆ្នាំ២០២៥ ត្រូវបានវាយតម្លៃយ៉ាងហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ ដោយលទ្ធផលបង្ហាញថា ពុំមានផលប៉ះពាល់ជាដុំកំភួនដល់ប្រតិបត្តិការរបស់ក្រុមហ៊ុនឡើយ។ លើសពីនេះ គណៈគ្រប់គ្រងបានដោះស្រាយ និងអនុវត្តការកែលម្អជាបន្តបន្ទាប់ស្របតាមអនុសាសន៍ដែលបានផ្តល់ជូន។ ស្របពេលជាមួយគ្នានេះ គ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ បានប្តេជ្ញាចិត្តបញ្ចប់ផែនការសកម្មភាពកែតម្រូវឱ្យបានទាន់ពេលវេលាស្របតាមការព្រមព្រៀង។

បន្ថែមពីនេះ គណៈកម្មការសវនកម្មបានពិនិត្យលើការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយផ្ទៃក្នុងរបស់ក្រុមហ៊ុន ព្រមទាំងវាយតម្លៃលើភាពឯករាជ្យ និងប្រសិទ្ធភាពនៃសវនករឯករាជ្យ។ ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ គណៈកម្មការមានទស្សនៈថា ក្រុមហ៊ុនបានរក្សាបាននូវក្របខណ្ឌត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព សមស្របនឹងទំហំ និងលក្ខណៈប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

តាមរយៈការអនុវត្តតួនាទី និងភារកិច្ចប្រកបដោយប្រសិទ្ធភាព គណៈកម្មការសវនកម្មបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្ម ការលើកកម្ពស់តម្លាភាព និងគណនេយ្យភាព ព្រមទាំងការពារផលប្រយោជន៍របស់ភាគទុនិក និងភាគីពាក់ព័ន្ធទាំងអស់។ សកម្មភាពទាំងនេះបានជួយឱ្យ**ក្រុមហ៊ុន កម្ពុជា រី** បន្តរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ ភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុ និងការអនុលោមតាមក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

គណៈកម្មការវិនិយោគ

គណៈកម្មការវិនិយោគ គឺជាគណៈកម្មការអចិន្ត្រៃយ៍មួយរបស់ក្រុមប្រឹក្សាភិបាលនៃ**ក្រុមហ៊ុន កម្ពុជា រី** ដែលមានតួនាទីជាសេនាធិការ និងផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យ និងផ្តល់អនុសាសន៍ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យ វិនិយោគ ការបែងចែកទ្រព្យសកម្ម និងការគ្រប់គ្រងហានិភ័យវិនិយោគ។ គណៈកម្មការនេះធានាថាការវិនិយោគរបស់ក្រុមហ៊ុនត្រូវបានអនុវត្តប្រកបដោយភាពប្រុងប្រយ័ត្ន ស្របតាមគោលនយោបាយវិនិយោគ បទប្បញ្ញត្តិរបស់និយ័តករធានារ៉ាប់រងកម្ពុជា និងច្បាប់ពាក់ព័ន្ធជាធរមាន។

គណៈកម្មការវិនិយោគបានរៀបចំកិច្ចប្រជុំជាប្រចាំក្នុងអំឡុងឆ្នាំ២០២៥ ដើម្បីពិនិត្យ និងវាយតម្លៃលទ្ធផលនៃការវិនិយោគ ស្ថានភាពទីផ្សារហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ព្រមទាំងតាមដានការអនុលោមតាមគោលនយោបាយវិនិយោគ និងដែនកំណត់ហានិភ័យដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ អនុសាសន៍ និងសេចក្តីសម្រេចសំខាន់ៗរបស់គណៈកម្មការ ត្រូវបានរាយការណ៍ជូនក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងសម្រេច។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ **ក្រុមហ៊ុន កម្ពុជារី** មានសំពៀតវិនិយោគសរុបប្រមាណ ២៦,៧២ លានដុល្លារអាម៉េរិក ដែលភាគច្រើនត្រូវបានវិនិយោគក្នុងប្រាក់បញ្ញើមានកាលកំណត់ មូលបត្របំណុលរដ្ឋ និងទ្រព្យវិនិយោគដែលអនុញ្ញាតតាមបទប្បញ្ញត្តិជាធរមាន។ ក្នុងន័យនេះ គណៈកម្មការវិនិយោគបានផ្តោតការយកចិត្តទុកដាក់លើការរក្សាតុល្យភាពរវាងសុវត្ថិភាព សាច់ប្រាក់ងាយស្រួល និងផលត្រឡប់ពីការវិនិយោគ ដើម្បីធានាទ្រព្យវិនិយោគរបស់ក្រុមហ៊ុនអាចគាំទ្របានទាំងកាតព្វកិច្ចអាជីវកម្មនិងគោលដៅកំណើនរយៈពេលវែង។

ក្នុងឆ្នាំ២០២៥ គណៈកម្មការបានត្រួតពិនិត្យជាបន្តបន្ទាប់លើការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ដើម្បីធានាថាក្រុមហ៊ុនមានលទ្ធភាពបំពេញកាតព្វកិច្ចទូទាត់សំណងធានារ៉ាប់រង និងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះ គណៈកម្មការក៏បានពិនិត្យលើការផ្គូផ្គងរវាងទ្រព្យសកម្ម និងបំណុលបច្ចេកទេស ដើម្បីធានាថារចនាសម្ព័ន្ធទ្រព្យវិនិយោគមានសមស្របជាមួយនឹងកាតព្វកិច្ចរបស់ក្រុមហ៊ុន និងអាចទប់ទល់នឹងការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

បន្ថែមពីនេះ គណៈកម្មការបានត្រួតពិនិត្យជាប្រចាំលើភាពរឹងមាំនៃមូលធន និងកម្រិតសោធនភាពរបស់ក្រុមហ៊ុន ដើម្បីធានាថាក្រុមហ៊ុនបន្តរក្សាបាននូវស្ថានភាពហិរញ្ញវត្ថុដ៏រឹងមាំ និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ ការត្រួតពិនិត្យនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ការពារផលប្រយោជន៍របស់ភាគទុនិក និងពង្រឹងសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជា។

តាមរយៈការអនុវត្តតួនាទី និងភារកិច្ចប្រកបដោយប្រសិទ្ធភាព គណៈកម្មការវិនិយោគបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ និងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ការត្រួតពិនិត្យ និងអនុសាសន៍របស់គណៈកម្មការ បានជួយឱ្យ**ក្រុមហ៊ុន កម្ពុជា រី** បន្តរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ ភាពរឹងមាំនៃមូលធន និងកំណើនប្រកបដោយចីរភាព ស្របតាមចក្ខុវិស័យ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងរបស់ក្រុមហ៊ុន។

៣.៣. របាយការណ៍អំពីអភិបាលកិច្ចសាជីវកម្ម

ក្នុងអំឡុងឆ្នាំ២០២៥ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់**ក្រុមហ៊ុន កម្ពុជា រ៍** បានបន្តពង្រឹងការអនុវត្តអភិបាលកិច្ចសាជីវកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីគាំទ្រដល់ការរីកចម្រើនប្រកបដោយចីរភាព និងការបង្កើតតម្លៃរយៈពេលវែងសម្រាប់ភាគទុនិក អតិថិជន និងភាគីពាក់ព័ន្ធទាំងអស់។ ការអនុវត្តអភិបាលកិច្ចត្រូវបានផ្តោតលើការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ ការអនុលោមតាមបទប្បញ្ញត្តិ និងការធានាបាននូវការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវ និងវិជ្ជាជីវៈ។

បញ្ហាសំខាន់ៗទាក់ទងនឹងអភិបាលកិច្ចក្នុងអំឡុងឆ្នាំរួមមាន៖

- ការត្រួតពិនិត្យលើប្រតិបត្តិការ និងដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមទាំងបុព្វលាភធានារ៉ាប់រងដុលសរុប ចំនួន ២០,៩៦ លានដុល្លារអាម៉េរិក ទ្រព្យសកម្មសរុបចំនួន ៤៨,០៦ លានដុល្លារអាម៉េរិក និងមូលធនសរុបចំនួន ២៧,៧៧ លានដុល្លារអាម៉េរិក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។
- ការបន្តតាមដានលើសាធនភាពនិងភាពគ្រប់គ្រាន់នៃមូលធន ដោយអត្រាសាធនភាព ត្រូវបានរក្សានៅកម្រិត ៣៩៦ ភាគរយ ដែលជាកម្រិតមួយយ៉ាងល្អប្រសើរ និងខ្ពស់ជាងកម្រិតអប្បបរមាដែលតម្រូវដោយបទប្បញ្ញត្តិ។
- ការពិនិត្យវាយតម្លៃលើដំណើរការនៃការវាយតម្លៃហានិភ័យ និងនិន្នាការនៃការទាមទារសំណង រួមទាំងការកើនឡើងនៃសំណងទាមទារសុទ្ធដែលបានកើតឡើង ចំនួន ៩,៤៦ លានដុល្លារអាម៉េរិក និងការកើនឡើងនៃបំណុលកិច្ចសន្យាធានារ៉ាប់រងចំនួន ១៣,១៦ លានដុល្លារអាម៉េរិក។
- ការត្រួតពិនិត្យលើការគ្រប់គ្រងការវិនិយោគ សាច់ប្រាក់ងាយស្រួល និងការបែងចែកទ្រព្យសកម្ម រួមទាំងការគ្រប់គ្រងការវិនិយោគដែលមានទឹកប្រាក់ចំនួន ២៦,៧២ លានដុល្លារអាម៉េរិក និងសាច់ប្រាក់ព្រមទាំងសមមូលសាច់ប្រាក់ចំនួន ០,៤៨ លានដុល្លារអាម៉េរិកនៅចុងឆ្នាំ។
- ការបន្តគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈ កិច្ចសន្ទនាទីផ្សារ និងការចូលរួមពីភាគីពាក់ព័ន្ធ ដែលជាផ្នែកមួយនៃតួនាទីជាស្ថាប័នដ៏ទូលំទូលាយរបស់**ក្រុមហ៊ុន កម្ពុជារ៍** នៅក្នុងវិស័យធានារ៉ាប់រង។
- ក្រុមប្រឹក្សាភិបាលក៏បានរក្សាការត្រួតពិនិត្យផងដែរលើប្រធានបទយុទ្ធសាស្ត្រសំខាន់ៗដែលពាក់ព័ន្ធនឹងជំហររយៈពេលវែងរបស់ក្រុមហ៊ុន រួមមាន វិន័យក្នុងការវាយតម្លៃហានិភ័យ សម្ពាធនៃការទាមទារសំណងផ្នែកវេជ្ជសាស្ត្រនិងយានយន្តនៅក្នុងទីផ្សារដ៏ទូលំទូលាយ ចីរភាពនៃផលិតផល និងតម្រូវការក្នុងការរក្សាភាពបត់បែនផ្នែកហិរញ្ញវត្ថុនៅក្នុងបរិយាកាសហានិភ័យដែលតែងតែផ្លាស់ប្តូរ។

៤

ស្ថានភាពហិរញ្ញវត្ថុ និង ប្រតិបត្តិការអាជីវកម្ម

៤.១. ដើមទុន និងកម្រិតសោធនភាព

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ **ក្រុមហ៊ុន កម្ពុជា រី** មានមូលធនសរុបមានចំនួន ២៧,៧៧ លានដុល្លារ-អាម៉េរិក ហើយកម្រិតសាធនភាព ត្រូវបានរក្សានៅកម្រិត ៣៩៦ ភាគរយ ដែលជាកម្រិតមួយយ៉ាងល្អប្រសើរ និងខ្ពស់ជាងកម្រិតអប្បបរមាដែលតម្រូវដោយបទប្បញ្ញត្តិ។ កម្រិតសោធនភាពនេះបង្ហាញពីសមត្ថភាពហិរញ្ញ-វត្ថុដ៏រឹងមាំរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចចំពោះអតិថិជន និងភាគីពាក់ព័ន្ធ ព្រមទាំងគាំទ្រដល់ការរីកចម្រើនប្រកបដោយចីរភាពនៃអាជីវកម្ម។

ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនបានបន្តអនុលោមតាមតម្រូវការមូលធន និងសាធនភាពទាំងស្រុង ដោយរក្សាបាននូវមូលធនខ្ពស់ជាងកម្រិតអប្បបរមាដែលត្រូវបានកំណត់ចំនួន ៧ លានដុល្លារអាម៉េរិក (ប្រមាណ ២៨,០៨ ប៊ីលានរៀល)។ ស្ថានភាពនេះបង្ហាញពីគ្រឹះហិរញ្ញវត្ថុដ៏រឹងមាំ និងការគ្រប់គ្រងមូលធនប្រកបដោយប្រសិទ្ធភាព ដែលគាំទ្រដល់កំណើនអាជីវកម្ម និងនិរន្តរភាពរយៈពេលវែងរបស់ក្រុមហ៊ុន។

៤.២. ការវិនិយោគ

ក្រុមហ៊ុន កម្ពុជា រី បន្តអនុវត្តយុទ្ធសាស្ត្រវិនិយោគប្រកបដោយភាពប្រុងប្រយ័ត្ន ដោយផ្តោតលើការរក្សាសុវត្ថិភាពនៃទ្រព្យសកម្ម ភាពងាយស្រួលក្នុងការបម្លែងជាសាច់ប្រាក់ ការធ្វើពិពិធកម្ម និងការបង្កើតផលចំណេញប្រកបដោយចីរភាព ស្របតាមគោលនយោបាយវិនិយោគ និងដែនកំណត់ហានិភ័យដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ទ្រព្យវិនិយោគសរុបរបស់ក្រុមហ៊ុនមានចំនួន ២៦,៧២ លានដុល្លារ-អាម៉េរិក ខណៈដែលសាច់ប្រាក់ និងសមមូលសាច់ប្រាក់មានចំនួន ០,៤៨ លានដុល្លារអាម៉េរិក។ ប្រាក់បញ្ញើមានកាលកំណត់ នៅតែជាផ្នែកសំខាន់នៃសំពៀតវិនិយោគ ដោយមានទំហំសរុប ២៣,២៣ លានដុល្លារអាម៉េ-រិក ស្មើនឹងប្រមាណ ៨៧% នៃទ្រព្យវិនិយោគសរុប។

ដើម្បីកាត់បន្ថយហានិភ័យនៃការប្រមូលផ្តុំធនធាន និងពង្រឹងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ក្រុមហ៊ុនបានធ្វើពិពិធកម្មការវិនិយោគទៅក្នុងធនាគារដៃគូចំនួន ១១ និងរៀបចំរចនាសម្ព័ន្ធកាលកំណត់វិនិយោគចាប់ពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ ដោយផ្អែកលើតម្រូវការសាច់ប្រាក់ កាតព្វកិច្ចធានារ៉ាប់រង និងស្ថានភាពទីផ្សារហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ក្រុមហ៊ុនបានបន្តពង្រឹងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យវិនិយោគ ដោយធ្វើការត្រួតពិនិត្យ និងវាយ-តម្លៃជាប្រចាំលើហានិភ័យទីផ្សារ ហានិភ័យឥណទាន ហានិភ័យប្រមូលផ្តុំធនធាន និងហានិភ័យសាច់ប្រាក់ងាយស្រួល។ សំពៀតវិនិយោគទាំងមូលត្រូវបានគ្រប់គ្រងដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងស្របតាមគោលការណ៍សុវត្ថិភាព ភាពគ្រប់គ្រាន់នៃមូលធន និងការធានាសមត្ថភាពបំពេញកាតព្វកិច្ចធានារ៉ាប់រងរបស់ក្រុមហ៊ុនក្នុងរយៈពេលវែង។

៤.៣. ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង

ផ្អែកលើការវាយតម្លៃដោយអ្នកគណនាបុព្វលាភធានារ៉ាប់រង ប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រងរបស់ **ក្រុមហ៊ុន កម្ពុជា រី** ត្រូវបានកត់ត្រាស្ថិតនៅក្រោម **«បំណុលកិច្ចសន្យាធានារ៉ាប់រង»** ដើម្បីធានាឱ្យមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទូទាត់សំណង និងកាតព្វកិច្ចផ្សេងៗដែលកើតឡើងពីកិច្ច-សន្យាធានារ៉ាប់រងដែលរួមមាន៖ ប្រាក់បម្រុងសំណងធានារ៉ាប់រងដែលបានទទួលរបាយការណ៍ប៉ុន្តែមិនទាន់បានទូទាត់ (RBNS) ប្រាក់បម្រុងសំណងធានារ៉ាប់រងដែលបានកើតឡើងប៉ុន្តែមិនទាន់ទទួលរបាយការណ៍ (IBNR) ប្រាក់បម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល (UPR) ប្រាក់បម្រុងហានិភ័យមិនទាន់ផុតសុពលភាព (URR) និងប្រាក់បម្រុងគណិតវិទ្យា។

គិតត្រឹមឆ្នាំ២០២៥ បំណុលកិច្ចសន្យាធានារ៉ាប់រងសរុបរួមមានទំហំរហូតដល់ ១៣,១៦ លានដុល្លារ-អាមេរិក ដែលឆ្លុះបញ្ចាំងពីកំណើនគួរឱ្យកត់សម្គាល់ ធៀបនឹងចំនួន ១១,៥៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤។ ទន្ទឹមនឹងការកើនឡើងនៃទំហំបំណុលនេះ ទ្រព្យសកម្មធានារ៉ាប់រងបន្ត ដែលទាក់ទងនឹងកាតព្វកិច្ចទាំងនេះ ក៏បានកើនឡើងដល់ ២,៩៤ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៥ ផងដែរ បើធៀបទៅនឹងចំនួន ២,៤១ លានដុល្លារអាមេរិក កាលពីឆ្នាំ២០២៤ កន្លងទៅ។ កំណើនទន្ទឹមគ្នានៃសូចនាករទាំងពីរនេះបង្ហាញពីការពង្រីកទំហំប្រតិបត្តិការអាជីវកម្ម និងការគ្រប់គ្រងហានិភ័យប្រកបដោយភាពហ្មត់ចត់។

ជារួម ការកើនឡើងស្របគ្នានៃបំណុលកិច្ចសន្យាធានារ៉ាប់រង និងទ្រព្យសកម្មធានារ៉ាប់រងបន្ត បានឆ្លុះបញ្ចាំងពីកំណើនប្រតិបត្តិការអាជីវកម្មរបស់ **ក្រុមហ៊ុន កម្ពុជា រី** ព្រមទាំងបញ្ជាក់ពីការអនុវត្តនូវគោល-នយោបាយគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងប្រាក់បម្រុងបច្ចេកទេសប្រកបដោយភាពម៉ឺងម៉ាត់ សំដៅធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ និងសមត្ថភាពបំពេញកាតព្វកិច្ចរយៈពេលវែងជូនដល់ភាគីពាក់ព័ន្ធទាំងអស់។

៤.៤. លទ្ធផលអំពីប្រតិបត្តិការអាជីវកម្ម

ក្នុងឆ្នាំ២០២៥ បុព្វលាភធានារ៉ាប់រងដុលសរុបមានចំនួន ២០,៩៦ លានដុល្លារអាមេរិក ប្រាក់ចំណេញពីធានារ៉ាប់រង មានចំនួន ២,១៨ លានដុល្លារអាមេរិក សំណងសុទ្ធមានចំនួន ៩,៤៦ លានដុល្លារអាមេរិក និងប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំមានចំនួន ០,៨៨ លានដុល្លារអាមេរិក។

ក្នុងអំឡុងឆ្នាំនេះ សំណងទាមទារដុលដែលបានទូទាត់មានចំនួនសរុប ៨,៩៩ លានដុល្លារអាមេរិក ថយចុះពី ១១,០១ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤។ ទោះជាយ៉ាងណា សំណងសុទ្ធបានកើនឡើង ដោយសារការកើនឡើងនៃចំនួនករណីសំណង ដែលមានទំហំសំណងមធ្យមតិច ប៉ុន្តែកើតឡើងញឹកញាប់ ជាពិសេសលើអាជីវកម្មធានារ៉ាប់រងសុខភាព និងយានយន្ត ដែលបានដាក់សម្ពាធបន្ថែមលើលទ្ធផលធានារ៉ាប់រងរបស់ក្រុមហ៊ុន។ចំណាយប្រតិបត្តិការបានកើនឡើងដល់ ២,១០ លានដុល្លារអាមេរិក ពីចំនួន ២,០២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤ ខណៈដែលចំណាយកម្រៃជើងសារបានកើនឡើងដល់ ៦,១៥ លានដុល្លារអាមេរិក ពីចំនួន ៦,០០ លានដុល្លារអាមេរិក។ បម្រែបម្រួលទាំងនេះបានបណ្តាលឱ្យប្រាក់ចំណេញមានការធ្លាក់ចុះ ទោះបីជាមានកំណើនបុព្វលាភជាបន្តបន្ទាប់ក៏ដោយ។

៤.៥. ធានារ៉ាប់រងបន្ត

ស្របតាមយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ និងការការពារកាតព្វកិច្ចហិរញ្ញវត្ថុ ក្រុមហ៊ុនបានរៀបចំនិងអនុវត្តកម្មវិធីធានារ៉ាប់រងបន្តយ៉ាងម៉ត់ចត់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំហានិភ័យ ព្រមទាំងបង្កើនលទ្ធភាពក្នុងការទទួលធានារ៉ាប់រងបន្ថែម។ ក្នុងការជ្រើសរើស និងវាយតម្លៃដៃគូធានារ៉ាប់រងបន្ត ក្រុមហ៊ុនផ្តោតលើការវាយតម្លៃយ៉ាងតឹងរ៉ឹងលើកេរ្តិ៍ឈ្មោះ ស្ថិរភាពហិរញ្ញវត្ថុ និងចំណាត់ថ្នាក់ឥណទាន របស់ក្រុមហ៊ុនធានារ៉ាប់រងបន្តទាំងនោះ ដើម្បីធានាបាននូវការកាត់បន្ថយហានិភ័យឥណទានរបស់ភាគីកិច្ចសន្យា ប្រកបដោយប្រសិទ្ធភាព។ សម្រាប់ឆ្នាំរបាយការណ៍នេះក្រុមហ៊ុនពុំមានការផ្លាស់ប្តូរឬបម្រែបម្រួលធំដុំណាមួយដែលមានលក្ខណៈគួរឱ្យកត់សម្គាល់ នៅក្នុងរចនាសម្ព័ន្ធ ឬការរៀបចំកម្មវិធីធានារ៉ាប់រងបន្តនោះទេ ដោយរាល់ការបែងចែកភាគទាន និងទំហំនៃការរក្សាទុកហានិភ័យ គឺត្រូវបានរក្សាស្របតាមគោលការណ៍ណែនាំផ្ទៃក្នុងរបស់ក្រុមហ៊ុន។

៤.៦. ការគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុន កម្ពុជា រី អនុវត្តការគ្រប់គ្រងហានិភ័យទៅលើការវាយតម្លៃហានិភ័យ និងហានិភ័យធានារ៉ាប់រង ការប្រមូលផ្តុំហានិភ័យ ហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ។ ក្រុមហ៊ុនក៏បានតាមដានជាប្រចាំនូវទំនាក់ទំនងរវាងផលប័ត្រវិនិយោគ ទុនបម្រុងបច្ចេកទេស និងតម្រូវការមូលធន ដើម្បីធានាបាននូវភាពបត់បែនផ្នែកហិរញ្ញវត្ថុ និងរក្សាធនធានឱ្យបានគ្រប់គ្រាន់ សម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលនៃការទាមទារសំណង ការផ្លាស់ប្តូរលក្ខខណ្ឌទីផ្សារ និងការពង្រីកអាជីវកម្ម។

ក្នុងឆ្នាំ ២០២៥ **ក្រុមហ៊ុន កម្ពុជា រី** បានបន្តអនុវត្តក្របខ័ណ្ឌអនុលោមភាព និងការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងរឹងមាំ ដើម្បីធានាបាននូវការគោរពច្បាប់ និងបទប្បញ្ញត្តិ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រកបដោយតម្លាភាព អភិបាលកិច្ចហានិភ័យ និងគណនេយ្យភាពក្នុងប្រតិបត្តិការ។ ក្រុមហ៊ុនបានរក្សាភាពស្របគ្នាយ៉ាងពេញលេញជាមួយនឹងតម្រូវការបទប្បញ្ញត្តិ ព្រមទាំងពង្រឹងដំណើរការផ្ទៃក្នុងលើការវាយតម្លៃហានិភ័យធានារ៉ាប់រង ការពារមូលធន វិន័យវិនិយោគ និងការប្រព្រឹត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ។

ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការសំខាន់ៗដែលអាចប្រឈម រួមមានហានិភ័យលើការទទួលធានា និងកិច្ចសន្យា ការគ្រប់គ្រងសំណង ប្រព័ន្ធបច្ចេកវិទ្យា និងទិន្នន័យ ការប៉ាន់ប្រមាណប្រាក់បម្រុងបច្ចេកទេស និងហានិភ័យអនុលោមភាព។ ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនេះ ក្រុមហ៊ុនបានអនុវត្តវិធានការគ្រប់គ្រងជាច្រើន ដូចជា ការពិនិត្យផ្ទៀងផ្ទាត់លើការទទួលធានា ការកំណត់ដែនកំណត់ហានិភ័យ ការត្រួតពិនិត្យសំណងជាប្រចាំ ការពង្រឹងសុវត្ថិភាពប្រព័ន្ធព័ត៌មាន ការវាយតម្លៃប្រាក់បម្រុងដោយអ្នកគណនាបុព្វលាភធានារ៉ាប់រងឯករាជ្យ និងការតាមដានការអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធ។

ក្នុងការប្រតិបត្តិអាជីវកម្មធានារ៉ាប់រងបន្ត **ក្រុមហ៊ុន កម្ពុជា រី** បានបង្កើត និងអនុវត្តនូវគោលនយោបាយ នីតិវិធី និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងយ៉ាងច្បាស់លាស់ ដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យប្រតិបត្តិការដែលអាចកើតមាននៅគ្រប់ដំណាក់កាលនៃការប្រតិបត្តិអាជីវកម្ម។ ក្របខណ្ឌគ្រប់គ្រងហានិភ័យនេះត្រូវបានរៀបចំស្របតាមបទប្បញ្ញត្តិ ស្តង់ដារវិជ្ជាជីវៈ និងគោលការណ៍អភិបាលកិច្ចល្អ។

ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនបានអនុវត្តប្រតិបត្តិការអាជីវកម្មស្របតាមគោលនយោបាយ និងនីតិវិធីដែលបានកំណត់ ដោយមានការត្រួតពិនិត្យជាបន្តបន្ទាប់ពីថ្នាក់គ្រប់គ្រង គណៈកម្មាធិការពាក់ព័ន្ធ និងសវនកម្មផ្ទៃក្នុង។ ជាលទ្ធផល មិនមានព្រឹត្តិការណ៍ហានិភ័យប្រតិបត្តិការសំខាន់ណាមួយ ដែលបង្កឱ្យមានការខាតបង់ជាសារវន្ត ឬ ប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ក្រុមហ៊ុនឡើយ។

ជារួម **ក្រុមហ៊ុន កម្ពុជា រី** នៅតែរក្សាបាននូវប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និងភាពរឹងមាំ ដែលគាំទ្រដល់ការអនុវត្តអាជីវកម្មប្រកបដោយសុវត្ថិភាព តម្លាភាព និងចីរភាព ព្រមទាំងពង្រឹងទំនុកចិត្តរបស់ភាគីពាក់ព័ន្ធទាំងអស់ចំពោះស្ថិរភាព និងសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរយៈពេលវែង។

ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ផ្នែកហិរញ្ញវត្ថុដែលកើតឡើងនៅពេលដៃគូកិច្ចសន្យា ឬភាគីម្ខាងទៀតមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមកិច្ចព្រមព្រៀង។ សម្រាប់ **ក្រុមហ៊ុន កម្ពុជា រ៉េ** ហានិភ័យឥណទានចម្បងៗត្រូវបានគ្រប់គ្រង និងកាត់បន្ថយតាមរយៈវិធានការសំខាន់ៗដូចខាងក្រោម៖

- **ការធ្វើពិពិធកម្មប្រាក់បញ្ញើ៖** ដើម្បីជៀសវាងការប្រមូលផ្តុំហានិភ័យ និងធានាសុវត្ថិភាពសាច់ប្រាក់**ក្រុមហ៊ុន កម្ពុជា រ៉េ** បានបែងចែកប្រាក់បញ្ញើរបស់ខ្លួនទៅកាន់ធនាគារដៃគូចំនួន ១១ ផ្សេងគ្នា។ ការសម្រេច ចិត្តដាក់ប្រាក់បញ្ញើ និងការវិនិយោគលើសញ្ញាប័ណ្ណសាជីវកម្ម គឺធ្វើឡើងតែជាមួយគ្រឹះស្ថានហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ មានស្ថិរភាព និងមានចំណាត់ថ្នាក់ឥណទានល្អ ។ យុទ្ធសាស្ត្រនេះធានាថា ភាពរង្គោះរង្គើនៃស្ថាប័នហិរញ្ញវត្ថុណាមួយ មិនអាចជះឥទ្ធិពលធ្ងន់ធ្ងរដល់សាច់ប្រាក់សរុបរបស់ក្រុមហ៊ុននោះឡើយ។
- **ការគ្រប់គ្រងបុព្វលាភធានារ៉ាប់រងត្រូវប្រមូល៖** ក្រុមហ៊ុនមានយន្តការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងលើការប្រមូលប្រាក់បុព្វលាភពីក្រុមហ៊ុនធានារ៉ាប់រងដើម ដោយតាមដានអាយុកាលនៃបំណុលជាប្រចាំ និងអនុវត្តគោលនយោបាយទូទាត់ឱ្យបានទាន់ពេលវេលា ដើម្បីការពារការកើនឡើងនៃការខាតបង់។

ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែលក្រុមហ៊ុនមិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួនបានទាន់ពេលវេលា នៅពេលដែលកាតព្វកិច្ចនោះដល់កំណត់ ជាពិសេសគឺការទូទាត់សំណងធានារ៉ាប់រងបន្តភ្លាមៗដែលមិនបានរំពឹងទុក។

ដើម្បីគ្រប់គ្រងហានិភ័យនេះ **ក្រុមហ៊ុន កម្ពុជា រ៉េ** បានអនុវត្តយុទ្ធសាស្ត្រ និងយន្តការយ៉ាងម៉ឺងម៉ាត់និងមានភាពបត់បែនខ្ពស់ រាល់កិច្ចសន្យាប្រាក់បញ្ញើទាំងអស់របស់ក្រុមហ៊ុន សុទ្ធតែត្រូវបានរៀបចំឡើងដោយមានលក្ខខណ្ឌអនុញ្ញាតឱ្យដកប្រាក់មុនកាលកំណត់ ដែលជាយន្តការធានាដល់ការបំប្លែងជា សាច់ប្រាក់បានភ្លាមៗក្នុងករណីមានការទាមទារសំណងធំៗដោយមិនបានរំពឹងទុក។ សម្រាប់ទិសដៅទៅមុខ **ក្រុមហ៊ុន កម្ពុជា រ៉េ** នឹងបន្តត្រួតពិនិត្យស្ថានភាពសាច់ប្រាក់ជាប្រចាំ ដោយធានាថាទាំងអនុបាតសាច់ប្រាក់ងាយស្រួលសរុប និងអនុបាតបច្ចុប្បន្ន ត្រូវតែរក្សាឱ្យនៅលើសពី ១ ជានិច្ច ព្រមទាំងបន្តសហការជាមួយដៃគូហិរញ្ញវត្ថុ ដើម្បីរក្សានូវយន្តការដកប្រាក់ដ៏មានភាពបត់បែន នេះសម្រាប់ស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែងរបស់ក្រុមហ៊ុន។

ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យដែលតម្លៃសមរម្យ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុមានការប្រែប្រួលដោយសារការផ្លាស់ប្តូរនៃតម្លៃទីផ្សារ។ ហានិភ័យទីផ្សាររបស់ **ក្រុមហ៊ុន កម្ពុជា រ៉េ** រួមមានហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់។

ហានិភ័យទីផ្សាររបស់ **ក្រុមហ៊ុន កម្ពុជា រ៉េ** ត្រូវបានគ្រប់គ្រងយ៉ាងល្អ និងមានប្រសិទ្ធភាព តាមរយៈការវាយតម្លៃយ៉ាងម៉ត់ចត់លើហានិភ័យអត្រាការប្រាក់ និងហានិភ័យអត្រាប្តូរប្រាក់បរទេស ដើម្បីការពារផលប័ត្រវិនិយោគពីការប្រែប្រួលនៃតម្លៃទីផ្សារ។ នៅក្នុងបរិបទអត្រាការប្រាក់ទាប ក្រុមហ៊ុនមានយុទ្ធសាស្ត្របង្រួញកាលកំណត់នៃប្រាក់បញ្ញើ ដើម្បីរក្សាភាពបត់បែន និងត្រៀមខ្លួនចាប់យកឱកាសវិនិយោគឡើងវិញនៅពេលអត្រាការប្រាក់ងើបឡើង ព្រមទាំងបានបង្កើនការបែងចែកទុនទៅលើសញ្ញាប័ណ្ណ សាជីវកម្ម ដែលមានចំណាត់ថ្នាក់ឥណទានចាប់ពី B ឡើងទៅ ដើម្បីធានាប្រភពចំណូលមួយដ៏ស្ថិតស្ថេរ។ ដោយឡែក ហានិភ័យអត្រាប្តូរប្រាក់បរទេសត្រូវបានវាយតម្លៃថានៅមានកម្រិតទាប និងអាចគ្រប់គ្រងបានយ៉ាងល្អ ដោយសារប្រតិបត្តិការអាជីវកម្មភាគច្រើនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាម៉េរិក រួមផ្សំនឹងការប្រើប្រាស់យន្តការទូទាត់សុទ្ធ ជាមួយដៃគូធានារ៉ាប់រងបន្ត ដែលជួយកាត់បន្ថយការប្រឈមមុខផ្ទាល់ទៅនឹងការប្រែប្រួលរូបិយប័ណ្ណយ៉ាងមានប្រសិទ្ធភាព។

និតិវិធីនៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និងដៃគូពាក់ព័ន្ធ

ក្រុមហ៊ុនបានអនុវត្តនីតិវិធីវាយតម្លៃអតិថិជន និងនីតិវិធីស្គាល់អតិថិជន យ៉ាងតឹងរ៉ឹងចំពោះដៃគូ និងទំនាក់ទំនងអាជីវកម្ម។ ដំណើរការនេះរួមមានការពិនិត្យលើឯកសារចុះបញ្ជីសាជីវកម្ម ស្ថានភាពអាជ្ញាបណ្ណ និងព័ត៌មានអំពីភាពជាម្ចាស់ ដើម្បីធានាបាននូវការអនុលោមតាមគោលការណ៍គ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងជាប្រចាំ។

៤.៧. ព័ត៌មានស្តីពីចីរភាព

ក្រុមហ៊ុន កម្ពុជា រី ប្រកាន់ខ្ជាប់នូវគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាព ដោយផ្តោតលើសសរស្តម្ភសំខាន់ចំនួន៤ រួមមាន៖ **អភិបាលកិច្ចសាជីវកម្មល្អ ការអភិវឌ្ឍធនធានមនុស្ស និងការកសាងសមត្ថភាពវិជ្ជាជីវៈ ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម។** តាមរយៈការអនុវត្តយុទ្ធសាស្ត្រទាំងនេះ ក្រុមហ៊ុនមានគោលបំណងពង្រឹងភាពធន់ ភាពប្រកួតប្រជែង និងនិរន្តរភាពរយៈពេលវែងសម្រាប់វិស័យធានារ៉ាប់រងកម្ពុជា។

ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនបានបន្តដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រការអភិវឌ្ឍវិស័យធានារ៉ាប់រង តាមរយៈការរៀបចំ និងគាំទ្រសិក្ខាសាលា វេទិកាវិជ្ជាជីវៈ និងកម្មវិធីចែករំលែកចំណេះដឹងនានា សំដៅលើការលើកកម្ពស់សមត្ថភាពបច្ចេកទេស និងការយល់ដឹងអំពីនិន្នាការថ្មីៗក្នុងឧស្សាហកម្មធានារ៉ាប់រង។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនក៏បានបន្តបង្ហាញពីការប្តេជ្ញាចិត្តចំពោះសង្គមតាមរយៈសកម្មភាពគាំទ្រវិស័យអប់រំការអភិវឌ្ឍសហគមន៍ និងការលើកកម្ពស់សុខុមាលភាពសង្គម ស្របតាមតួនាទីជាស្ថាប័នហិរញ្ញវត្ថុដែលមានទំនួលខុសត្រូវ។

ធនធានមនុស្ស និងការកសាងសមត្ថភាព

ក្រុមហ៊ុន កម្ពុជា រី ចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាស្នូលនៃការរីកចម្រើនប្រកបដោយចីរភាព និងជាកត្តាសំខាន់ក្នុងការពង្រឹងភាពធន់របស់វិស័យធានារ៉ាប់រង។ ក្រុមហ៊ុនបន្តវិនិយោគលើការកសាងសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក និងអ្នកជំនាញក្នុងឧស្សាហកម្ម តាមរយៈកម្មវិធីបណ្តុះបណ្តាលសិក្ខាសាលាបច្ចេកទេស វេទិកាវិជ្ជាជីវៈ និងសកម្មភាពផ្លាស់ប្តូរចំណេះដឹងជាបន្តបន្ទាប់។

ក្នុងឆ្នាំ២០២៥ កន្លងទៅនេះ ក្រុមហ៊ុនបានដឹកនាំ និងចូលរួមក្នុងគំនិតផ្តួចផ្តើមសំខាន់ៗជាច្រើន ដែលគ្របដណ្តប់លើវិស័យបច្ចេកទេសឯកទេស ដូចជា៖

- **បច្ចេកទេសធានារ៉ាប់រង និងធានារ៉ាប់រងបន្ត៖** ការបណ្តុះបណ្តាលលើការវាយតម្លៃហានិភ័យកម្រិតខ្ពស់ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការរៀបចំរចនាសម្ព័ន្ធកិច្ចសន្យាធានារ៉ាប់រងបន្ត ដើម្បីពង្រឹងសមត្ថភាពរក្សាទុកហានិភ័យក្នុងស្រុក។
- **ការគ្រប់គ្រងហានិភ័យ និងការអនុលោមភាព៖** ការយល់ដឹងអំពីក្របខណ្ឌគ្រប់គ្រងហានិភ័យសាជីវកម្ម (និងការត្រៀមលក្ខណៈផ្ទៃកប្រព័ន្ធ គណនេយ្យ និងបច្ចេកទេស ស្របតាមការវិវត្តនៃបទប្បញ្ញត្តិថ្មីៗរបស់និយ័តករធានារ៉ាប់រងកម្ពុជា ។
- **ការគ្រប់គ្រងហិរញ្ញវត្ថុនិងស្តង់ដារអន្តរជាតិ៖**ការពង្រឹងសមត្ថភាពយល់ដឹងលើស្តង់ដាររបាយការណ៍ហិរញ្ញ-វត្ថុអន្តរជាតិ (IFRS/CIFRS) ដែលទាមទារនូវតម្លាភាពខ្ពស់ក្នុងការបង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់ ស្ថាប័ន។

ក្រុមហ៊ុនធានារ៉ាប់រងឡើងវិញកម្ពុជា "កម្ពុជា រី"
CAMBODIA RE

ការអភិវឌ្ឍវិជ្ជាជីវៈ

កម្មវិធី Associateship កម្រិត ១ របស់វិទ្យាស្ថានធានារ៉ាប់រងអាស៊ី (ហៅកាត់ថា AAii កម្រិត ១)

ក្នុងឆ្នាំ២០២៥ **ក្រុមហ៊ុន កម្ពុជា រី** បានបន្តគាំទ្រវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសប្រចាំឆ្នាំក្រោមកម្មវិធី Associateship កម្រិត ១ របស់វិទ្យាស្ថានធានារ៉ាប់រងអាស៊ី (ហៅកាត់ថា AAii កម្រិត ១) ដែលមានអ្នកចូលរួមក្នុងវគ្គនេះមានចំនួន ១២ នាក់ ។ វគ្គ AAii កម្រិត ១ នេះ នឹងផ្តល់ជូនអ្នកចូលរួមនូវចំណេះដឹងបច្ចេកទេស និងជំនាញជាក់ស្តែងនៅកម្រិតប្រតិបត្តិ ដែលនឹងផ្តល់ឱកាសឱ្យពួកគេអាចបង្កើនសមត្ថភាពឆ្ពោះទៅរកតួនាទីផ្នែកបច្ចេកទេស ផ្នែកត្រួតពិនិត្យ និងផ្នែកគ្រប់គ្រងនៅក្នុងវិស័យនេះ។



អ្នកចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ *AAii* កម្រិត ១ របស់**ក្រុមហ៊ុន កម្ពុជារី** ក្នុងឆ្នាំ២០២៥។

កម្មវិធី Professional Certificate in General Insurance Underwriting (PCGIU) របស់វិទ្យាស្ថានធានារ៉ាប់រងអាស៊ី (Aii)

អ្នកចូលរួមចំនួន ២៥ នាក់បន្ថែមទៀតបានទទួលអត្ថប្រយោជន៍ពីកម្មវិធី PCGIU ក្នុងឆ្នាំ២០២៥។ តាមរយៈការគាំទ្រឱ្យមានលទ្ធភាពទទួលបាននូវការសិក្សាជំនាញធានារ៉ាប់រង **ក្រុមហ៊ុន កម្ពុជា រី** បានបន្តចូលរួមចំណែក ដល់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យធានារ៉ាប់រងឱ្យកាន់តែរឹងមាំនិងមានសមត្ថភាពផ្នែកបច្ចេកទេសកាន់តែខ្ពស់។



អ្នកចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល *PCGIU* ដែលទទួលបានការគាំទ្រពី**ក្រុមហ៊ុន កម្ពុជារី** ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមក្នុងការកសាងសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន។

សិក្ខាសាលាស្តីពីមូលដ្ឋានគ្រឹះនៃការធានារ៉ាប់រងភារៈទទួលខុសត្រូវ

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៥ **ក្រុមហ៊ុន កម្ពុជា រី** បានសហការជាមួយក្រុមហ៊ុន Asia Reinsurance Brokers (ARB) រៀបចំសិក្ខាសាលាមួយស្តីពីមូលដ្ឋានគ្រឹះនៃការធានារ៉ាប់រងភារៈទទួលខុសត្រូវ ដែលមានអ្នកចូលរួមចំនួន ៥៩ នាក់។ វគ្គបណ្តុះបណ្តាលនេះបានជួយបង្កើនការយល់ដឹងអំពីហានិភ័យនៃភារៈទទួលខុសត្រូវ ការពិចារណាលើការវាយតម្លៃហានិភ័យធានារ៉ាប់រង និងការអនុវត្តលើការទាមទារសំណង ព្រមទាំងផ្តល់នូវទស្សនវិស័យស៊ីជម្រៅស្តីពីនិន្នាការ បញ្ហាប្រឈម និងឱកាសនៅក្នុងឧស្សាហកម្ម តាមរយៈការចូលរួមធ្វើបទបង្ហាញដោយលោក Roy Sharma នាយកគ្រប់គ្រងនៃក្រុមហ៊ុន ARB។

ក្រុមហ៊ុន កម្ពុជា រី និងក្រុមហ៊ុន Asia Reinsurance Brokers បានរៀបចំសិក្ខាសាលាស្តីពីមូលដ្ឋានគ្រឹះនៃការធានារ៉ាប់រងភារៈទទួលខុសត្រូវ
កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៥។

វេទិកាធានារ៉ាប់រង និងធានារ៉ាប់រងបន្តកម្ពុជា ឆ្នាំ ២០២៥

នៅថ្ងៃទី២៧-២៨ ខែមិថុនា ឆ្នាំ២០២៥ ក្រុមហ៊ុន កម្ពុជា រី និងក្រុមហ៊ុនជើងសារធានារ៉ាប់រងបន្ត AON បានសហការរៀបចំវេទិកាជួបជុំថ្នាក់ដឹកនាំធានារ៉ាប់រងនិងធានារ៉ាប់រងបន្តនៅកម្ពុជា ឆ្នាំ២០២៥ ក្រោមមូលបទ **"ការកសាងភាពធន់ក្នុងបរិបទទីផ្សារដែលមានការប្រែប្រួល និងភាពមិនប្រាកដប្រជា"** ។ ព្រឹត្តិការណ៍នេះមានការចូលរួមពីតំណាងចំនួន ៤៦ នាក់ រួមមានថ្នាក់ដឹកនាំក្នុងវិស័យធានា-រ៉ាប់រង និងអ្នកតាក់តែងគោលនយោបាយ ដើម្បីផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកជុំវិញការវិវឌ្ឍនៃម៉ាក្រូសេដ្ឋកិច្ចហានិភ័យដែលកំពុងលេចឡើងថ្មីៗ និងឱកាសនៅក្នុងវិស័យធានារ៉ាប់រង និងធានារ៉ាប់រងបន្ត ស្របពេលជាមួយគ្នានេះក៏បានជួយពង្រឹងកិច្ចសហការឱ្យកាន់តែរឹងមាំនៅទូទាំងទីផ្សារផងដែរ។

ថ្នាក់ដឹកនាំក្នុងវិស័យធានារ៉ាប់រង និងអ្នកតាក់តែងគោលនយោបាយជួបជុំគ្នានៅក្នុងកម្មវិធី វេទិកាធានារ៉ាប់រង និងធានារ៉ាប់រងបន្តកម្ពុជា ឆ្នាំ ២០២៥ ដែលសហការរៀបចំដោយ **ក្រុមហ៊ុន កម្ពុជា រី** និងក្រុមហ៊ុន Aon។

ពិធីលៀងសាយភោជនដើម្បីចែករំលែកអំពី " ទីផ្សារធានារ៉ាប់រងអាយុជីវិតក្នុងតំបន់អាស៊ីទាក់ទងនឹងនិន្នាការនៃជំងឺធ្ងន់ធ្ងរ "

ក្រៅពីសកម្មភាពខាងលើ **ក្រុមហ៊ុន កម្ពុជា រី** បានរៀបចំពិធីលៀងសាយភោជនដើម្បីចែករំលែកអំពី **" ទីផ្សារធានារ៉ាប់រងអាយុជីវិតក្នុងតំបន់អាស៊ីទាក់ទងនឹងនិន្នាការនៃជំងឺធ្ងន់ធ្ងរ "** ដោយមានអ្នកចូលរួមចំនួន ៤៥ នាក់។ ព្រឹត្តិការណ៍នេះបានប្រមូលផ្តុំអ្នកជំនាញក្នុងតំបន់ និងថ្នាក់ដឹកនាំវិស័យធានារ៉ាប់រង ដើម្បីពិភាក្សាអំពីនិន្នាការថ្មីៗ ការអភិវឌ្ឍផលិតផល និងការគ្រប់គ្រងហានិភ័យក្នុងវិស័យធានារ៉ាប់រងអាយុជីវិត។ សកម្មភាពនេះមិនត្រឹមតែជួយពង្រឹងចំណេះដឹងផ្នែកបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែជាការបង្កើតទំនាក់ទំនងថ្មីៗយ៉ាងរឹងមាំនិងមានអត្ថន័យរវាងអ្នកពាក់ព័ន្ធទាំងអស់ទាំងក្នុងស្រុកនិងតំបន់ដែលអាចនាំទៅដល់ការបង្កើតឱ្យមានកិច្ចសហការនិងកាលានុវត្តភាពរួមគ្នានៅក្នុងវិស័យធានារ៉ាប់រងនៅកម្ពុជា។

អ្នកជំនាញក្នុងតំបន់ និងថ្នាក់ដឹកនាំក្នុងវិស័យធានារ៉ាប់រងអាយុជីវិតចូលរួមក្នុង
ពិធីលៀងសាយភោជនដើម្បីចែករំលែកអំពី
" ទីផ្សារធានារ៉ាប់រងអាយុជីវិតក្នុងតំបន់អាស៊ីទាក់ទងនឹងនិន្នាការនៃជំងឺធ្ងន់ធ្ងរ "

ជារួម គំនិតផ្តួចផ្តើមទាំងនេះបានឆ្លុះបញ្ចាំងពីតួនាទីយ៉ាងសកម្មរបស់ **ក្រុមហ៊ុន កម្ពុជា រី** ទាំងក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្ត និងជាដៃគូយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទីផ្សារ។ តាមរយៈការវិនិយោគលើការកសាងសមត្ថភាពវិជ្ជាជីវៈ ក្រុមហ៊ុនបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ស្តង់ដារបច្ចេកទេស ការពង្រឹងសមត្ថភាពវាយតម្លៃហានិភ័យ និងការជំរុញឱ្យឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជាកាន់តែមានភាពរឹងមាំ និងប្រកបដោយវិជ្ជាជីវៈខ្ពស់។

ចីរភាព និងការចូលរួមចំណែកក្នុងសង្គម

ក្រុមហ៊ុន កម្ពុជា រី ប្តេជ្ញាបង្កើតតម្លៃប្រកបដោយចីរភាពរយៈពេលវែង មិនត្រឹមតែសម្រាប់ម្ចាស់ភាគហ៊ុន និងអតិថិជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់សហគមន៍ទាំងមូលផងដែរ។ យុទ្ធសាស្ត្រចីរភាពរបស់ក្រុមហ៊ុនគឺផ្អែកលើទស្សនវិស័យដែលថា ការទទួលខុសត្រូវរបស់សាជីវកម្ម គឺជាចំណែកមិនអាចកាត់ផ្តាច់បានពីការអភិវឌ្ឍវិស័យធានារ៉ាប់រងមួយឱ្យមានភាពធន់ គួរឱ្យទុកចិត្ត និងប្រកបដោយបរិយាបន្ន។

ក្រៅពីការពង្រឹងសមត្ថភាពទីផ្សារតាមរយៈសកម្មភាពអាជីវកម្មស្នូល **ក្រុមហ៊ុន កម្ពុជា រី** បានបន្តចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសហគមន៍ តាមរយៈការគាំទ្រដល់គំនិតផ្តួចផ្តើមសំខាន់ៗលើវិស័យអប់រំ និងសុខុមាលភាពសង្គម។ សកម្មភាពទាំងនេះមិនត្រឹមតែបង្ហាញពីការប្តេជ្ញាចិត្តចំពោះសង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងពីតម្លៃស្នូលរបស់ក្រុមហ៊ុន ក្នុងការកសាងអនាគតដ៏ប្រសើរជូនប្រទេសជាតិ។

សកម្មភាពទទួលខុសត្រូវខាងសង្គម

ក្រុមហ៊ុន កម្ពុជា រី ប្ដេជ្ញាផ្ដល់ការគាំទ្រសប្បុរសធម៌ជូនដល់សហគមន៍ដែលមានតម្រូវការតាមរយៈការអនុវត្តសកម្មភាពទទួលខុសត្រូវខាងសង្គម។

ការគាំទ្រដល់ការអប់រំនៅសាលាបឋមសិក្សា បឹងទឹម

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៥ ក្នុងខេត្តបាត់ដំបង**ក្រុមហ៊ុន កម្ពុជា រី** បានរៀបចំសកម្មភាពទំនួលខុសត្រូវសង្គម នៅសាលាបឋមសិក្សាបឹងទឹម ក្រោមប្រធានបទ **«រួមគ្នាដើម្បីការអប់រំដ៏រឹងមាំ និងសហគមន៍បៃតង»**។ គំនិតផ្តួចផ្តើមនេះបានជួយគាំទ្រដល់សិស្សានុសិស្សចំនួន ៣០៥ នាក់ ដោយផ្តល់ជូននូវសម្ភារសិក្សា មានដូចជា សៀវភៅចំនួន ២០០ក្បាលដល់បណ្ណាល័យ និងផ្តល់ជូននូវឧបករណ៍ចាំបាច់នានាដើម្បីលើកកម្ពស់សមត្ថភាពបង្រៀន និងកិច្ចការរដ្ឋបាល។ តាមរយៈសកម្មភាពនេះ **ក្រុមហ៊ុន កម្ពុជា រី** បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការអប់រំ ក្នុងនាមជាគ្រឹះសម្រាប់ការអភិវឌ្ឍសង្គម និងភាពធន់របស់សហគមន៍ក្នុងរយៈពេលវែង។

ក្រុមការងាររបស់ **ក្រុមហ៊ុន កម្ពុជា រី** រួមទាំង **លោក ហ៊ុយ វ៉ាថារ៉ូ** អគ្គនាយក បានជួបសំណេះសំណាលជាមួយសិស្សានុសិស្សនៅសាលាបឋមសិក្សាបឹងទឹម ដោយលើកទឹកចិត្តឱ្យមានការស្រឡាញ់ការសិក្សា ព្រមទាំងបានផ្តល់ជូននូវសម្ភារសិក្សា និងការគាំទ្រចាំបាច់នានា។

សិស្សានុសិស្សនៅសាលាបឋមសិក្សា បឹងទឹម បង្ហាញស្នាមញញឹម និងសំណើចយ៉ាងរីករាយ ក្នុងអំឡុងពេលសកម្មភាពចុះជួយសហគមន៍ផ្នែកអប់រំរបស់ **ក្រុមហ៊ុន កម្ពុជារី**។

កម្មវិធីចែករំលែកអំណោយសប្បុរសធម៌ក្នុងខេត្តកំពង់ធំ

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ **ក្រុមហ៊ុន កម្ពុជា រី** បានរៀបចំកម្មវិធីចែករំលែកអំណោយសប្បុរសធម៌ជូនដល់គ្រួសារដែលមានជីវភាពខ្វះខាតចំនួន ៤០០ គ្រួសារ នៅសាលាស្រុកសន្ទុក ខេត្តកំពង់ធំ។ គំនិតផ្តួចផ្តើមនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនក្នុងការផ្តល់ការគាំទ្រដល់សហគមន៍ដែលងាយរងគ្រោះ និងបង្ហាញពីជំនឿរបស់ក្រុមហ៊ុនថា ភាពជោគជ័យនៃអាជីវកម្មប្រកបដោយចីរភាព ត្រូវតែអមមកជាមួយនូវការចូលរួមចំណែកក្នុងសង្គមដ៏មានអត្ថន័យ។

តំណាងក្រុមហ៊ុន កម្ពុជា រី ចូលរួមក្នុងកម្មវិធីចែករំលែកអំណោយសប្បុរសធម៌ជូនដល់គ្រួសារដែលមានជីវភាពខ្វះខាតនៅក្នុងខេត្តកំពង់ធំ។

គំនិតផ្តួចផ្តើមទាំងនេះគឺជាការបន្តនូវប្រពៃណីដ៏យូរលង់របស់ **ក្រុមហ៊ុន កម្ពុជា រី** ក្នុងការធ្វើជាពលរដ្ឋល្អក្នុងសង្គម ដែលក្នុងឆ្នាំកន្លងទៅ ក្រុមហ៊ុនបានគាំទ្រដល់សកម្មភាពសប្បុរសធម៌នានាដែលពាក់ព័ន្ធនឹងវិស័យអប់រំ និងសុខាភិបាល។ ក្នុងឆ្នាំ២០២៥ ក្រុមហ៊ុនបានបន្តការប្តេជ្ញាចិត្តនេះ ដោយផ្តោតលើការគាំទ្រជាក់ស្តែងដល់សហគមន៍ ដែលអាចបង្កើតឱ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ និងយូរអង្វែង។

របាយការណ៍អភិបាលកិច្ចសាជីវកម្ម

ក្រុមហ៊ុន កម្ពុជា រី ជឿជាក់ថា អភិបាលកិច្ចសាជីវកម្មដ៏ល្អ គឺជាមូលដ្ឋានគ្រឹះនៃភាពធន់របស់ ស្ថាប័ន ការបង្កើតទំនុកចិត្តដល់ភាគីពាក់ព័ន្ធ និងការបង្កើនតម្លៃរយៈពេលវែង។ ក្របខ័ណ្ឌអភិបាលកិច្ចរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងយ៉ាងហ្មត់ចត់ ដើម្បីធានាបាននូវការសម្រេចចិត្តប្រកបដោយភាពប្រុងប្រយ័ត្ន ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងហានិភ័យប្រកបដោយការទទួលខុសត្រូវ ស្របតាមតួនាទីរបស់ **ក្រុមហ៊ុន កម្ពុជា រី** ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តតែមួយគត់នៅកម្ពុជា។

ក្រុមប្រឹក្សាភិបាលដើរតួនាទីជាស្នូលក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងត្រួតពិនិត្យការអនុវត្តការងាររបស់ថ្នាក់ដឹកនាំប្រតិបត្តិ។ ជាមួយនឹងបទពិសោធន៍ដ៏សម្បូរបែបទាំងក្នុងវិស័យសាធារណៈ និងឯកជន ក្រុម-ប្រឹក្សាភិបាលបានផ្តល់នូវការដឹកនាំប្រកបដោយតុល្យភាព ទាំងលើការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍ ទីផ្សារ និងយុទ្ធសាស្ត្រស្ថាប័ន។ រចនាសម្ព័ន្ធនេះបានគាំទ្រយ៉ាងពេញលេញដល់តួនាទីទ្វេដងរបស់ **ក្រុមហ៊ុន កម្ពុជា រី** ទាំងក្នុងនាមជាអង្គភាពអាជីវកម្មដែលមានវិន័យខ្ពស់ និងជាស្ថាប័នអភិវឌ្ឍទីផ្សារដែលមានបេសកកម្មបម្រើផលប្រយោជន៍សាធារណៈ។

ក្នុងឆ្នាំ ២០២៥ **ក្រុមហ៊ុន កម្ពុជា រី** បានបន្តពង្រឹងការគ្រប់គ្រងផ្ទៃក្នុង ការអនុលោមតាមច្បាប់ និងដំណើរការអភិបាលកិច្ចហានិភ័យ។ ក្រុមហ៊ុនបានតម្រឹមប្រតិបត្តិការរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនតាមតម្រូវការបទប្បញ្ញត្តិជាធរមាន ដោយផ្តោតសំខាន់លើវិន័យនៃការវាយតម្លៃហានិភ័យធានារ៉ាប់រង ភាពគ្រប់គ្រាន់នៃមូលធន និងការទទួលខុសត្រូវក្នុងប្រតិបត្តិការ។

យុទ្ធសាស្ត្រអភិបាលកិច្ចរបស់យើងត្រូវបានពង្រឹងដោយវប្បធម៌នៃវិជ្ជាជីវៈ សុចរិតភាព និងកិច្ចសហការ។ តាមរយៈរចនាសម្ព័ន្ធត្រួតពិនិត្យច្បាស់លាស់ ការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងការសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័ននិយតករ **ក្រុមហ៊ុន កម្ពុជា រី** នៅតែបន្តលើកកម្ពស់ស្តង់ដារអាជីវកម្មប្រកបដោយការទទួលខុសត្រូវ និងការអភិវឌ្ឍស្ថាប័នប្រកបដោយចីរភាព។

៥

របាយការណ៍របស់ ក្រុមប្រឹក្សាភិបាល

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់បង្ហាញជូនរបាយការណ៍នេះ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់**ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រ៉ី"** ហៅកាត់ថា **("ក្រុមហ៊ុន")** និង**ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ជារួមហៅកាត់ថា "ក្រុមហ៊ុនរួម")** និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក របស់ក្រុមហ៊ុន **(ជារួមហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក")** ដែលត្រូវបានធ្វើសវនកម្មរួចនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

សកម្មភាពអាជីវកម្មចម្បង

ក្រុមហ៊ុនមេ៖ សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការលើការធានារ៉ាប់រងបន្តលើហានិភ័យធានារ៉ាប់រងមិនមែនអាយុជីវិត និងធានារ៉ាប់រងអាយុជីវិត។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ៖ សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺផ្តល់សេវាលើការគ្រប់គ្រងសំណងធានារ៉ាប់រង។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសង្ខេប នៃប្រតិបត្តិការរបស់ក្រុមហ៊ុនរួម និង ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដូចខាងក្រោម៖

	២០២៥		*២០២៤*	
	ដុល្លារអាម៉េរិក	*ពាន់រៀល*	*ដុល្លារអាម៉េរិក*	*ពាន់រៀល*
ក្រុមហ៊ុនរួម				
ចំណេញមុនគិតពន្ធលើប្រាក់ចំណូល	១.៤៥០.៦៧២	៥.៨១៨.៦៤៥	១.៩៨៨.៦៩៦	៨.០៩៥.៩៨២
ចំណាយពន្ធលើប្រាក់ចំណូល	(៩២៦.៣៩២)	(៣.៧១៥.៧៥៨)	(៨៦៨.៩៥៤)	(៣.៥៣៧.៥១២)
ចំណេញសុទ្ធក្នុងឆ្នាំ	**៥២៤.២៨០**	**២.១០២.៨៨៧**	**១.១១៩.៧៤២**	**៤.៥៥៨.៤៧០**

	២០២៥		*២០២៤*	
	ដុល្លារអាម៉េរិក	*ពាន់រៀល*	*ដុល្លារអាម៉េរិក*	*ពាន់រៀល*
ក្រុមហ៊ុន				
ចំណេញមុនគិតពន្ធលើប្រាក់ចំណូល	១.៨០៧.៧៣៥	៧.២៥០.៨២៤	២.២៤១.១៨៣	៩.១២៣.៨៥៦
ចំណាយពន្ធលើប្រាក់ចំណូល	(៩២៤.៨៣៧)	(៣.៧០៩.៥២១)	(៨៦៨.៩៥៤)	(៣.៥៣៧.៥១២)
ចំណេញសុទ្ធក្នុងឆ្នាំ	**៨៨២.៨៩៨**	**៣.៥៤១.៣០៣**	**១.៣៧២.២២៩**	**៥.៥៨៦.៣៤៤**

ភាគលាភ

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ ភាគទុនិករបស់ក្រុមហ៊ុន បានអនុម័តចំពោះការបែងចែកភាគលាភ ពីប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ចំនួន ០,៨៤ លានដុល្លារអាម៉េរិក (ស្មើនឹង ១,៥ ដុល្លារអាម៉េរិក ក្នុងមួយភាគហ៊ុន)។ ការបែងចែកភាគលាភត្រូវបានអនុម័តដោយនិយ័តករធានារ៉ាប់រងកម្ពុជា នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥ និងបានទូទាត់រួចរាល់នៅ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។
នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦ ក្រុមប្រឹក្សាភិបាលបានស្នើសុំបែងចែកភាគលាភចំនួន ០,៥៤ លានដុល្លារអាម៉េរិក (ស្មើនឹង ០,៩៧ ដុល្លារអាម៉េរិក ក្នុងមួយភាគហ៊ុន) ពីប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ ការស្នើសុំបែងចែកភាគលាភនេះ ត្រូវបានអនុម័តក្នុងកិច្ចប្រជុំភាគទុនិកនាកាលបរិច្ឆេទដដែលនោះ ដែលការបែងចែកភាគលាភនេះ នឹងត្រូវសុំការអនុម័តពីនិយ័តករធានារ៉ាប់រងកម្ពុជា។

ដើមទុន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដើមទុនរបស់ក្រុមហ៊ុន មានចំនួន ១៤.០០០.០០០ ដុល្លារអាម៉េរិក (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤៖ ១៤.០០០.០០០ ដុល្លារអាម៉េរិក)។

ទុនបម្រុង និងសំវិធានធន

ក្រៅពីការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ពុំមានការប្រែប្រួលជាសារវន្តរវាងទុនបម្រុង និងសំវិធានធន នៅក្នុងអំឡុងការិយបរិច្ឆេទទេ។

ទ្រព្យសកម្ម

មុនពេលរបាយការណ៍ហិរញ្ញវត្ថុវត្ថុរួម និងដាច់ដោយឡែក របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមហេតុផលដើម្បីធានាថា ទ្រព្យសកម្មណាមួយដែលទំនងជាមិនអាចប្រមូលបានមកវិញក្នុងដំណើរការអាជីវកម្មធម្មតា តាមតម្លៃដូចដែលបានបង្ហាញនៅក្នុងកំណត់ត្រាគណនេយ្យ របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ត្រូវបាន កត់ត្រានៅស្មើនឹងចំនួនដែលរំពឹងថានឹងទទួលបាន។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងអំពីករណីណាមួយដែលនឹងធ្វើឱ្យតម្លៃដែលត្រូវបានដាក់បញ្ចូលជាទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

វិធីសាស្ត្រវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឱ្យប៉ះពាល់ដល់វិធីសាស្ត្រកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

ការប្រែប្រួលកាលៈទេសៈ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ដែលនឹងបណ្តាលឱ្យចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។
តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលដំណាច់ឆ្នាំនេះ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

បំណុលយថាភាព ឬបំណុលផ្សេងទៀត

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងទៀត ដែលត្រូវទូទាត់សងក្នុងរយៈពេលដប់ពីរខែបន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ ក្រុមហ៊ុនរួម និងក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចទូទាត់ នៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ ក្រៅពីអ្វីដែលបានបង្ហាញ នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកនេះ។
នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖
(ក) ពុំមានការដាក់បញ្ចាំ (បន្ទុក) ទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន កើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកសម្រាប់ការធានាចំពោះ បំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ
(ខ) ពុំមានបំណុលយថាភាពណាមួយដែលកើតមានឡើង ឬអាចនឹងកើតមានឡើងចំពោះក្រុមហ៊ុនរួម និងក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ នោះឡើយ។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ដែលបានបំពេញតួនាទីនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

	ឯកឧត្តម រស់ សីលវ៉ា	ប្រធានក្រុមប្រឹក្សាភិបាល
	លោកជំទាវ នួន សុណេតា	សមាជិកាក្រុមប្រឹក្សាភិបាល
	ឯកឧត្តម ប៉ែន ពេជ្រសាលី	សមាជិកក្រុមប្រឹក្សាភិបាល (លាលែងពីតំណែងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៥)
	ឯកឧត្តម សាង តូនិច	សមាជិកក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៥)

	លោក Teddy Hailamsah	សមាជិកក្រុមប្រឹក្សាភិបាល
	លោក យក់ ចំរើនឫទ្ធិ	សមាជិកក្រុមប្រឹក្សាភិបាល (លាលែងពីតំណែងនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥)
	លោកស្រី ហង្ស ចន្ទូ	សមាជិកាក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥)
	លោក ហ៊ុយ វ៉ាថារ៉ូ	សមាជិកក្រុមប្រឹក្សាភិបាល
	លោក រ័ត្ន វាសនា	សមាជិកក្រុមប្រឹក្សាភិបាល

គណៈគ្រប់គ្រង ដែលបានបំពេញតួនាទីនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

លោក ហ៊ុយ វ៉ាថារ៉ូ
អគ្គនាយក

លោក ទី អាទិត្យ
នាយកប្រតិបត្តិការ

លោក រ័ត្ន វាសនា
នាយកហិរញ្ញវត្ថុ

ភាគកម្មរបស់អភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនរួម និង ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល នៅក្នុងការិយបរិច្ឆេទនេះទេ។

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ បានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុនឱ្យទទួលបាននូវ អត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃទៀតទេ។

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដោយ ឬក៏ត្រូវទូទាត់ទៅក្រុមប្រឹក្សាភិបាល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនរួម និងក្រុមហ៊ុន ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះ ឬដែលអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការធានាថា របាយការណ៍ហិរញ្ញរួម និងដាច់ដោយឡែកផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និង ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ជាមួយការពន្យារពេលលើការអនុវត្តនៃស្តង់ដាគណនេយ្យអន្តរជាតិ ១៧ កិច្ចសន្យាធានារ៉ាប់រង និង ៩ ឧបករណ៍ហិរញ្ញវត្ថុ ("CIFRSs ជាមួយការពន្យារលើ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ និង ៩) ស្របតាមការអនុម័តរបស់និយ័តករគណនេយ្យ និងសវនកម្ម ដែលអនុញ្ញាតសម្រាប់ការពន្យារលើការអនុវត្ត (សូមមើលកំណត់សម្គាល់លេខ ២.២)។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យដោយអនុលោមទៅតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជា ជាមួយនឹងការពន្យារពេលលើ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ និង ៩ ដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ii) អនុលោមតាមលក្ខខណ្ឌតម្រូវរបស់ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ជាមួយនឹងការពន្យារពេលលើ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ និង ៩ និងស្របតាមច្បាប់ ហើយប្រសិនបើមានការបង្ហាញប្រាសចាកណាមួយដើម្បីផលប្រយោជន៍នៃបទបង្ហាញដោយយុត្តិធម៌ ត្រូវប្រាកដថាវាត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ ពន្យល់និងបរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសមាស និងដាច់ដោយឡែក។

(iii) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកតាមមូលដ្ឋាននិរន្តរភាពអាជីវកម្ម លើកលែងតែមិនមានលក្ខណៈសមស្រប ក្នុងការសន្មតថាក្រុមហ៊ុនរួម និងក្រុមហ៊ុន នឹងបន្តប្រតិបត្តិការអាជីវកម្មក្នុងពេលអនាគតដែលអាចប៉ាន់ស្មានបាននិង

(v) គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនរួម និងក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពខ្ពស់ និងចូលរួមរាល់ការសម្រេចចិត្តលើបញ្ហាសំខាន់ៗ ដែលមានផលប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុ និងធានាថាផលប៉ះពាល់ទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក។

(vi) ធានាថាមានវិធានការសមស្របចំពោះការជម្រះចេញពីបញ្ជីនូវបំណុលអាក្រក់ និងការធ្វើសំវិធានធនសម្រាប់បំណុលសង្ស័យ ព្រមទាំងប្រាកដថារាល់បំណុលអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានធ្វើសំវិធានធនគ្រប់គ្រាន់សម្រាប់បំណុលសង្ស័យ។
(vii) ធានាថាទ្រព្យសកម្មរយៈពេលខ្លី ក្រៅពីបំណុល ដែលទំនងជាមិនអាចទទួលបានពីសកម្មភាពអាជីវកម្មធម្មតាតាមតម្លៃដូចបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយតម្លៃឱ្យនៅស្មើនឹងតម្លៃដែលរំពឹងថានឹងអាចប្រមូលបាន។
(viii) វាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលពាក់ព័ន្ធទៅលើការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានគម្រោងបិទអាជីវកម្មរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនរួម និងក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

យើងខ្ញុំ សូមបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ដែលមានភ្ជាប់មកជាមួយទាំងនេះផ្តល់នូវទិដ្ឋភាពពិត និង ត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និង ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាម ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ជាមួយការពន្យា ពេលលើការអនុវត្តនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ១៧ ស្របតាមការអនុម័តរបស់និយ័តករគណនេយ្យ និងសវនកម្ម ដែលអនុញ្ញាតសម្រាប់ការពន្យារលើការអនុវត្ត។

បានចុះហត្ថលេខាដោយអនុលោមទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងក្នុងនាមក្រុមហ៊ុនរួម និងក្រុមហ៊ុន៖

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦

ចុះហត្ថលេខាតំណាងដោយក្រុមប្រឹក្សាភិបាលរបស់ ក្រុមហ៊ុនរួម និងក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"

ប្រធានក្រុមប្រឹក្សាភិបាល	**អគ្គនាយក**
រស់ សីលវ៉ា	ហ៊ុយ វ៉ាថារ៉ូ

យើងខ្ញុំ តំណាងឱ្យក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ធានារ៉ាប់រងបន្តកម្ពុជា “កម្ពុជា រី” ហៅកាត់ថា (“ក្រុមហ៊ុន”) និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ជារួមហៅកាត់ថា “ក្រុមហ៊ុនរួម”) សូមបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែករបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ នៃស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”) ជាមួយការពន្យារពេលលើការអនុវត្តនៃ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ១៧ កិច្ចសន្យាធានារ៉ាប់រង និង ៩ ឧបករណ៍ហិរញ្ញវត្ថុ ស្របតាមសេចក្តីជូនដំណឹងរបស់និយ័តករគណនេយ្យ និងសវនកម្ម អនុញ្ញាតលើការពន្យារពេលក្នុងការអនុវត្តស្តង់ដាទាំងនេះ។

បានចុះហត្ថលេខាដោយអនុលោមទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងក្នុងនាមក្រុមហ៊ុនរួម និងក្រុមហ៊ុន

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦
ចុះហត្ថលេខាតំណាងដោយក្រុមប្រឹក្សាភិបាលរបស់ ក្រុមហ៊ុនរួម
និងក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា “កម្ពុជា រី”

ប្រធានក្រុមប្រឹក្សាភិបាល	**អគ្គនាយក**
រស់ សីលវ៉ា	ហ៊ុយ វ៉ាចារ៉ូ

៦

របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្ម

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
64 Preah Norodom Boulevard
Corner Street 178, Sangkat Chey Chumneah
Khan Daun Penh, Phnom Penh, Cambodia

Tel: +855 23 860 450/451
Email: eykoc@kh.ey.com
Website: ey.com/en_kh

Shape the future
with confidence

យោង៖ ៦១៥៦៩៦១៧/៦៩៥៥៩៦០៧

របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះ៖ ភាគទុនិក និងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន ធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"

មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមហ៊ុន ធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ហៅកាត់ថា ("ក្រុមហ៊ុន") និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ជារួមហៅកាត់ថា "ក្រុមហ៊ុនរួម") និង របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ក្រុមហ៊ុន ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និង ដាច់ដោយឡែក នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងរបាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លទ្ធផល ពេញលេញផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់រួម និងដាច់ដោយ ឡែក សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ដោយរួមមានព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ជារួមហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក")។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកនេះ បង្ហាញនូវទិដ្ឋភាពពិត និង ត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផល ហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយ អនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ("CIFRSs") ជាមួយការពន្យារ ពេលលើការអនុវត្តនៃ CIFRS ១៧ កិច្ចសន្យាធានារ៉ាប់រង និង CIFRS ៩ ឧបករណ៍ហិរញ្ញវត្ថុ ("CIFRSs ជាមួយ ការពន្យារលើ CIFRS ១៧ និង CIFRS ៩) ស្របតាមការអនុម័តរបស់និយ័តករគណនេយ្យ និងសវនកម្ម ដែល អនុញ្ញាតសម្រាប់ការពន្យារលើការអនុវត្ត (សូមមើលកំណត់សម្គាល់លេខ ២.២)។

មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្ម នៃកម្ពុជា ("CISAs")។ ការ ទទួលខុសត្រូវរបស់យើងខ្ញុំយោងតាមស្តង់ដាទាំងនោះ ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ *ការទទួលខុស ត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមាន ឯករាជ្យភាពពីក្រុមហ៊ុន ដោយយោងតាមប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដែលសមស្របចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៃសហគ្រាសដែលទទួល ខុសត្រូវជាសាធារណៈ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃកម្ពុជា ជាមួយតម្រូវការផ្នែកសីលធម៌ ដែលពាក់ព័ន្ធនឹងការងារសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ នៃសហគ្រាសដែលទទួលខុសត្រូវ ជាសាធារណៈ នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌របស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះផងដែរ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

Shape the future
with confidence

ការសង្កត់ធ្ងន់លើបញ្ហា

យើងខ្ញុំ សូមទាញចំណាប់អារម្មណ៍ទៅលើកំណត់សម្គាល់លេខ ២.២ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ដែលពណ៌នាអំពីការណែនាំលើការពន្យារពេលអនុវត្តស្តង់ដា CIFRS ១៧ និង CIFRS ៩។ មតិយោបល់របស់យើងខ្ញុំ មិនត្រូវបានកែប្រែចំពោះបញ្ហានេះទេ។

បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិ ដែលមិនមានការកែប្រែ លើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ នៅថ្ងៃទី២៨ ខែមិនា ឆ្នាំ២០២៥។

ព័ត៌មានផ្សេងៗ ក្រៅពីរបាយការណ៍ហិរញ្ញវត្ថុសរុប និងដាច់ដោយឡែក និងរបាយការណ៍របស់សវនករ

ព័ត៌មានផ្សេងៗដែលទទួលបាន នាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍និងសេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាភិបាល។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានបែបធានាអះអាងក្នុងទម្រង់ណាមួយ ទៅលើព័ត៌មានផ្សេងៗនេះដែរ។

ទាក់ទងនឹងសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយពិចារណាថា តើព័ត៌មានផ្សេងៗនេះមានភាពខុសគ្នាជាសារវន្តឬទេ ជាមួយនឹង របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ឬ ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការងារសវនកម្ម ឬ ថាតើព័ត៌មានផ្សេងៗនេះមានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះ ដោយផ្អែកលើការងារដែលបានអនុវត្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ដែលផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត CIFRS ១៧ និង CIFRS ៩ ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ដែលពុំមាននូវកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

EY

Shape the future
with confidence

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច (តពីទំព័រមុន)

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក គណៈគ្រប់គ្រងមានទំនួលខុសត្រូវលើការវាយតម្លៃនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង ប្រសិនបើមាន នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹង និរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធានគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណី គណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការក្រុមហ៊ុន ឬ ក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការ នៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា ការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយត្រូវបានចាត់ទុកថា ជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក។

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្រប សម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញ មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានភាពជាសារវន្ត ជាងហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណង ដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផល នៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀត ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

Shape the future
with confidence

ការទទួលខុសត្រូវរបស់សវនករចំពោះសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក (តពីទំព័រមុន)

- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មតាមវិធាន គណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថា តើមានវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌទាំងឡាយណា ដែលនាំឱ្យមានការសង្ស័យជាសារវន្តទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនរួម និង ក្រុមហ៊ុន ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានវត្តមាននៃភាពមិនប្រាកដប្រជា ជាសារវន្ត យើងខ្ញុំ តម្រូវឱ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍របស់សវនករ លើកំណត់សម្គាល់ពាក់ព័ន្ធ ដែលមាននៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ឬ ប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់ គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើ ភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ។ តែទោះជា យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬ លក្ខខណ្ឌនាពេលអនាគត ក៏អាចបង្កអោយក្រុមហ៊ុនរួម និង ក្រុមហ៊ុន មិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក តំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋាន ដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពី វិសាលភាព និងពេលវេលាដែលបានគ្រោងទុក នៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផង ដែរនូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ព្រះរាជាណាចក្រកម្ពុជា
អ៊ីនស្ទ័ អែន យ៉ាំង (ខេមបូឌា)
ERNST & YOUNG (CAMBODIA) LTD

Emmanuel A. Guelas

Emmanuel A. Guelas
Partner

អ៊ីនស្ទ័ អែន យ៉ាំង (ខេមបូឌា)
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៦

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម					
ប្រាក់តម្កល់ធានាអាជីវកម្ម	៦	១.៤១០.០០០	៥.៦៥៨.៣៣០	១.៤១០.០០០	៥.៦៧៥.២៥០
ទ្រព្យសកម្មអរូបី	៧	២៤.០៥១	៩៦.៥១៧	៣២.៥១៨	១៣០.៨៨៥
ទ្រព្យ និងបរិក្ខារ	៨	៩.៣១៨.៩៨៤	៣៧.៣៩៧.០៨៣	៦.៣៤០.៤៩៣	២៥.៥២០.៤៨៤
ការវិនិយោគ	១០	២៦.៤៦៧.០១១	១០៦.២១២.១១៥	២៩.២៦៤.៩១៧	១១៧.៧៩១.២៩១
គណនីធានារ៉ាប់រងត្រូវទទួល	១១	៧.១៤៨.៦៤៣	២៨.៦៨៧.៥០៤	៩.១៧៤.១៦១	៣៦.៩២៥.៩៩៨
ទ្រព្យសកម្មធានារ៉ាប់រងបន្ត	១២	២.៩៤៤.៦៤៧	១១.៨១៦.៨៦៨	២.៤០៧.០៥២	៩.៦៨៨.៣៨៤
ទ្រព្យសកម្មផ្សេងៗ	១៣	៨៣.៣០១	៣៣៤.២៨៧	២៨.២១៩	១១៣.៥៨២
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	១៤	៥១១.៨៧៤	២.០៥៤.១៥០	៨៩៨.៧៤៣	៣.៦១៧.៤៤១
ទ្រព្យសកម្មសរុប		**៤៧.៩០៨.៥១១**	**១៩២.២៥៦.៨៥៤**	**៤៩.៥៥៦.១០៣**	**១៩៩.៤៦៣.៣១៥**
មូលធន និងបំណុល					
មូលធន					
ដើមទុន	១៥	១៤.០០០.០០០	៥៦.០០០.០០០	១៤.០០០.០០០	៥៦.០០០.០០០
ទុនបម្រុង	១៦	៦.០៤១.១១៧	២៤.៣៦២.៩០៦	៥.៩៦៨.៩៦៣	២៤.០៧៣.២៨៤
ទុនបម្រុងពីការវាយតម្លៃឡើងវិញ	១៧	២៣៤.៦៨៧	៩៥០.០១៥	១៩២.១១៤	៧៧៩.២៥៥
ប្រាក់ចំណេញរក្សាទុក		៧.១៨២.៥៧២	២៩.៤២២.៧៨០	៧.៣៩៤.៧២៣	៣០.២៧៥.៦០៩
លម្អៀងបង្គរពីការប្តូររូបិយប័ណ្ណ		-	(៥៤៥.២៣៨)	-	(២១៦.០៥៣)
មូលធនត្រូវបែងចែកជូនម្ចាស់ក្រុមហ៊ុន		**២៧.៤៥៨.៣៧៦**	**១១០.១៩០.៤៦៣**	**២៧.៥៥៥.៨០០**	**១១០.៩១២.០៩៥**
ភាគហ៊ុនអប្បភាគ		(៥៦.៩៤៣)	(២២៨.៥១២)	១១៨.៧៨០	៤៧៨.០៩០
មូលធនសរុប		**២៧.៤០១.៤៣៣**	**១០៩.៩៦១.៩៥១**	**២៧.៦៧៤.៥៨០**	**១១១.៣៩០.១៨៥**
បំណុល					
បំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	១៣.២១៩.៨១៦	៥៣.០៥១.១២២	១១.៥៤៦.៦៩៥	៤៦.៤៧៥.៤៤៧
គណនីធានារ៉ាប់រងត្រូវទូទាត់	២០	៦.៨៩៧.៥១៩	២៧.៦៧៩.៧៤៤	១០.០៧៨.១៤៣	៤០.៥៦៤.៥២៦
បំណុលផ្សេងៗ	២១	១៨៨.៦៧៨	៧៥៧.១៦៣	៧០.៧៧៨	២៨៤.៨៨១
បំណុលពន្ធលើប្រាក់ចំណូល	២២	២០១.០៦៥	៨០៦.៨៧៤	១៨៥.៩០៧	៧៤៨.២៧៦
បំណុលសរុប		**២០.៥០៧.០៧៨**	**៨២.២៩៤.៩០៣**	**២១.៨៨១.៥២៣**	**៨៨.០៧៣.១៣០**
មូលធន និងបំណុលសរុប		**៤៧.៩០៨.៥១១**	**១៩២.២៥៦.៨៥៤**	**៤៩.៥៥៦.១០៣**	**១៩៩.៤៦៣.៣១៥**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

របាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗរួម

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	*២០២៥*			
		មិនមែនអាយុជីវិត	*អាយុជីវិត*	*សរុប*	
		ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ពាន់រៀល*
ចំណូលបុព្វលាភដុល	៣២	២០.៥៧៨.៦៦៨	៣៧៧.០០៤	២០.៩៥៥.៦៧២	៨៤.០៥៣.២០០
បុព្វលាភធានារ៉ាប់រងបន្ត	២៣	(៤.៧១២.១៨៥)	(១៧.៦៩០)	(៤.៧២៩.៨៧៥)	(១៨.៩៧១.៥២៩)
បម្រែបម្រួលទុនបុព្វលាភបម្រុងមិនទាន់ទទួលស្គាល់	១៩	(១៥៧.០៣៨)	៨២.១៣៩	(៧៤.៨៩៩)	(៣០០.៨២០)
ចំណូលបុព្វលាភសុទ្ធ		**១៥.៧០៩.៤៤៥**	**៤៤១.៤៥៣**	**១៦.១៥០.៨៩៨**	**៦៤.៧៨១.២៥១**
ចំណូលកម្រៃជើងសា	២៤	១.៨៨៥.៤៩៧	៤.០៥០	១.៨៨៩.៥៤៧	៧.៥១៨.៥៣៣
ចំណូលធានារ៉ាប់រងសរុប		**១៧.៥៩៤.៩៤២**	**៤៤៥.៥០៣**	**១៨.០៤០.៤៤៥**	**៧២.២៩៩.៧៨៤**
សំណងដុលដែលបានទូទាត់		(៨.៦១៨.៦៥៩)	(៣៧៣.៥៨៦)	(៨.៩៩២.២៤៥)	(៣៦.០៦៧.៨៩៥)
សំណងដែលបានផ្ទេរទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត		៥៨៨.២៦០	១០.៤៤៧	៥៩៨.៧០៧	២.៣៩៨.៣៧០
បម្រែបម្រួលនៃបំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	(១.១៥៦.៩៤៦)	៩៦.៣១៩	(១.០៦០.៦២៧)	(៤.២៥៤.១៧៥)
សំណងសុទ្ធ		**(៩.១៨៧.៣៤៥)**	**(២៦៦.៨២០)**	**(៩.៤៥៤.១៦៥)**	**(៣៧.៩៣៦.៧០០)**
ចំណាយកម្រៃជើងសា	២៦	(៦.១៨៩.២០២)	(៤.៥៧០)	(៦.១៩៣.៧៧២)	(២៤.៦៨២.៧៧៦)
ប្រាក់វិភាគទាន		(១០២.៨៩៦)	(១.៨៨៥)	(១០៤.៧៨១)	(៤២០.២៧៧)
ចំណាយធានារ៉ាប់រងសរុប		**(១៥.៤៨៣.៤៤៣)**	**(២៧៣.២៧៥)**	**(១៥.៧៥៦.៧១៨)**	**(៦៣.០៣៦.៧៥៦)**
ចំណេញពីធានារ៉ាប់រង		២.១១១.៤៩៩	១៧២.២២៨	២.២៨៣.៧២៧	៩.១៦០.០២៨
ចំណូលហិរញ្ញវត្ថុ និងចំណូលផ្សេងៗ	២៥			១.៧២០.៩៧៩	៦.៩០២.៨៤៧
ចំណាយប្រតិបត្តិការ	២៧			(២.៥៥៤.០៣៤)	(១០.២៤៤.២៣០)
ចំណេញមុនកាត់ពន្ធលើប្រាក់ចំណូល				**១.៤៥០.៦៧២**	**៥.៨១៨.៦៤៥**
ចំណាយពន្ធលើប្រាក់ចំណូល	២២			(៩២៦.៣៩២)	(៣.៧១៥.៧៩៨)
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ				**៥២៤.២៨០**	**២.១០២.៨៤៧**
ចំណូលលម្អិតផ្សេងៗ					
ធាតុដែលមិនត្រូវចាត់ថ្នាក់ឡើងវិញក្នុងរបាយការណ៍ចំណេញ ឬខាត					
ខាតលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់	១៧			៤២.៥៧៣	១៧០.៧៦០
លម្អៀងពីការប្តូររូបិយប័ណ្ណ				-	(៣៣០.៩៦១)
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ				**៥៦៦.៨៥៣**	**១.៩៤២.៦៤៦**
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ ត្រូវបែងចែក ឱ្យ ៖					
អប្បភាគភាគកម្ម				(១៧៥.៧២៣)	(៧០៤.៨២៦)
ម្ចាស់ក្រុមហ៊ុន				៧០០.០០៣	២.៨០៧.៧១៣
				៥២៤.២៨០	**២.១០២.៨៤៧**
ចំណូលលម្អិតសរុប ត្រូវបែងចែក ឱ្យ ៖					
អប្បភាគភាគកម្ម				(១៧៥.៧២៣)	(៧០៦.៦០២)
ម្ចាស់ក្រុមហ៊ុន				៧៤២.៥៧៦	២.៦៤៩.២៤៨
				៥៦៦.៨៥៣	**១.៩៤២.៦៤៦**

របាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗរួម (ត)

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥			
		មិនមែនអាយុជីវិត	អាយុជីវិត	សរុប	
		ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលបុព្វលាភដុល	៣២	១៥.២៦២.២០៧	៦៤៩.០៩៣	១៥.៩១១.៣០០	៨១.០៥៨.៩០២
បុព្វលាភដែលបានផ្ទេរចេញទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត	២៣	(៤.៣៣៩.៥៦៥)	(២៤.៦៩១)	(៤.៣៦៤.២៥៦)	(១៧.៧៦៦.៨៨៦)
បម្រែបម្រួលទុនបុព្វលាភបម្រុងមិនទាន់ទទួលស្គាល់	១៩	(៥៧៦.៦៣៧)	២០៦.៥៧០	(៣៧០.០៦៧)	(១.៥០៦.៩៤៣)
ចំណូលបុព្វលាភសុទ្ធ		**១៤.៣៤៦.០០៥**	**៨៣០.៩៧២**	**១៥.១៧៦.៩៧៧**	**៦១.៧៨៥.៤៧៣**
ចំណូលកម្រៃជើងសា	២៤	១.៣៩០.៨២៣	៥.៤៣៥	១.៣៩៦.២៥៨	៥.៦៨៤.១៦៦
ចំណូលធានារ៉ាប់រងសរុប		**១៥.៧៣៦.៨២៨**	**៨៣៦.៤០៧**	**១៦.៥៧៣.២៣៥**	**៦៧.៤៦៩.៦៣៩**
សំណងដុលដែលបានទូទាត់		(១០.៣៥២.០៦៧)	(៦៥៤.៣០៥)	(១១.០០៦.៣៧២)	(៤៤.៨០៦.៩៥០)
សំណងដែលបានផ្ទេរទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត		២.៨២៨.៩៣៩	១០.៥០០	២.៨៣៩.៤៣៩	១១.៥៥៩.៣៥៦
បម្រែបម្រួលនៃចំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	២០៤.២៨១	(៥៧.៦៥៤)	១៤៦.៦២៧	៥៩៦.៩១៩
សំណងសុទ្ធ		**(៧.៣១៨.៨៤៧)**	**(៧០១.៤៥៩)**	**(៨.០២០.៣០៦)**	**(៣២.៦៥០.៦៧៥)**
ចំណាយកម្រៃជើងសា	២៦	(៥.៩៤៨.០៩៨)	(៥២.៥៩៤)	(៦.០០០.៦៩២)	(២៤.៤២៨.៨១៧)
ប្រាក់វិភាគទាន		(៩៦.៣១៤)	(៣.២៤៥)	(៩៩.៥៥៩)	(៤០៥.៣០៥)
ចំណាយធានារ៉ាប់រងសរុប		**(១៣.៣៦៣.២៥៩)**	**(៧៥៧.២៩៨)**	**(១៤.១២០.៥៥៧)**	**(៥៧.៤៨៤.៧៨៧)**
ចំណេញពីធានារ៉ាប់រង		២.៣៧៣.៥៦៩	៧៩.១០៩	២.៤៥២.៦៧៨	៩.៩៨៤.៨៥២
ចំណូលហិរញ្ញវត្ថុ និងចំណូលផ្សេងៗ	២៥			១.៨១៧.១៧៩	៧.៣៩៧.៧៣៦
ចំណាយប្រតិបត្តិការ	២៧			(២.២៨១.១៦១)	(៩.២៨៦.៦០៦)
ចំណេញមុនគិតពន្ធលើប្រាក់ចំណូល				**១.៩៨៨.៦៩៦**	**៨.០៩៥.៩៨២**
ចំណាយពន្ធលើប្រាក់ចំណូល	២២			(៨៦៨.៩៥៤)	(៣.៥៣៧.៥១២)
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ				**១.១១៩.៧៤២**	**៤.៥៥៨.៤៧០**
ចំណូលលម្អិតផ្សេងៗ					
ធាតុដែលមិនត្រូវចាត់ថ្នាក់ឡើងវិញក្នុងរបាយការណ៍ចំណេញ ឬខាត					
ខាតលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់	១៧			(២៤.៧១៨)	(១០០.៦១១)
លម្អៀងពីការប្តូររូបិយប័ណ្ណ				-	(១.៧២៩.៥៣១)
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ				**១.០៩៥.០២៤**	**២.៧២៨.៣២៨**
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ ត្រូវបែងចែក ឱ្យ ៖					
អប្បភាគភាគកម្ម				(១២៣.៧១៩)	(៥០៣.៦៦០)
ម្ចាស់ក្រុមហ៊ុន				១.២៤៣.៤៦១	៥.០៦២.១៣០
				១.១១៩.៧៤២	**៤.៥៥៨.៤៧០**
ចំណូលលម្អិតសរុប ត្រូវបែងចែក ឱ្យ ៖					
អប្បភាគភាគកម្ម				(១២៣.៧១៩)	(៥១២.៥១៩)
ម្ចាស់ក្រុមហ៊ុន				១.២១៨.៧៤៧	៣.២៤៩.៧០៦
				១.០៩៥.០២៤	**២.៧២៨.៣២៨**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

របាយការណ៍បម្រែបម្រួលមូលធនរួម

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ត្រូវបែងចែកជូនម្ចាស់ក្រុមហ៊ុន						
	ដើមទុន		ទុនបម្រុង		ទុនបម្រុងពីការវាយតម្លៃឡើងវិញ		
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	
២០២៥							
សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	១៤.០០០.០០០	៥៦.០០០.០០០	៥.៦២៨.៩២៣	២៤.០៧៣.២៨៨	១៩២.១១៨	៧៧៤.២៥៥	
ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន៖							
ការបែងចែកភាគលាភ *(កំណត់សម្គាល់លេខ ១៨)*	-	-	-	-	-	-	
ការផ្ទេរទៅទុនបម្រុងសម្រាប់គ្រោះមហន្តរាយ *(កំណត់សម្គាល់លេខ ១២)*	-	-	៨៨.២៥១	៣៥៥.៣០២	-	-	
ការផ្ទេរទៅមូលនិធិបម្រុងសង្គម និងការអភិវឌ្ឍ *(កំណត់សម្គាល់លេខ ១២)*	-	-	១៧.២៨៨	៧០.៥២២	-	-	
ការផ្ទេរពីមូលនិធិបម្រុងសង្គម *(កំណត់សម្គាល់លេខ ១២)*	-	-	(៣៣.៧៥៥)	(១៣៥.៥៥២)	-	-	
	-	-	**៧២.០៨៨**	**២៨៥.២២២**	-	-	
ចំណូលលម្អិតសរុប							
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	
ចំណូលលម្អិតសរុបផ្សេងៗ							
ចំណេញលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់	-	-	-	-	៥២.៥៧៣	១៧០.៧២០	
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ	-	-	-	-	**៥២.៥៧៣**	**១៧០.៧២០**	
សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**១៤.០០០.០០០**	**៥៦.០០០.០០០**	**៥.៧០០.០១៨**	**២៤.៣៦២.៩០២**	**២៣៤.២៥៧**	**៩៤៥.០១៥**	

	ត្រូវបែងចែកជូនម្ចាស់ក្រុមហ៊ុន					[illegible]		សរុប	
	ប្រាក់ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ	សរុប					
	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
២០២៥									
សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	៧.៣៤៥.៧២៣	៣០.២៧៨.២០៥	(២០២.០៥៣)	២៧.៨៥៥.៨០០	១១០.៦០២.០៥៥	១០៥.៧៨០	៥៧៥.០៤០	២៧.២៧៥.៥៨០	១១០.៣៥០.១៨៥
ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន៖									
ការបែងចែកភាគលាភ *(កំណត់សម្គាល់លេខ ១៨)*	(៨៥០.០០០)	(៣.៣៧០.៦២០)	-	(៨៥០.០០០)	(៣.៣៧០.៦២០)	-	-	(៨៥០.០០០)	(៣.៣៧០.៦២០)
ការផ្ទេរទៅទុនបម្រុងសម្រាប់គ្រោះមហន្តរាយ *(កំណត់សម្គាល់លេខ ១២)*	(៨៨.២៥១)	(៣៥៥.៣០២)	-	-	-	-	-	-	-
ការផ្ទេរទៅមូលនិធិបម្រុងសង្គម និងការអភិវឌ្ឍ *(កំណត់សម្គាល់លេខ ១២)*	(១៧.២៨៨)	(៧០.៥២២)	-	-	-	-	-	-	-
ការផ្ទេរពីមូលនិធិបម្រុងសង្គម *(កំណត់សម្គាល់លេខ ១២)*	៣៣.៧៥៥	១៣៥.៥៥២	-	-	-	-	-	-	-
	(៩០២.០៨៨)	**(៣.៦៤០.៥៩២)**	-	**(៨៥០.០០០)**	**(៣.៣៧០.៦២០)**	-	-	**(៨៥០.០០០)**	**(៣.៣៧០.៦២០)**
ចំណូលលម្អិតសរុប									
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	៧០០.០០៣	២.៨០៧.៧០៣	-	៧០០.០០៣	២.៨០៧.៧០៣	(១៣៥.៧២៣)	(៧០៥.២២២)	៥២៤.២៥០	២.១០២.៨៨៧
ចំណូលលម្អិតសរុបផ្សេងៗ									
ចំណេញលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់	-	-	-	៥២.៥៧៣	១៧០.៧២០	-	-	៥២.៥៧៣	១៧០.៧២០
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	(៣២៤.០៥៥)	-	(៣២៤.០៥៥)	-	(១.៧៧២)	-	(៣៣០.៤២០)
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ	**៧០០.០០៣**	**២.៨០៧.៧០៣**	**(៣២៤.០៥៥)**	**៧៥២.៥៧៦**	**២.៦៥៤.២៥៨**	**(១៣៥.៧២៣)**	**(៧០២.២០១)**	**៥៦២.៥៥៣**	**១.៩៥២.២៥២**
សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**៧.០៥២.៥៥២**	**២៨.៥២២.៧៥០**	**(៥២៥.២៣៨)**	**២៧.៥៥៥.៣០២**	**១១០.០៤០.៥២៣**	**(៥២.៥៥៣)**	**(២២៥.៥០២)**	**២៧.៥០១.៥៣៣**	**១០៥.៥២០.៥៥០**

របាយការណ៍បម្រែបម្រួលមូលធនរួម (ត)

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	[illegible]														
	[illegible]		[illegible]		[illegible]		[illegible]		[illegible]	[illegible]		[illegible]		[illegible]	
	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
[illegible]															
[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
[illegible]															
[illegible]	-	-	-	-	-	-	[illegible]	[illegible]	-	[illegible]	[illegible]	-	-	[illegible]	[illegible]
[illegible]	-	-	[illegible]	[illegible]	-	-	[illegible]	[illegible]	-	-	-	-	-	-	-
[illegible]	-	-	[illegible]	[illegible]	-	-	[illegible]	[illegible]	-	-	-	-	-	-	-
[illegible]	-	-	[illegible]	[illegible]	-	-		-	-	[illegible]	[illegible]	-	-	[illegible]	[illegible]
	-	-	**[illegible]**	**[illegible]**	-	-	**[illegible]**	**[illegible]**	-	**[illegible]**	**[illegible]**	-	-	**[illegible]**	**[illegible]**
[illegible]															
[illegible]	-	-	-	-	-	-	[illegible]	[illegible]	-	[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]
[illegible]															
[illegible]	-	-	-	-	[illegible]	[illegible]	-	-	-	[illegible]	[illegible]	-	-	[illegible]	[illegible]
[illegible]	-	-	-	-	-	-	-	-	[illegible]	-	[illegible]	-	[illegible]	-	[illegible]
[illegible]	-	-	-	-	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**
[illegible]	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**	**[illegible]**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

របាយការណ៍លំហូរសាច់ប្រាក់រួម

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ឆ្នាំ២០២៥		ឆ្នាំ២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
សកម្មភាពប្រតិបត្តិការ					
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		៥២៥.២៤០	២.១០២.៨៨៧	១.១១៩.៧៤២	៤.៥៥៨.៩៧០
និយ័តកម្មលើ៖					
ចំណូលពីការប្រាក់ និងចំណូលភាគលាភ	២៥	(១.៧២០.៩៧៩)	(៦.៩០២.៨៤៧)	(១.៨១៧.១៧៩)	(៧.៣៩៧.៧៣៦)
រំលស់ទ្រព្យបរិក្ខារ និងអរូបី	២៧	១០៥.៧៤៥	៤២៤.១៤៣	៩៧.៩៥២	៣៩៨.៧៦៣
ចំណាយពន្ធលើប្រាក់ចំណូល	២២	៩២៦.៣៩២	៣.៧១៥.៧៥៨	៨៦៤.៩៥៥	៣.៥៣៧.៥១២
ការខាតបង់នៃការលក់ទ្រព្យ និងបរិក្ខារ		២២៦	៩០៦	-	-
(ខាត)/ចំណេញ ប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល		(១៦៤.៣៣៦)	(៦៥៩.១៥៣)	២៦៩.៤៦៩	១.០៩៧.០០៩
បម្រែបម្រួលទុនបង្វិល៖					
គណនីធានារ៉ាប់រងត្រូវទទួល		២.០២៥.៥១៨	៨.១២៤.៣៥៣	(១.៦៣៦.៩៣៨)	(៦.៦៦៣.៩៧៥)
ប្រាក់តម្កល់ធានាអាជីវកម្ម		-	-	(១០.០០០)	(៤០.៧១០)
គណនីត្រូវទទួលផ្សេងៗ		(៥៥.០៨២)	(២២០.៩៣៤)	(១៦.២៥១)	(៦៦.១៥៨)
គណនីធានារ៉ាប់រងត្រូវទូទាត់		(៣.១៨០.៦២៤)	(១២.៧៥៧.៨៨៣)	១.៨៩១.៣៨៦	៧.៦៩៩.៦៧០
បំណុលផ្សេងៗ		១១៧.៩០០	៤៧២.៨៩៧	៥៩.៩៧៥	២៤៤.១៥៨
ទុនបុព្វលាភបម្រុងមិនទាន់ទទួលស្គាល់	១៩	៧៤.៨៩៩	៣០០.៤២០	៣៧០.០៩៧	១.៥០៦.៥៤៣
បំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	១.០៦០.៦២៧	៤.២៥៥.១៧៥	(១៤៦.៦២៧)	(៥៩៦.៩១៩)
សាច់ប្រាក់(ប្រើប្រាស់)/ទទួលបានពីប្រតិបត្តិការ		**(១២១.០៩៨)**	**(៤៨៥.៧២៥)**	**៧៨១.០៩១**	**៣.១៧៩.៦១៨**
ពន្ធលើប្រាក់ចំណូលដែលបានបង់	២២	(៩១១.២៣៤)	(៣.៦៥៥.៩៦០)	(៧៩៦.១៩៣)	(៣.២៤១.៣០២)
សាច់ប្រាក់សុទ្ធ ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ		**(១.០៣២.៣៣២)**	**(៤.១៤០.៦៨៥)**	**(១៥.១៥២)**	**(៦១.៦៨៤)**
សកម្មភាពវិនិយោគ					
ការទិញ៖					
ទ្រព្យ និងបរិក្ខារ	៨	(៣.០៧៥.៩៩៥)	(១២.៣៣៧.៨១៦)	(៦៧.៩៤៣)	(២៧៦.៥៩៥)
ទ្រព្យសកម្មអរូបី	៧	-	-	(៤.២៦១)	(១៧.៣៤៧)
ប្រាក់បញ្ញើនៅធនាគារ		(៤.៨៩៩.០០៦)	(១៨.០២៥.៨៥៨)	(១១.១៧៥.៥០៦)	(៤៥.៤៩៥.៨៨៥)
សញ្ញាប័ណ្ណសាជីវកម្ម		(៧០៤.១២២)	(២.៨២៤.២៣៣)	(១.០១០.៥៧៥)	(៤.១១៤.០៥១)
ប្រាក់បញ្ញើនៅធនាគារដល់កាលកំណត់		៨.២៣៩.៨៦០	៣៣.០៤៨.៤៧៤	១១.៨៩៧.១១០	៤៨.៤៣៣.១៣៥
ការប្រាក់ និងភាគលាភបានទទួល		១.៥២០.១២៦	៦.០៩៧.២២៥	១.៧៤៨.៤៧១	៧.១១៨.០២៥
សាច់ប្រាក់សុទ្ធ ទទួលបានពីសកម្មភាពវិនិយោគ		**១.៨៨៥.៨៦៣**	**៥.៩៥៨.១៩២**	**១.៣៨៧.២៦៦**	**៥.៦៤៧.៦៨២**
សកម្មភាពហិរញ្ញប្បទាន					
ភាគលាភបានទូទាត់	១៨	(៨៤០.០០០)	(៣.៣៦៩.២៤០)	(១.៤០០.០០០)	(៥.៦៩៩.៤០០)
ការប្រើប្រាស់មូលនិធិបម្រុងសង្គម	១៦	-	-	(២៧.៥៩៨)	(១១២.៣៥១)
សាច់ប្រាក់សុទ្ធ ប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន		**(៨៤០.០០០)**	**(៣.៣៦៩.២៤០)**	**(១.៤២៧.៥៩៨)**	**(៥.៨១១.៧៥១)**
ការថយចុះសុទ្ធនៃសាច់ប្រាក់និងសាច់ប្រាក់សមមូល		(៣៨៦.៨៦៩)	(១.៥៥១.៧៣៣)	(៥៥.៤៥៤)	(២២៥.៧៥៣)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ		៨៩៨.៧៤៣	៣.៦១៧.៨៤១	៩៥៤.១៩៧	៣.៨៩៧.៨៩៥
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(១១.៥៥៨)	-	(៥៤.៧០១)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ	១៤	**៥១១.៨៧៤**	**២.០៥៤.១៥០**	**៨៩៨.៧៤៣**	**៣.៦១៧.៨៤១**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដាច់ដោយឡែក

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម					
ប្រាក់តម្កល់ធានាអាជីវកម្ម	៦	១.៤០០.០០០	៥.៦១៨.២០០	១.៤០០.០០០	៥.៦៣៥.០០០
ទ្រព្យសកម្មអរូបី	៧	២០.៣៧៥	៨១.៧៦៥	២៨.៤១៥	១១៤.៣៧០
ទ្រព្យ និងបរិក្ខារ	៨	៩.៣០៩.៦៦៥	៣៧.៣៥៩.៦៨៦	៦.៣៣៣.៣៦២	២៥.៤៩១.៧៨២
ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ	៩	២៥៥.០០០	១.០២៣.៣១៥	២៥៥.០០០	១.០២៦.៣៧៥
ការវិនិយោគ	១០	២៦.៤៦៧.០១១	១០៦.២១២.១១៥	២៩.១៦២.២០៦	១១៧.៣៧៧.៨៧៩
គណនីធានារ៉ាប់រងត្រូវទទួល	១១	៧.១២៣.២៧៣	២៨.៥៨៥.៦៩៥	៩.១៧៤.១៦១	៣៦.៩២៥.៩៩៨
ទ្រព្យសកម្មធានារ៉ាប់រងបន្ត	១២	២.៩៤៤.៦៤៧	១១.៨១៦.៨៦៨	២.៤០៧.០៥២	៩.៦៨៨.៣៨៤
ទ្រព្យសកម្មផ្សេងៗ	១៣	៥៨.២៧៥	២៣៣.៨៥៨	១២.០៥២	៤៨.៥០៩
សាច់ប្រាក់ និងសាច់ប្រាក់សមមូល	១៤	៤៨០.៦៩១	១.៩២៩.០១៣	៧៧០.៤៨១	៣.១០១.១៨៦
ទ្រព្យសកម្មសរុប		**៤៨.០៥៨.៩៣៧**	**១៩២.៨៦០.៥១៥**	**៤៩.៥៤២.៧២៩**	**១៩៩.៤០៩.៤៨៣**
មូលធន និងបំណុល					
មូលធន					
ដើមទុន	១៥	១៤.០០០.០០០	៥៦.០០០.០០០	១៤.០០០.០០០	៥៦.០០០.០០០
ទុនបម្រុង	១៦	៦.០៤១.១១៧	២៤.៣៦៤.១៧៥	៥.៩៦៨.៩៦៣	២៤.០៧៤.៩៥៣
ទុនបម្រុងពីការវាយតម្លៃឡើងវិញ	១៧	២៣៤.៦៨៧	៩៥០.០១៥	១៩២.១១៤	៧៧៩.២៥៥
ប្រាក់ចំណេញរក្សាទុក		៧.៤៩៦.៨៣៨	៣០.៦៩១.២៨២	៧.៥២៦.០៩៤	៣០.៨១០.៥២១
ទុនបម្រុងពីការប្តូររូបិយប័ណ្ណ		-	(៥៥៣.៨៦០)	-	(២២៣.៨៦៦)
មូលធនសរុប		**២៧.៧៧២.៦៤២**	**១១១.៤៥១.៦១២**	**២៧.៦៨៧.១៧១**	**១១១.៤៤០.៨៦៣**
បំណុល					
បំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	១៣.១៦៤.៣១៤	៥២.៨២៨.៣៩២	១១.៥៤៦.៦៩៥	៤៦.៤៧៥.៤៤៧
គណនីធានារ៉ាប់រងត្រូវទូទាត់	២០	៦.៨៩៧.៥១៩	២៧.៦៧៩.៧៤៤	១០.០៧៨.១៤៣	៤០.៥៦៤.៥២៦
បំណុលផ្សេងៗ	២១	៤៤.៦១៩	១៧៩.០៥៧	៥០.២៦២	២០២.៣០៤
បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ	២២	១៧៩.៨៤៣	៧២១.៧១០	១៨០.៤៥៨	៧២៦.៣៤៣
បំណុលសរុប		**២០.២៨៦.២៩៥**	**៨១.៤០៨.៩០៣**	**២១.៨៥៥.៥៥៨**	**៨៧.៩៦៨.៦២០**
មូលធន និងបំណុលសរុប		**៤៨.០៥៨.៩៣៧**	**១៩២.៨៦០.៥១៥**	**៤៩.៥៤២.៧២៩**	**១៩៩.៤០៩.៤៨៣**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

របាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗដាច់ដោយឡែក

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

កំណត់សម្គាល់		*២០២៥*			
		មិនមែនអាយុជីវិត	*អាយុជីវិត*	*សរុប*	
		ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ពាន់រៀល*
ចំណូលបុព្វលាភដុល	៣២	២០.៥៧៨.៦៦៨	៣៧៧.០០៤	២០.៩៥៥.៦៧២	៨៤.០៥៣.២០០
បុព្វលាភដែលបានផ្ទេរចេញទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត	២៣	(៤.៧១២.១៨៥)	(១៧.៦៩០)	(៤.៧២៩.៨៧៥)	(១៨.៩៧១.៥២៩)
បម្រែបម្រួលទុនបុព្វលាភបម្រុងមិនទាន់ទទួលស្គាល់	១៩	(១០១.៥៣៦)	៨២.១៣៩	(១៩.៣៩៧)	(៧៧.៨០១)
ចំណូលបុព្វលាភសុទ្ធ		**១៥.៧៦៤.៩៤៧**	**៤៤១.៤៥៣**	**១៦.២០៦.៤០០**	**៦៥.០០៣.៨៧០**
ចំណូលកម្រៃជើងសា	២៤	១.៦៩០.១៦៩	៤.០៥០	១.៦៩៤.២១៩	៦.៧៩៥.៥១២
ចំណូលធានារ៉ាប់រងសរុប		**១៧.៤៥៥.១១៦**	**៤៤៥.៥០៣**	**១៧.៩០០.៦១៩**	**៧១.៧៩៩.៣៨២**
សំណងដុលដែលបានទូទាត់		(៨.៦១៨.៦៥៩)	(៣៧៣.៥៨៦)	(៨.៩៩២.២៤៥)	(៣៦.០៦៧.៨៥៥)
សំណងដែលបានផ្ទេរទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត		៥៨៤.២៦០	១០.៤៤៧	៥៩៤.៧០៧	២.៣៨៥.៣៧០
បម្រែបម្រួលនៃបំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	(១.៩៥៦.៩៤៦)	៩៦.៣១៩	(១.០៦០.៦២៧)	(៤.២៥៤.១៧៥)
សំណងសុទ្ធ		**(៩.៩៩១.៣៤៥)**	**(២៦៦.៨២០)**	**(៩.៤៥៨.១៦៥)**	**(៣៧.៩៣៦.៧០០)**
ចំណាយកម្រៃជើងសា	២៦	(៦.១៤៩.២០២)	(៤.៥៧០)	(៦.១៥៣.៧៧២)	(២៤.៦៨២.៧៧៩)
ប្រាក់វិភាគទាន		(១០២.៨៩៦)	(១.៨៨៥)	(១០៤.៧៨១)	(៤២០.២២៧)
ចំណាយធានារ៉ាប់រងសរុប		**(១៥.៤៤៣.៤៤៣)**	**(២៧៣.២៧៥)**	**(១៥.៧១៦.៧១៨)**	**(៦៣.០៣៩.៧៥៦)**
ចំណេញពីធានារ៉ាប់រង		**២.០១១.៦៧៣**	**១៧២.២២៨**	**២.១៨៣.៩០១**	**៨.៧៥៩.៦២៦**
ចំណូលហិរញ្ញវត្ថុ និងចំណូលផ្សេងៗ	២៥			១.៧២០.៨៤៧	៦.៩០២.៣១៧
ចំណាយប្រតិបត្តិការ	២៧			(២.០៩៧.០១៣)	(៨.៤១១.១១៩)
ចំណេញមុនគិតពន្ធលើប្រាក់ចំណូល				**១.៨០៧.៧៣៥**	**៧.២៥០.៨២៤**
ចំណាយពន្ធលើប្រាក់ចំណូល	២២			(៩២៤.៨៣៧)	(៣.៧០៩.៥២១)
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ				**៨៨២.៨៩៨**	**៣.៥៤១.៣០៣**
ចំណូលលម្អិតផ្សេងៗ					
ធាតុដែលមិនត្រូវចាត់ថ្នាក់ឡើងវិញក្នុងរបាយការណ៍ចំណេញ ឬខាត					
ខាតលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់	១៧			៤២.៥៧៣	១៧០.៧៦០
លម្អៀងពីការប្តូររូបិយប័ណ្ណ				-	(៣៣០.៣៩៤)
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ				**៩២៥.៤៧១**	**៣.៣៨១.៦៦៩**

របាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗដាច់ដោយឡែក(ត)

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	*២០២៤*			
		មិនមែនអាយុជីវិត	*អាយុជីវិត*	*សរុប*	
		ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ពាន់រៀល*
ចំណូលបុព្វលាភដុល	៣២	១៩.២៦២.២០៧	៦៤៩.០៩៣	១៩.៩១១.៣០០	៨១.០៥៨.៩០២
បុព្វលាភដែលបានផ្ទេរចេញទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត	២៣	(៤.៣៣៩.៥៦៥)	(២៤.៦៩១)	(៤.៣៦៤.២៥៦)	(១៧.៧៦៦.៨៨៦)
បម្រែបម្រួលទុនបុព្វលាភបម្រុងមិនទាន់ទទួលស្គាល់	១៩	(៥៧៦.៦៣៧)	២០៦.៥៧០	(៣៧០.០៦៧)	(១.៥០៦.៥៤៣)
ចំណូលបុព្វលាភសុទ្ធ		**១៤.៣៤៦.០០៥**	**៨៣០.៩៧២**	**១៥.១៧៦.៩៧៧**	**៦១.៧៨៥.៤៧៣**
ចំណូលកម្រៃជើងសា	២៤	១.៣៩០.៨២៣	៥.៤៣៥	១.៣៩៦.២៥៨	៥.៦៨៤.១៦៦
ចំណូលធានារ៉ាប់រងសរុប		**១៥.៧៣៦.៨២៨**	**៨៣៦.៤០៧**	**១៦.៥៧៣.២៣៥**	**៦៧.៤៦៩.៦៣៩**
សំណងដុលដែលបានទូទាត់		(១០.៣៥២.០៦៧)	(៦៥៤.៣០៥)	(១១.០០៦.៣៧២)	(៤៤.៨០៦.៩៤០)
សំណងដែលបានផ្ទេរទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត		២.៨២៨.៩៣៩	១០.៥០០	២.៨៣៩.៤៣៩	១១.៥៥៩.៣៥៦
បម្រែបម្រួលនៃបំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	២០៤.២៨១	(៥៧.៦៥៤)	១៤៦.៦២៧	៥៩៦.៩១៩
សំណងសុទ្ធ		**(៧.៣១៨.៨៤៧)**	**(៧០១.៤៥៩)**	**(៨.០២០.៣០៦)**	**(៣២.៦៥០.៦៦៥)**
ចំណាយកម្រៃជើងសា	២៦	(៥.៩៤៨.០៩៨)	(៥២.៥៩៤)	(៦.០០០.៦៩២)	(២៤.៤២៨.៨១៧)
ប្រាក់វិភាគទាន		(៩៦.៣១៤)	(៣.២៤៥)	(៩៩.៥៥៩)	(៤០៥.៣០៥)
ចំណាយធានារ៉ាប់រងសរុប		**(១៣.៣៦៣.២៥៩)**	**(៧៥៧.២៩៨)**	**(១៤.១២០.៥៥៧)**	**(៥៧.៤៨៤.៧៨៧)**
ចំណេញពីធានារ៉ាប់រង		**២.៣៧៣.៥៦៩**	**៧៩.១០៩**	**២.៤៥២.៦៧៨**	**៩.៩៨៤.៨៥២**
ចំណូលហិរញ្ញវត្ថុ និងចំណូលផ្សេងៗ	២៥			១.៨០៨.៩៩៣	៧.៣៦៤.៤១១
ចំណាយប្រតិបត្តិការ	២៧			(២.០២០.៤៨៨)	(៨.២២៥.៤០៧)
ចំណេញមុនគិតពន្ធលើប្រាក់ចំណូល				**២.២៤១.១៨៣**	**៩.១២៣.៨៥៦**
ចំណាយពន្ធលើប្រាក់ចំណូល	២២			(៨៦៨.៩៥៤)	(៣.៥៣៧.៥១២)
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ				**១.៣៧២.២២៩**	**៥.៥៨៦.៣៤៤**
ចំណូលលម្អិតផ្សេងៗ					
ធាតុដែលមិនត្រូវចាត់ថ្នាក់ឡើងវិញក្នុងរបាយការណ៍ចំណេញ ឬខាត					
ខាតលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់	១៧			(២៤.៧១៤)	(១០០.៦១១)
លម្អៀងពីការប្តូររូបិយប័ណ្ណ				-	(១.៧២៨.០២២)
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ				**១.៣៤៧.៥១៥**	**៣.៧៥៧.៧១១**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ដើមទុន		ទុនបម្រុង		ទុនបម្រុងពីការវាយតម្លៃឡើងវិញ		ប្រាក់ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ	សរុប	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
២០២៥											
គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	១៨.០០០.០០០	៧២.០០០.០០០	៥.៨២៨.៨២៣	២៨.០៧៨.៥៥៣	១៨២.១១៨	៧៧៨.២៥៥	៧.៥២២.០៨៨	៣០.៨១០.៥២១	(២២៣.៨២២)	២៧.២៨៧.១៧១	១១១.៨៨០.៨២៣
ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន៖											
ការបែងចែកភាគលាភ *(កំណត់សម្គាល់លេខ ១៨)*	-	-	-	-	-	-	(៨៨០.០០០)	(៣.៣៧០.៨២០)	-	(៨៨០.០០០)	(៣.៣៧០.៨២០)
ការផ្ទេរទៅទុនបម្រុងសម្រាប់គ្រោះមហន្តរាយ *(កំណត់សម្គាល់លេខ ១២)*	-	-	៨៨.២៦១	៣៥៨.៣១២	-	-	(៨៨.២៦១)	(៣៥៨.៣១២)	-	-	-
ការផ្ទេរទៅមូលនិធិបម្រុងសង្គម និងការអភិវឌ្ឍ *(កំណត់សម្គាល់លេខ ១២)*	-	-	១៧.២៨៨	៧០.៨២២	-	-	(១៧.២៨៨)	(៧០.៨២២)	-	-	-
ការប្រើប្រាស់មូលនិធិបម្រុងសង្គម *(កំណត់សម្គាល់លេខ ១២)*	-	-	(៣៣.៧៨៥)	(១៣៥.៥៥២)	-	-	៣៣.៧៨៥	១៣៥.៥៥២	-	-	-
	-	-	៧២.១៨៨	២៨៨.២២២	-	-	(៨១២.១៨៨)	(៣.២២០.៨៨២)		(៨៨០.០០០)	(៣.៣៧០.៨២០)
ចំណូលលម្អិតសរុប											
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	៨៨២.៨៨៨	៣.៥៨១.៣០៣	-	៨៨២.៨៨៨	៣.៥៨១.៣០៣
ចំណូលលម្អិតសរុបផ្សេងៗ											
ចំណេញលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុ សម្រាប់លក់	-	-	-	-	៨២.៥៧៣	១៧០.៧២០	-	-	-	៨២.៥៧៣	១៧០.៧២០
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	(៣៣០.៣៨៨)	-	(៣៣០.៣៨៨)
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ	-	-	-	-	**៨២.៥៧៣**	**១៧០.៧២០**	**៨៨២.៨៨៨**	**៣.៥៨១.៣០៣**	**(៣៣០.៣៨៨)**	**៩២៥.៨៧១**	**៣.៣៨១.៦២៨**
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**១៨.០០០.០០០**	**៧២.០០០.០០០**	**៦.០៨១.១១៨**	**២៨.៣២៨.១៧៥**	**២៣៨.២៨៧**	**៨៨០.០១៥**	**៧.៨៨២.៨៣៨**	**៣០.២៨១.២៨២**	**(៥៥៣.៨២០)**	**(២៧.៧៧២.២៦២)**	**១១១.៨៨១.២០២**

របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក (ត)

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ដើមទុន		ទុនបម្រុង		ទុនបម្រុងពីការវាយតម្លៃឡើងវិញ		ប្រាក់ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ	សរុប	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
២០២៤											
គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	១៤.០០០.០០០	៥៦.០០០.០០០	៥.៨៣១.៨៨៨	២៣.៥២២.៨៨០	២១២.៨២៤	៨៧៦.៨២២	៧.៧១៤.៨៣២	៣១.៨២១.៦២២	១.៨០៨.៨៨២	២៧.៧២៧.២៨៨	១១៣.៨២៦.២៣៨
ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន៖											
ការបែងចែកភាគលាភ *(កំណត់សម្គាល់លេខ ១៨)*	-	-	-	-	-	-	(១.៨០០.០០០)	(៥.២៣៨.០០០)	-	(១.៨០០.០០០)	(៥.២៣៨.០០០)
ការផ្ទេរទៅទុនបម្រុងសម្រាប់គ្រោះមហន្តរាយ *(កំណត់សម្គាល់លេខ ១៦)*	-	-	១៣៧.២២១	៥៥២.៣១៥	-	-	(១៣៧.២២១)	(៥៥២.៣១៥)	-	-	-
ការផ្ទេរទៅមូលនិធិបម្រុងសង្គម និងការអភិវឌ្ឍ *(កំណត់សម្គាល់លេខ ១៦)*	-	-	២៧.៨៨២	១១០.៨៧០	-	-	(២៧.៨៨២)	(១១០.៨៧០)	-	-	-
ការប្រើប្រាស់មូលនិធិបម្រុងសង្គម *(កំណត់សម្គាល់លេខ ១៦)*	-	-	(២៧.៨៥៤)	(១១១.០៨២)	-	-	-	-	-	(២៧.៨៥៤)	(១១១.០៨២)
	-	**-**	**១៣៧.០២៤**	**៥៥១.៧០៣**	**-**	**-**	**(១.៥២៤.២២៧)**	**(៦.២៥៨.៧៨៨)**	**-**	**(១.៤២៧.៥៥៤)**	**(៥.៧៨៦.០៨៦)**
ចំណូលលម្អិតសរុប											
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	១.៣៧២.២២៤	៥.៥៥២.៣៨៨	-	១.៣៧២.២២៤	៥.៥៥២.៣៨៨
ចំណូលលម្អិតសរុបផ្សេងៗ											
ខាតលើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុ សម្រាប់លក់	-	-	-	-	(២៤.៧១៤)	(១០០.២១១)	-	-	-	(២៤.៧១៤)	(១០០.២១១)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	-	-	-	(១.៧២៤.០២២)	-	(១.៧២៤.០២២)
ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ	**-**	**-**	**-**	**-**	**(២៤.៧១៤)**	**(១០០.២១១)**	**១.៣៧២.២២៤**	**៥.៥៥២.៣៨៨**	**(១.៧២៤.០២២)**	**១.៣៤៧.៥១០**	**៣.៧២៨.១៥៥**
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**១៤.០០០.០០០**	**៥៦.០០០.០០០**	**៥.៩៦៨.៩១៣**	**២៤.០៧៤.៥៥៣**	**១៨៨.១១០**	**៧៧៦.២៥៥**	**៧.៥២២.០៥៤**	**៣០.៨១០.៥២១**	**(២២៣.៥២២)**	**២៧.៦២៧.១៥៧**	**១១១.៥៥០.៨២៣**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

របាយការណ៍លំហូរសាច់ប្រាក់ដាច់ដោយឡែក

សម្រាប់ការិយច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	*ឆ្នាំ២០២៥*		*ឆ្នាំ២០២៤*	
		ដុល្លារអាម៉េរិក	*ពាន់រៀល*	*ដុល្លារអាម៉េរិក*	*ពាន់រៀល*
សកម្មភាពប្រតិបត្តិការ					
ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ		៨៨២.៨៩៨	៣.៥៩១.៣០៣	១.៣៧២.២២៩	៥.៥៨៦.៣៩៩
និយ័តកម្មលើ៖					
ចំណូលពីការប្រាក់ និងចំណូលភាគលាភ	២៥	(១.៧២០.៨៩៧)	(៦.៩០២.៣១៧)	(១.៨០៨.៩៩៣)	(៧.៣៦៥.៤១១)
រំលស់ទ្រព្យបី និងអរូបី	២៧	១០០.៤៦៨	៤០២.៩៧៧	៩៥.៦៧៧	៣៨៥.៤៣០
ចំណាយពន្ធលើប្រាក់ចំណូល	២២	៩២៤.៨៣៧	៣.៧០៩.៥២១	៨៦៨.៩៥៩	៣.៥៣៧.៥១២
ការខាតបង់នៃការលក់ទ្រព្យ និងបរិក្ខារ		២២៦	៩០៦	-	-
ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល		១៨៧.៥៨២	៧៥២.៣៩០	៥២៦.៨៦៧	២.១៤៤.៨៧៥
បម្រែបម្រួលទុនបង្វិល៖					
គណនីធានារ៉ាប់រងត្រូវទទួល		២.០៥០.៨៨៨	៨.២២៦.១១២	(១.៦៣៦.៩៣៨)	(៦.៦៦៣.៩៧៥)
គណនីត្រូវទទួលផ្សេងៗ		(៤៦.២២៣)	(១៨៥.៤០០)	៤.៩៨៩	២០.២៩០
គណនីធានារ៉ាប់រងត្រូវទូទាត់		(៣.១៩០.៦២៥)	(១២.៧៥៧.៨៨៣)	១.៨៩១.៣៨៦	៧.៦៩៩.៦៧០
បំណុលផ្សេងៗ		(៥.៦៤៣)	(២២.៦៣៤)	៤០.៦៨៩	១៦៥.៦៤៥
ទុនបុព្វលាភបម្រុងមិនទាន់ទទួលស្គាល់	១៩	១៩.៣៩៧	៧៧.៨០១	៣៧០.០៦៧	១.៥០៦.៥៥៣
បំណុលកិច្ចសន្យាធានារ៉ាប់រង	១៩	១.០៦០.៦២៧	៤.២៥៤.១៧៥	(១៩៦.៦២៧)	(៥៩៦.៩១៩)
សាច់ប្រាក់ទទួលបានពីប្រតិបត្តិការ		**៨៦.០០៤**	**៣៤៤.៩៦១**	**១.០៥០.៣៨៨**	**៤.២៧៦.១២៩**
ពន្ធលើប្រាក់ចំណូលដែលបានបង់	២១	(៩២៥.៤៥២)	(៣.៧១១.៩៨៨)	(៨០១.៤៧៦)	(៣.២៦២.៨០៩))
សាច់ប្រាក់(ប្រើប្រាស់ក្នុង)/ទទួលបានសុទ្ធពីសកម្មភាពប្រតិបត្តិការ		**(៨៣៩.៤៤៨)**	**(៣.៣៦៧.០២៧)**	**២៤៨.៩១២**	**១.០១៣.៣២០**
សកម្មភាពវិនិយោគ					
ការទិញ៖					
ទ្រព្យ និងបរិក្ខារ	៨	(៣.០៦៨.៩៥៧)	(១២.៣០៩.៥៨៧)	(៥៧.៦៩៦)	(២៣៤.៨៨០)
ប្រាក់បញ្ញើនៅធនាគារ		(៤.៤៩៩.៤	(១៨.០២៧.៤១១)	(១១.០៧២.៧៩៥)	(៤៥.០៧៧.៣៨៨)
សញ្ញាប័ណ្ណសាជីវកម្ម		(៧០៩.	(២.៨២៤.២៣៣)	(១.០១០.៥៧៥)	(៤.១១៤.០៥១)
ប្រាក់បញ្ញើនៅធនាគារដល់កាលកំណត់		៨.១៣៦.៧៥០	៣២.៦៣៦.៥០៤	១១.៨៩៧.១១០	៤៨.៤៣៣.១៣៤
ការប្រាក់ និងភាគលាភបានទទួល		១.៥២០.៤៨០	៦.០៩៨.៦៤៥	១.៧៤០.២៨៥	១.៧៤០.២៨៥
សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពវិនិយោគ		**១.៣៨៩.៦៥៨**	**៥.៥៧៣.៩១៨**	**១.៤៩៦.៣២៩**	**៦.០៩១.៥៥៥**
សកម្មភាពហិរញ្ញប្បទាន					
ភាគលាភបានទូទាត់	១៨	(៨៤០.០០០)	(៣.៣៦៩.២៤០)	(១.៤០០.០០០)	(៥.៦៩៩.៤០០)
ការប្រើប្រាស់មូលនិធិបម្រុងសង្គម	១៦	-	-	(២៧.៥៩៨)	(១១២.៣៥១)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន		**(៨៤០.០០០)**	**(៣.៣៦៩.២៤០)**	**(១.៤២៧.៥៩៨)**	**(៥.៨១១.៧៥១)**
(ការថយចុះ)/ការកើនឡើង សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល		(២៨៩.៧៩០)	(១.១៦២.៣៤៩)	៣១៧.៦៤៣	១.២៩៣.១២៤
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ		៧៧០.៤៨១	៣.១០១.១៨៦	៤៥២.៨៣៨	១.៨៤៩.៨៤៣
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(៩.៨២៤)	-	(៤១.៧៨១)
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ	១៤	**៤៨០.៦៩១**	**១.៩២៩.០១៣**	**៧៧០.៤៨១**	**៣.១០១.១៨៦**

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកទាំងនេះ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

១. អំពីក្រុមហ៊ុន

ក្រុមហ៊ុន ធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ហៅកាត់ថា ("ក្រុមហ៊ុន") និងក្រុមហ៊ុនបុត្រសម្ព័ន្ធ, ក្រុមហ៊ុន កម្ពុជារី ប្លូវេនឈ័រ ឯ.ក (ហៅកាត់ថា "ក្រុមហ៊ុនបុត្រសម្ព័ន្ធ") បានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ដែលតទៅនេះហៅកាត់ថា ក្រុមហ៊ុនរួម)។

ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០២ ជាសហគ្រាសរដ្ឋ ដែលកាន់កាប់ទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជា ដែលស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ Co - ៦០៦៣/០២ Et។ នៅក្នុងឆ្នាំ២០០៤ ក្រុមហ៊ុនបានប្រែក្លាយជាក្រុមហ៊ុនចម្រុះរដ្ឋ ដែលរាជរដ្ឋាភិបាលកម្ពុជា កាន់កាប់ចំណែកភាគហ៊ុនចំនួន ៨០% និងក្រុមហ៊ុន Asia Insurance International (Holding) Co., Ltd (AII) កាន់កាប់ចំណែកភាគហ៊ុនចំនួន ២០%។ការផ្លាស់ប្តូរនេះត្រូវបានចុះបញ្ជីនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ ៦៩៩២/០៤M។

ការរៀបចំម្ចាស់ភាគទុនិកថ្មីបានធ្វើឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមាន ក្រុមហ៊ុន ហ្វតតេ អ៊ិនវេសមិុន ហូលឌីង ឯ.ក (Forte) និងក្រុមហ៊ុន សុវណ្ណភូមិ ឡាយហ្វ៍ អ៊ីស្សូរិនស៍ ភីអិលស៊ី (SVL) បានទិញភាគហ៊ុនសរុប ចំនួន១៧,២២២១% និង ៥,៣៤៧១% នៃដើមទុនសរុបរបស់
ក្រុមហ៊ុន។ បន្ទាប់ពីការផ្លាស់ប្តូរថ្មីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុន Asia Insurance International (Holding) Co., Ltd (AII) កាន់កាប់ភាគហ៊ុនចំនួន ៦០,២០៨៦% និង ១៧,២២២១% នៃដើមទុនសរុបរបស់ក្រុមហ៊ុន។

ការរៀបចំម្ចាស់ភាគទុនិកថ្មីបានធ្វើឡើងនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៥ ដែលមាន ក្រុមហ៊ុន Thai Reinsurance Public Company Limited និងក្រុមហ៊ុន សុវណ្ណភូមិ ឡាយហ្វ៍ អ៊ីស្សូរិនស៍ ភីអិលស៊ី (SVL) បានទិញភាគហ៊ុនសរុប ចំនួន១០,០០០០% និង ១០,០០០០% នៃដើមទុនសរុបរបស់ក្រុមហ៊ុន។ បន្ទាប់ពីការផ្លាស់ប្តូរថ្មីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន ៦០,២០៨៦% នៃដើមទុនសរុបរបស់ក្រុមហ៊ុន និងក្រុមហ៊ុន Asia Insurance International (Holding) Co., Ltd (AII) និងក្រុមហ៊ុន ហ្វតតេ អ៊ិនវេសមិុន ហូលឌីង ឯ.ក (Forte) កាន់កាប់ភាគហ៊ុនចំនួន ១៧,២២២១% និង ២,៥៦៩៣% នៃដើមទុនសរុបរបស់ក្រុមហ៊ុន។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការលើការធានារ៉ាប់រងបន្តលើហានិភ័យធានារ៉ាប់រងមិនមែនអាយុជីវិត និងធានារ៉ាប់រងអាយុជីវិត។ ក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ ក្រោមអាជ្ញាបណ្ណដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្រុមហ៊ុន បានទទួលអាជ្ញាបណ្ណធានារ៉ាប់រងបន្តជាអចិន្ត្រៃយ៍ លេខ ០០១ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនថ្មីមួយដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.០០០២M/២០២៣ ចេញដោយក្រសួងពាណិជ្ជកម្ម (MOC) នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ ដែលភាគហ៊ុន ៥១% នៃក្រុមហ៊ុននេះ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុន ធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ។សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺផ្តល់សេវាលើការគ្រប់គ្រងសំណងធានារ៉ាប់រង ។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅ អគារលេខ១៧ ផ្លូវលេខ ១៣៤ សង្កាត់ មិត្តភាព ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញរួម និងដាច់ដោយឡែកទាំងនេះ នៅថ្ងៃ២៤ ខែមីនា ឆ្នាំ២០២៦។

២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត

២.១. មូលដ្ឋាននៃការរៀបចំ និងការបង្ហាញ

របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ត្រូវបានរៀបចំដោយផ្អែកទៅលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងនៅតម្លៃសមស្រប។

ក្រុមហ៊ុនរួម និងក្រុមហ៊ុន បានរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ខ្លួនទៅតាមមូលដ្ឋាននៃការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម។

ក្រុមហ៊ុនរួម និងក្រុមហ៊ុន បង្ហាញរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនរួម និងក្រុមហ៊ុន បានរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ខ្លួនទៅតាមមូលដ្ឋាននៃការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម។ដោយឡែក របស់ខ្លួនទៅតាមលំដាប់នៃសន្ទនីយភាព។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃសុទ្ធក្រោយការកាត់កងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែមានសិទ្ធិក្នុងការអនុវត្តស្របច្បាប់ដើម្បីកាត់កងចំនួនដែលបានទទួលស្គាល់ ហើយមានបំណងទូទាត់ជាមូលដ្ឋានសុទ្ធ ឬ កត់ត្រាជាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

២.២. របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ត្រូវបានរៀបចំដោយអនុលោមទៅតាមស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIFRSs") ជាមួយនឹងការពន្យារពេលអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ ១៧ កិច្ចសន្យាធានារ៉ាប់រង និង ៩ ឧបករណ៍ហិរញ្ញវត្ថុ (ហៅកាត់ថា "CIFRSs ជាមួយនឹងការពន្យារពេលអនុវត្ត ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ និង ៩") ស្របតាមសេចក្តីជូនដំណឹងរបស់ និយ័តករគណនេយ្យ និងសវនកម្មដែលអនុញ្ញាតឱ្យពន្យារពេលក្នុងការអនុវត្តស្តង់ដាទាំងនេះនៅក្នុងការអនុវត្តរបស់ពួកគេ។ ដូច្នេះហើយ ក្រុមហ៊ុនបានអនុវត្ត ស្តង់ដាគណនេយ្យអន្តរជាតិ ៤ កិច្ចសន្យាធានារ៉ាប់រង ក្នុងការកត់ត្រាគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រង និង CIAS ៣៩ ការទទួលស្គាល់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ ក្នុងការកត់ត្រាគណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ។ (កំណត់សម្គាល់លេខ ៥)

២.៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម

របាយការណ៍ហិរញ្ញវត្ថុរួម រួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក របស់ ក្រុមហ៊ុនរួម និង ក្រុមហ៊ុន ដែលបានរៀបចំនៅចុងការិយបរិច្ឆេទនីមួយៗ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាអង្គភាពដែលគ្រប់គ្រងដោយ ក្រុមហ៊ុន។ ក្រុមហ៊ុនគ្រប់គ្រងលើអង្គភាពប្រសិនបើវា ប្រឈមទៅនឹង ឬមានសិទ្ធិទទួលបានផលចំណេញអថេរពីការចូលរួមរបស់ខ្លួនជាមួយអង្គភាព និងមាន សមត្ថភាពធ្វើឱ្យប្រែប្រួលដល់អត្ថប្រយោជន៍ទាំងនោះ តាមរយៈអំណាចរបស់ខ្លួននៅក្នុងអង្គភាព។ ក្រុមហ៊ុន បានវាយតម្លៃឡើងវិញថាតើវាមានការគ្រប់គ្រងដែរ ឬទេ ប្រសិនបើមានការផ្លាស់ប្តូរធាតុមួយ ឬ ច្រើននៃការ គ្រប់គ្រង។ នេះរួមបញ្ចូលទាំងកាលៈទេសៈដែលសិទ្ធិការពារត្រូវបានធ្វើឡើង (ឧទាហរណ៍ លទ្ធផលដែល ទទួលបានពីទំនាក់ទំនងផ្តល់ប្រាក់កម្ចី) មានប្រសិទ្ធភាព និងធ្វើឱ្យក្រុមហ៊ុនមានអំណាចលើអង្គភាព ដែល ត្រូវបានធ្វើការវិនិយោគ។របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែករបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបាន បញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ចាប់ពីកាលបរិច្ឆេទដែលការគ្រប់គ្រងចាប់ផ្តើម រហូតដល់ថ្ងៃដែលការ គ្រប់គ្រងត្រូវបានបញ្ចប់។ ជាពិសេស លទ្ធផលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានទិញ ឬលក់ ក្នុងអំឡុងឆ្នាំ ត្រូវបានរួមបញ្ចូលក្នុងរបាយការណ៍ចំណេញ ឬខាត និងរបាយការណ៍លទ្ធផលពេញលេញផ្សេងៗ ចាប់ពី កាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានសិទ្ធិគ្រប់គ្រង រហូតដល់កាលបរិច្ឆេទដែលក្រុមហ៊ុមិនមានសិទ្ធិគ្រប់ គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ។

ទ្រព្យសកម្ម បំណុល មូលធន ចំណូល ចំណាយ និងលំហូរសាច់ប្រាក់អន្តរក្រុមហ៊ុនទាំងអស់ទាក់ទងនឹង ប្រតិបត្តិការរវាងសមាជិកនៃក្រុមហ៊ុនរួម ត្រូវបានលុបចោលនៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម។

ដើម្បីឱ្យស្របទៅតាមកម្មវត្ថុនៃរបាយការណ៍ហិរញ្ញវត្ថុរួម ក្នុងករណីចាំបាច់ណាមួយ របាយការណ៍ហិរញ្ញវត្ថុ នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ នឹងត្រូវបានធ្វើនិយ័តកម្ម ឱ្យស្របទៅតាមគោលនយោបាយគណនេយ្យរបស់ ក្រុមហ៊ុនរួម។

ការផ្លាស់ប្តូរលើការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនរួមនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមិនធ្វើឱ្យក្រុមហ៊ុនរួម បាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានទទួលស្គាល់ដូចប្រតិបត្តិការមូលធន។ តម្លៃយោង នៃភាគហ៊ុនរបស់ក្រុមហ៊ុនរួម និងអប្បភាគភាគហ៊ុនត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្តូរនៃភាគ ហ៊ុនពាក់ព័ន្ធនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ លម្អៀងណាមួយរវាងចំនួនដែលអប្បភាគភាគហ៊ុនធ្វើនិយ័តកម្ម និងតម្លៃសមស្របនៃទឹកប្រាក់ ដែលបានបង់ ឬទទួល គឺត្រូវបានទទួលស្គាល់ដោយផ្ទាល់ចូលក្នុងមូលធន និងទទួលស្គាល់នៅក្នុងម្ចាស់ភាគហ៊ុន នៃក្រុមហ៊ុន។

២.៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម (ត)

នៅពេលក្រុមហ៊ុនបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ប្រាក់ចំណេញ ឬខាតដែលទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងត្រូវបានគណនាដោយភាពលម្អៀងរវាង
(១) តម្លៃសមស្របសរុបនៃទឹកប្រាក់ដែលបានទទួល និងតម្លៃសមស្របនៃភាគហ៊ុនរក្សាទុកណាមួយ
(២) តម្លៃដុលពីមុននៃទ្រព្យសកម្ម (រួមទាំងកេរ្តិ៍ឈ្មោះ) និងបំណុលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ និងអប្បភាគភាគហ៊ុន។
ចំនួនទាំងអស់ដែលត្រូវបានទទួលស្គាល់ពីមុននៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ទាក់ទងនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ គឺត្រូវបានទទួលស្គាល់ដូចដែលក្រុមហ៊ុនរួម បានលក់ដោយផ្ទាល់នូវទ្រព្យសកម្ម និងបំណុល នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ (បែងចែកចូលក្នុងរបាយការណ៍ចំណេញ ឬខាត ឬផ្ទេរទៅចំណាត់ថ្នាក់ផ្សេងទៀតនៃ មូលធនដូចដែលបានបញ្ជាក់ ឬអនុញ្ញាតដោយ CIFRSs)។ តម្លៃសមស្របនៃការវិនិយោគណាមួយ ដែលរក្សានៅក្នុងអតីត ក្រុមហ៊ុនបុត្រសម្ព័ន្ធ នាកាលបរិច្ឆេទនៅពេលការគ្រប់គ្រងត្រូវបានបាត់បង់ គឺត្រូវបានទទួលស្គាល់ដូចជាតម្លៃសមស្របដែលទទួលស្គាល់ដំបូង សម្រាប់គណនេយ្យបន្តបន្ទាប់ទៀត តាម CIAS ៣៩ ឬតម្លៃទទួលស្គាល់ដំបូង នៃការវិនិយោគលើ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនចូលរួមភាគហ៊ុន។
នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ក្រុមហ៊ុន ការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានវាស់វែងតាមថ្លៃដើមដកឱនភាពតម្លៃដែលអាចប្រមូលបានវិញ ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

២.៤. ឆ្នាំសារពើពន្ធ

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុនចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

២.៥. រូបិយប័ណ្ណសម្រាប់ការវាស់វែង និងការបង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល ("រៀល")។ ប៉ុន្តែដោយក្រុមហ៊ុនរួម និង ក្រុមហ៊ុនបានប្រតិបត្តិអាជីវកម្ម និងរក្សាទុកបញ្ជីគណនេយ្យរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាម៉េរិក ("ដុល្លារអាម៉េរិក") គណៈគ្រប់គ្រងក្រុមហ៊ុនរួម និងក្រុមហ៊ុន បានកំណត់ប្រាក់ ដុល្លារអាម៉េរិកជារូបិយប័ណ្ណសម្រាប់ការវាស់វែង និងសម្រាប់ការបង្ហាញ ដោយរូបិយប័ណ្ណនេះវាឆ្លុះបញ្ចាំងពីព័ត៌មានសេដ្ឋកិច្ចនៃព្រឹត្តិការណ៍សំខាន់ៗ និងស្ថានភាពរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន។
របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ត្រូវបានបង្ហាញជាដុល្លារអាម៉េរិក ដែលជា រូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ។ តម្លៃទាំងអស់ ត្រូវបានបង្គត់ទៅជាខ្ទង់ដុល្លារអាម៉េរិកដែលនៅជិតបំផុត លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។
ប្រតិបត្តិការរូបិយប័ណ្ណបរទេសសកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាម៉េរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាម៉េរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។

ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ដែលជារូបិយប័ណ្ណបរទេស ត្រូវបាន ប្តូរទៅជាប្រាក់ដុល្លារអាម៉េរិក ដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍។ គណនីមិនមែនជារូបិយវត្ថុ ត្រូវបានវាស់វែងផ្អែកលើតម្លៃប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរដោយប្រើ អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ក៏ប៉ុន្តែ ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណបរទេស ដែលកើតឡើងពីការប្តូររូបិយប័ណ្ណនៃការវិនិយោគលើមូលធនទ្រព្យសកម្មហិរញ្ញវត្ថុដែលមានសម្រាប់លក់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ការបង្ហាញជាប្រាក់រៀល

ការប្តូរប្រាក់ដុល្លារអាម៉េរិកទៅជាពាន់រៀល (ពាន់រៀល) ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដោយ ប្រើប្រាស់អត្រាប្តូរប្រាក់ចុងគ្រា និងមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់ ដែលបានប្រកាស ដោយនិយ័តករគណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលដែលការប្តូរប្រាក់ដុល្លារអាម៉េរិកទៅជាពាន់រៀល (ពាន់រៀល) ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដោយ ប្រើប្រាស់អត្រាប្តូរប្រាក់ចុងគ្រា និងមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់ ដែលបានប្រកាស ដោយនិយ័តករគណនេយ្យ និងសវនកម្ម។

រួមបញ្ចូលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានប្តូរតាមអត្រាចុងគ្រានាការិយបរិច្ឆេទរាយការណ៍នីមួយៗ ដោយឡែកធាតុនៃប្រាក់ចំណូល និងចំណាយ ដែលបង្ហាញ ក្នុងរបាយការណ៍លទ្ធផលលម្អិតត្រូវបានប្តូរតាមអត្រាជាមធ្យមប្រចាំឆ្នាំ ដែលបានបញ្ចប់។ ភាពខុសគ្នានៃការផ្លាស់ប្តូរលទ្ធផលទាំងអស់ ត្រូវបានទទួលស្គាល់នៅក្នុង របាយការណ៍លទ្ធផលលម្អិត។ ការប្តូរបែបនេះ មិនគួរត្រូវបានបកស្រាយថា ដុល្លារអាម៉េរិក ដែលបានបង្ហាញ ឬត្រូវបាន ឬអាចត្រូវបានប្តូរទៅជាប្រាក់រៀលតាមអត្រានោះ ឬ អត្រា ផ្សេងទៀតនោះទេ។ តម្លៃទាំងអស់ជាប្រាក់រៀលត្រូវបានបង្គត់ទៅជាខ្ទង់ពាន់ (ពាន់រៀល) លើកលែងតែមានការចង្អុលបង្ហាញផ្សេងទៀត។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀលដោយផ្អែកលើអត្រាប្តូរប្រាក់អនុវត្តក្នុង ១ ដុល្លារអាម៉េរិក ដូចខាងក្រោម៖

	២០២៥	២០២៤
អត្រាចុងគ្រា	៤.០១៣	៤.០២៥
អត្រាមធ្យម	៤.០១១	៤.០៧១

៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

កំណត់សម្គាល់ខាងក្រោមផ្តល់នូវព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្តសង្ខេបក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក។ គោលនយោបាយទាំងនេះត្រូវបានអនុវត្តប្រកបដោយសង្គតិភាពទៅលើគ្រប់ការិយបរិច្ឆេទដែលបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

៣.១. ចំណាត់ថ្នាក់នៃផលិតផល

កិច្ចសន្យាធានារ៉ាប់រង គឺជាកិច្ចសន្យាដែលក្រុមហ៊ុនរួម និងក្រុមហ៊ុនបានទទួលយកនូវហានិភ័យធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងផ្ទាល់ និងការយល់ព្រម ទូទាត់ជូនក្រុមហ៊ុនធានារ៉ាប់រង ប្រសិនបើព្រឹត្តិការណ៍មិនប្រាកដប្រជានាពេលអនាគតណាមួយ **("ហេតុការណ៍ដែលបានធានា")** បានកើតឡើង។ ជាគោលការណ៍ទូទៅ ក្រុមហ៊ុនរួម និងក្រុមហ៊ុនបានកំណត់ហានិភ័យធានារ៉ាប់រងសំខាន់ៗ ដោយការវិភាគស៊ីជម្រៅនៃទិន្នន័យប្រវត្តិសាស្ត្រដែលមាន និងការអនុវត្តការវិភាគហានិភ័យនាពេលបច្ចុប្បន្ន។

កិច្ចសន្យាធានារ៉ាប់រង នឹងមានសុពលភាពរហូតដល់ផុតកំណត់រយៈពេលធានានៅក្នុងសន្យាធានារ៉ាប់រង ទោះបីជាហានិភ័យនៃកិច្ចសន្យាធានារ៉ាប់រង មានការថយចុះខ្លាំង លើកលែងតែ សិទ្ធិនិងកាតព្វកិច្ចដែលទទួលបានសំណងត្រូវបានរំសាយ ឬអស់សុពលភាព។

កិច្ចសន្យាធានារ៉ាប់រងរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ត្រូវបានបែងចែកជាពីរប្រភេទធំៗ ដោយផ្អែកលើរយៈពេលធានា និងប្រភេទហានិភ័យដែលត្រូវបានធានា មានដូចជា ធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងទូទៅ។

៣.២. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមាន កម្មវិធីកុំព្យូទ័រ ត្រូវបានកំណត់ដោយយកថ្លៃដើមដករំលស់បង្គរ និងឱនភាពនៃតម្លៃប្រសិនបើមាន។ អាជ្ញាបណ្ណកម្មវិធីកុំព្យូទ័រ ដែលបានទិញ ត្រូវបានធ្វើមូលធនកម្ម ដោយផ្អែកលើមូលដ្ឋានចំណាយដែលបានកើតឡើង ដើម្បីទិញកម្មវិធីកុំព្យូទ័រ ជាក់លាក់ និងការប្រើប្រាស់។

ចំណាយបន្ទាប់បន្សំលើកម្មវិធីកុំព្យូទ័រ ត្រូវបានធ្វើមូលធនកម្ម នៅពេលដែលកម្មវិធីនោះបានបង្កើនអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតដែលត្រូវចាត់ថ្នាក់ជាទ្រព្យសកម្ម។ រាល់ការចំណាយពាក់ពន្ធ័ផ្សេងៗ ត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតនៅពេលដែលកើតឡើង។

កម្មវិធីកុំព្យូទ័រ ត្រូវបានធ្វើរំលស់នៅក្នុង របាយការណ៍ចំណេញ ឬខាតដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាន គិតចាប់ពីពេលដែលអាចប្រើប្រាស់បាន។ អាយុកាលប៉ាន់ស្មាននៃការប្រើប្រាស់ នៃកម្មវិធី កុំព្យូទ័រ សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងអាយុកាលសរុបចំនួន ដប់ឆ្នាំ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ និងនិយ័តភាពប្រសិនបើសមស្រប។

៣.៣. ទ្រព្យ និងបរិក្ខារ

(i) ការទទួលស្គាល់និងការវាស់វែង

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើមដករំលស់បង្គរ និងឱនភាពតម្លៃបង្គរ ប្រសិនបើមាន។ ថ្លៃដើម ត្រូវបានរួមបញ្ចូលនូវចំណាយដែលកើតឡើងដោយផ្ទាល់សម្រាប់ការទិញនូវទ្រព្យសកម្ម និងចំណាយ ពាក់ព័ន្ធផ្សេងទៀត ដែលទ្រព្យសកម្មទាំងនោះ ប្រើប្រាស់ដើម្បីបំពេញការងារ និងមានគោលដៅច្បាស់លាស់។ តម្លៃយោងនៃទ្រព្យ និងបរិក្ខារ ត្រូវបានត្រួតពិនិត្យឡើងវិញ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃថាតើតម្លៃយោង ត្រូវបានគេកត់ត្រាលើសពីតម្លៃដែលអាចប្រមូលមកវិញដែរឬទេ ហើយក្នុងករណីដែលតម្លៃយោង លើសពីតម្លៃដែលអាចប្រមូលមកវិញនោះទ្រព្យសកម្មត្រូវកត់ត្រា ត្រឹមតម្លៃដែលអាចប្រមូលមកវិញ។

ប្រសិនបើ ប្រភេទនៃទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ត្រូវចាត់ទុកជាបណ្តុំ ផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ។

(ii) ចំណាយបន្ទបន្ទាប់

ចំណាយបន្ទបន្ទាប់ត្រូវបានធ្វើមូលធនកម្ម នៅពេលដែលមានភាពប្រាកដថាអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃចំណាយនោះ នឹងហូរចូលមកក្នុងក្រុមហ៊ុនរួមនិងក្រុមហ៊ុន។ រាល់ការចំណាយ ជាបន្ទបន្ទាប់ទៅលើការជួសជុល និងថែទាំ ត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

នៅពេលដែលទ្រព្យសកម្មត្រូវបានលក់ចេញ ថ្លៃដើម និងរំលស់បង្គររបស់វា ត្រូវបានជម្រះចេញពីបញ្ជី។ ចំណេញ ឬខាតពីការលក់ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។ ចំណេញ និងខាតពីការលក់ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបរវាងសាច់ប្រាក់ទទួលបាន ពីការលក់ ជាមួយនឹងតម្លៃយោង ហើយត្រូវទទួលស្គាល់ក្នុងចំណេញ ឬខាត ក្នុងខ្ទង់ចំណូលប្រតិបត្តិការផ្សេងៗ។ នៅពេលទ្រព្យសកម្មដែលបានវាយតម្លៃឡើងវិញត្រូវបានលក់ចេញ ចំនួនដែលរួមបញ្ចូលនៅក្នុងអតិរេកនៃការវាយតម្លៃឡើងវិញ ត្រូវបានផ្ទេរទៅប្រាក់ចំណេញរក្សាទុក។

(iii) រំលស់

រំលស់ត្រូវបានគណនាដើម្បីជម្រះថ្លៃដើមរបស់ទ្រព្យ និងបរិក្ខារ ដកតម្លៃសំណល់ប៉ាន់ស្មាន ដោយប្រើមូលដ្ឋានរំលស់ថយចុះ (លើកលែងតែ អគារ ដែលប្រើវិធីសាស្ត្ររំលស់ថេរ) ដែលប្រើតម្លៃចុះបញ្ជីសុទ្ធរបស់ទ្រព្យសកម្មនីមួយៗនាដើមការិយបរិច្ឆេទ តាមអត្រាប្រចាំឆ្នាំ ហើយជាទូទៅត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។ ទ្រព្យសកម្មកំពុងសាងសង់មិនត្រូវបានដករំលស់ទេ រហូតដល់ពេលបញ្ចប់ការសាងសង់ និងដាក់ឱ្យប្រើប្រាស់ក្នុងប្រតិបត្តិការអាជីវកម្ម។

អត្រារំលស់ប្រចាំឆ្នាំ នឹងវិធីសាស្ត្ររំលស់ មានដូចខាងក្រោម៖

ដី និងទ្រព្យសកម្មកំពុងសាងសង់		មិនដករំលស់
អគារការិយាល័យ	៥%	រំលស់ថេរ
កុំព្យូទ័រ និងបរិក្ខារការិយាល័យ	៥០%	រំលស់សមតុល្យថយចុះ
សង្ហារិម និងបរិក្ខារបំពាក់	២៥%	រំលស់សមតុល្យថយចុះ
យានយន្ត	២៥%	រំលស់សមតុល្យថយចុះ

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃសំណល់ ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវបានកែសម្រួលទៅតាមភាពសមស្រប។

៣.៤. ឱនភាពនៃតម្លៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនរួម និងក្រុមហ៊ុនពិនិត្យតម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដើម្បីកំណត់សូចនាករឱនភាពនៃតម្លៃ។ ក្នុងករណីដែលមានសូចនាករទាំងនោះកើតឡើង ចំនួននៃទ្រព្យសកម្មដែលអាចប្រមូលបានវិញនឹងត្រូវបានប៉ាន់ស្មាន។

សម្រាប់ការធ្វើតេស្តឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូច នៃទ្រព្យសកម្ម ដែលអាចបង្កើតលំហូរចូលសាច់ប្រាក់ពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរចូលសាច់ប្រាក់ពីទ្រព្យសកម្មដទៃទៀត ឬ ឯកត្តាបង្កើតសាច់ប្រាក់(“CGUs”)។

ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬ CGU គឺផ្អែកលើតម្លៃដែលធំជាង រវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយការលក់ចេញ។ តម្លៃប្រើប្រាស់ គឺអាស្រ័យលើការប៉ាន់ស្មាននូវលំហូរសាច់ប្រាក់នាពេលអនាគត អប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាអប្បហារមុនគិតពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ន នៃតម្លៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬ CGUs។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬ CGUs មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានបែងចែក ដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មក្នុង CGUs តាម មូលដ្ឋានសមាមាត្រ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានកត់ត្រាបញ្រ្ចាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឱ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះ មិនលើសពីតម្លៃយោងដែលត្រូវកំណត់ (ដករំលស់) ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ។

៣.៥. ឧបករណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនរួម និងក្រុមហ៊ុន បែងចែកទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទតាមប្រភេទមានដូចជា៖ ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របតាមចំណេញ ឬខាត (FVTPL) ទ្រព្យសកម្មហិរញ្ញវត្ថុកាន់កាប់រហូតដល់កាលកំណត់ ឥណទាន និងគណនីត្រូវទទួល និង ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់។

ក្រុមហ៊ុនរួម និងក្រុមហ៊ុន បែងចែកបំណុលហិរញ្ញវត្ថុអនិស្សន្ទ តាមប្រភេទបំណុលហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របតាមចំណេញ ឬខាត (FVTPL) និងបំណុលហិរញ្ញវត្ថុផ្សេងៗ។

(i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ និងអនិស្សន្ទបំណុលហិរញ្ញវត្ថុ - ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ការទទួលស្គាល់ដំបូងនៃឥណទាន និងគណនីត្រូវទទួល ទ្រព្យសកម្មហិរញ្ញវត្ថុកាន់កាប់រហូតដល់កាលកំណត់ និងទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ នៅកាលបរិច្ឆេទប្រតិបត្តិការបានចាប់ផ្តើម។ រាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដទៃទៀត ត្រូវបានទទួលស្គាល់ដំបូងនៅកាលបរិច្ឆេទជួញដូរ។

ក្រុមហ៊ុនរួម និងក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបាន សាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះ ផុតកំណត់ ឬក្រុមហ៊ុន បានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធភាពជាសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ ឬមិនបានផ្ទេរ ឬមិនរក្សានូវហានិភ័យ និងតម្លៃតបស្នងពី កម្មសិទ្ធភាពសារវន្ត និងមិនរក្សានូវការគ្រប់គ្រងទ្រព្យសកម្មដែលបានផ្ទេរ។ រាល់អត្ថប្រយោជន៍ដែលបានកើតឡើង ឬក៏រក្សាទុកដោយក្រុមហ៊ុនតាមរយៈទ្រព្យសកម្មហិរញ្ញវត្ថុដែលបានផ្ទេរចេញ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក។

ក្រុមហ៊ុនរួម និងក្រុមហ៊ុន ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុនៅពេលដែលកាតព្វកិច្ចកិច្ចសន្យាបានបញ្ចប់លុបចោល ឬ ផុតកាលកំណត់។

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ដែលចំនួននៅសល់សុទ្ធ ត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេលក្រុមហ៊ុនរួម និងក្រុមហ៊ុនមានសិទ្ធិពេញលេញតាមច្បាប់ដើម្បីទូទាត់និងមានបំណងធ្វើការទូទាត់លើមូលដ្ឋានកាត់កងឬពេលទ្រព្យសកម្មទទួលបាន និងទូទាត់បំណុលកើតឡើងនៅពេលដំណាលគ្នា។

(ii) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុអនិស្សន្ទ - ការវាស់វែង

ឥណទាន និងគណនីត្រូវទទួល

ឥណទាន និងគណនីត្រូវទទួល ត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃសមស្រប បូកបន្ថែមចំណាយប្រតិបត្តិការពាក់ព័ន្ធ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង វាត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព កាត់កងនឹងឱនភាពនៃតម្លៃ។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សមតុល្យសាច់ប្រាក់ និងប្រាក់បញ្ញើតាមតម្រូវការ ដែលមាន កាលកំណត់៣ខែ ឬតិចជាង គិតចាប់ពីកាលបរិច្ឆេទប្រតិបត្តិការ ដែលមានហានិភ័យនៃការផ្លាស់ប្តូរតម្លៃសមស្របតិចតួច ហើយក្រុមហ៊ុនរួម និងក្រុមហ៊ុនប្រើប្រាស់សម្រាប់ការចាត់ចែងការបំពេញកាតព្វកិច្ចទូទាត់រយៈពេលខ្លីរបស់ខ្លួន។

ទ្រព្យសកម្មហិរញ្ញវត្ថុកាន់កាប់រហូតដល់កាលកំណត់

ទ្រព្យសកម្មហិរញ្ញវត្ថុកាន់កាប់រហូតដល់កាលកំណត់ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការ។ បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុនេះ ត្រូវទទួលស្គាល់ដំបូងដោយការវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ទ្រព្យសកម្មហិរញ្ញវត្ថុនេះ រួមមានប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង តម្កល់នៅធនាគារពាណិជ្ជ ក្នុងព្រះរាជាណាចក្រកម្ពុជា និងការវិនិយោគលើសញ្ញាបណ្ណ ដែលមានកាលអវសានលើសពី ១២ខែ។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ គឺទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទ ដែលត្រូវបានចាត់ថ្នាក់នៅក្នុងប្រភេទដែលអាចលក់ អាចទិញ និងកាន់កាប់ដោយមិនមានកាលកំណត់ និងអាចលក់ក្នុងករណីក្រុមហ៊ុនរួម និងក្រុមហ៊ុនមានតម្រូវការសាច់ប្រាក់ ឬបម្រែបម្រួលនៃស្ថានភាពទីផ្សារ។
វិនិយោគទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ រួមមាន ការវិនិយោគមូលធនលើទីផ្សារមូលបត្រ ឬវិនិយោគមូលធនរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងស្រុក ដែលត្រូវទទួលស្គាល់ដំបូងតាមតម្លៃសមស្រប។
បន្ទាប់ពីពេលវាស់វែងដំបូង វិនិយោគទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ ត្រូវបានវាស់វែងជាបន្តបន្ទាប់នៅតម្លៃសមស្របដែល ចំណេញ ឬខាតមិនទាន់ទទួលស្គាល់ ត្រូវទទួលស្គាល់នៅក្នុង របាយការណ៍លទ្ធផលលម្អិតផ្សេងៗ ក្រោមគណនី "ចំណេញ ឬខាតលើតម្លៃទីផ្សារលើទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់" និងបង្ករក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ជាផ្នែកមួយដាច់ដោយឡែកនៃមូលធន រហូតដល់ពេលការវិនិយោគត្រូវបានឈប់ទទួលស្គាល់ ឬការវិនិយោគត្រូវបានកំណត់ថាមានឱនភាព ដែលនៅពេលនោះ ចំណេញ ឬខាតបង្គរដែលបានរាយការណ៍ក្នុងមូលធន នៅគ្រាមុន ត្រូវបានបញ្ចូលក្នុងរបាយការណ៍ចំណេញ ឬខាត។

បំណុលហិរញ្ញវត្ថុផ្សេងៗ

បំណុលហិរញ្ញវត្ថុផ្សេងៗ រួមមាន គណនីធានារ៉ាប់រងត្រូវទូទាត់ និងបំណុលផ្សេងៗ ដែលត្រូវទទួលស្គាល់ដំបូងតាមតម្លៃទីផ្សារដកថ្លៃដើមប្រតិបត្តិការផ្ទាល់។ បន្ទាប់ពីការទទួលស្គាល់ដំបូងនៃបំណុលនេះ ត្រូវបានវាស់វែងរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

(iii) ឱនភាពនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម និងទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ មិនរួមបញ្ចូលការវិនិយោគដែលទទួលស្គាល់តាមគណនេយ្យមូលធន ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទ វាយការណ៍នីមួយៗ ដើម្បីកំណត់សញ្ញាណឱនភាពនៃតម្លៃ។

ភស្តុតាងនានាដែលបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមាន៖

- ការខកខានទូទាត់សងរបស់កូនបំណុល
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនរួម និងក្រុមហ៊ុនមិនបានរំពឹងទុក
- សូចនាករដែលបញ្ជាក់ថាកូនបំណុលនឹងជួបការក្ស័យធន ឬមានការរៀបចំហិរញ្ញវត្ថុផ្សេងឡើងវិញ
- ការប្រែប្រួលជាអវិជ្ជមានចំពោះស្ថានភាពទូទាត់របស់កូនបំណុល ឬអ្នកបោះផ្សាយ
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រ ដោយសារតែវិបត្តិហិរញ្ញវត្ថុ ឬ
- ទិន្នន័យអង្កេត បានបង្ហាញថា មានការធ្លាក់ចុះនូវលំហូរសាច់ប្រាក់ដែលបានរំពឹងទុកពីក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម

ក្រុមហ៊ុនរួម និងក្រុមហ៊ុន ពិចារណាវាល់សញ្ញាណឱនភាពនៃតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងលើទ្រព្យសកម្មទោល និងជាក្រុម។ រាល់ទ្រព្យសកម្មទោលជាសារវន្ត ត្រូវបានវាយតម្លៃឱនភាពដាច់ដោយឡែក។ ទ្រព្យសកម្មហិរញ្ញវត្ថុទោលដែលមិនរកឃើញថា មានឱនភាពនៃតម្លៃក្នុងទម្រង់ដាច់ដោយឡែកទេ ត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃ ដែលបានកើតឡើងប៉ុន្តែមិនទាន់កំណត់នៅឡើយ។ ទ្រព្យសកម្មដែលមិនសារវន្តត្រូវបានវាយតម្លៃជាក្រុម។ ការវាយតម្លៃជាក្រុមត្រូវបានធ្វើឡើង ដោយរាប់បញ្ចូលនូវទ្រព្យដែលមានចរិតលក្ខណៈ ហានិភ័យស្រដៀងគ្នា។

ក្នុងការវាយតម្លៃឱនភាពនៃតម្លៃជាក្រុម ក្រុមហ៊ុនប្រើប្រាស់ព័ត៌មានពីមុនៗលើថេរវេលានៃការប្រមូលបាន និងចំនួននៃការខាតបង់កើតឡើង និងធ្វើការវិនិច្ឆ័យលើផ្នែកសេដ្ឋកិច្ចបច្ចុប្បន្ន និងលក្ខខណ្ឌឥណទានបច្ចុប្បន្ន ដូច្នេះការខាតបង់ជាក់ស្តែងអាចមានចំនួនច្រើនជាងឬតិចជាងចំនួនដែលបានកើតឡើងដោយយោងតាមនិន្នាការពីមុនៗមក។

ការខាតបង់លើឱនភាពនៃតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគណនាដោយផ្អែកលើភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង។ ការខាតបង់ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ដែលបង្ហាញក្នុងគណនីសំវិធានធន។ នៅពេលដែល ក្រុមហ៊ុនរួម យល់ថាមិនមានសង្ឃឹមក្នុងការទទួលបាននូវការទូទាត់សង ចំនួនដែលពាក់ព័ន្ធនឹងត្រូវបានលុបចោល។

ប្រសិនបើការខាតបង់លើឱនភាពនៃតម្លៃមានការថយចុះនៅពេលបន្ទាប់ ហើយការថយចុះអាចពាក់ព័ន្ធនឹងព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីឱនភាពនៃតម្លៃបានទទួលស្គាល់នោះ ការខាតបង់លើឱនភាព នៃតម្លៃដែលបានទទួលស្គាល់ពីមុន ត្រូវបានធ្វើការកត់ត្រាត្រឡប់ចូលក្នុងរបាយការណ៍ចំណេញ ឬខាត។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់

ឱនភាពនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ ត្រូវបានទទួលស្គាល់ដោយការធ្វើចំណាត់ថ្នាក់ឡើងវិញនៃការខាតបង្គរក្នុងទុនបម្រុងនៃបម្រែបម្រួលតម្លៃទីផ្សារ (របាយការណ៍លទ្ធផលលម្អិតផ្សេងៗ) ក្នុងរបាយការណ៍ចំណេញ ឬខាត។ ចំនួនដែលធ្វើចំណាត់ថ្នាក់ឡើងវិញ គឺជាចំនួនដែលខុសគ្នារវាងចំណាយនៃការទិញ (ការទូទាត់សងសុទ្ធនៃប្រាក់ដើម និងរំលស់) និងតម្លៃទីផ្សារបច្ចុប្បន្ន កាត់កងការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់នាគ្រាមុនក្នុងរបាយការណ៍ចំណេញ ឬខាត។ ឱនភាពនៃតម្លៃដែលទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតសម្រាប់ការវិនិយោគលើឧបករណ៍មូលធន ដែលបានចាត់ថ្នាក់ជាទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ គឺមិនត្រូវបានកត់ត្រាត្រឡប់ចូលក្នុងរបាយការណ៍ចំណេញ ឬខាតឡើយ។

៣.៦. គណនីធានារ៉ាប់រងត្រូវទទួល

គណនីធានារ៉ាប់រងត្រូវទទួល ត្រូវបានទទួលស្គាល់នៅពេលកំណត់ត្រូវទទួល និងវាស់វែងនៅពេលទទួលស្គាល់ដំបូង តាមតម្លៃសមស្របនៃចំនួនដែលត្រូវទទួលបាន។ បន្ទាប់ពីពេលទទួលស្គាល់ដំបូង គណនីធានារ៉ាប់រងត្រូវទទួល ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព កាត់កង និងឱនភាពនៃតម្លៃ។

៣.៧. ទ្រព្យសកម្មធានារ៉ាប់រងបន្ត

ទ្រព្យសកម្មធានារ៉ាប់រងបន្ត គឺជាសមតុល្យដែលត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត មានដូចជា បុព្វលាភធានារ៉ាប់រងមិនទាន់ទទួលស្គាល់ សំណងមិនទាន់ទូទាត់ និងសំណងកើតឡើងមិនទាន់រាយការណ៍ (IBNR)។ ចំនួនទឹកប្រាក់ដែលអាចប្រមូលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវបានប៉ាន់ប្រមាណស្របតាមចរិកលក្ខណៈនៃការទាមទារសំណង ឬសំណងដែលបានទូទាត់ទាក់ទងនឹង កិច្ចសន្យាធានារ៉ាប់រង និងកិច្ចសន្យាធានារ៉ាប់រងបន្ត លើសំណងកើតឡើងមិនទាន់រាយការណ៍ (IBNR) ដែលពាក់ព័ន្ធនាកាលបរិច្ឆេទរាយការណ៍ ព្រមទាំងចំណែកនៃបុព្វលាភធានារ៉ាប់រងមិនទាន់ទទួលស្គាល់។

ទ្រព្យសកម្មធានារ៉ាប់រងបន្ត ត្រូវបានពិនិត្យឡើងវិញចំពោះឱនភាពនៃតម្លៃ នាកាលបរិច្ឆេទ រាយការណ៍នីមួយៗ ថាតើទ្រព្យសកម្មធានារ៉ាប់រងបន្តមានឱនភាពនៃតម្លៃ ឬទេ។ ឱនភាពនៃតម្លៃលើទ្រព្យសកម្មធានារ៉ាប់រងបន្តកើតឡើង នៅពេលដែលមានភស្តុតាងពិតប្រាកដ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ដែលបានកើតឡើង បន្ទាប់ពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មធានារ៉ាប់រងបន្ត ដែលក្រុមហ៊ុនរួម និងក្រុមហ៊ុនអាចនឹងមិនទទួលបាននូវតម្លៃដែលនៅសល់ ដោយផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រង និងព្រឹត្តិការណ៍ដែលគួរឱ្យទុកចិត្តហើយមានផលប៉ះពាល់ដល់ការវាស់វែង លើតម្លៃដែលក្រុមហ៊ុនរួម និងក្រុមហ៊ុននឹងទទួលបានពីអ្នកធានារ៉ាប់រងបន្ត។ ឱនភាពនៃតម្លៃ ត្រូវបានបញ្ជីការនៅក្នុងរបាយការណ៍ចំណេញ ឬខាត។

៣.៨. ដើមទុន

ដើមទុន ត្រូវបានចាត់ថ្នាក់ជាគណនីមូលធន។ ថ្លៃដើមផ្ទាល់ដែលទាក់ទងនឹងការបោះផ្សាយ ភាគហ៊ុនធម្មតា ត្រូវបានទទួលស្គាល់ជាការកាត់កងពី គណនីមូលធនក្រោយកាត់កងពន្ធ។

៣.៩. បំណុលកិច្ចសន្យាធានារ៉ាប់រង

បំណុលកិច្ចសន្យាធានារ៉ាប់រងរួមមានសំណងមិនទាន់ទូទាត់ សំណងកើតឡើងមិនទាន់រាយការណ៍ ("IBNR") បុព្វលាភបម្រុងមិនទាន់ទទួលស្គាល់ និងសំវិធានធនសម្រាប់បុព្វលាភដែលមានការខាតបង់។ ក្រុមហ៊ុនរួម និងក្រុមហ៊ុនវាស់វែងសំណងមិនទាន់ទូទាត់ ដោយផ្អែកលើព័ត៌មានដែលផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រង។ IBNR តំណាងឱ្យទុនបម្រុងសម្រាប់ព្រឹត្តិការណ៍ធានារ៉ាប់រងដែលបាន កើតឡើង ដែលមិនទាន់បានរាយការណ៍ទៅក្រុមហ៊ុនរួម និងក្រុមហ៊ុន។ ការពន្យារពេលនៃទូទាត់សំណងអាចកើតមាន ទៅតាមការជូនដំណឹង និងការទូទាត់តាមប្រភេទនៃសំណង។ ដូច្នេះហើយ ទំហំសំណងជាក់លាក់ចុងក្រោយ គឺមិនអាចដឹងច្បាស់លាស់ នាកាលបរិច្ឆេទរាយការណ៍បានទេ។
បំណុលលើសំណង រួមមានសំណងមិនទាន់ទូទាត់ សំណងកើតឡើងមិនទាន់រាយការណ៍ ("IBNR") ត្រូវបានគណនា នាកាលបរិច្ឆេទរាយការណ៍ដោយប្រើវិធីសាស្ត្ររបស់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង តាមវិធីសាស្ត្រព្យាករណ៍ទំហំស្តង់ដាសំណងដោយផ្អែកលើទិន្នន័យជាក់ស្តែង និងការសន្មតបច្ចុប្បន្ន។ ការសន្មតទាំងនេះ អាចរាប់បញ្ចូលគម្លាតអវិជ្ជមាន ដើម្បីឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់ នៅក្នុងដំណើរការក្នុងការប៉ាន់ស្មាន។ បំណុលលើសំណង ត្រូវឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ចទូទាត់សំណងត្រូវបានហួសកាលកំណត់ បដិសេធ ឬលុបចោល។
បុព្វលាភបម្រុងមិនទាន់ទទួលស្គាល់ រួមមាន ចំណែកបុព្វលាភបានទទួល ឬត្រូវបានទទួល ដែលទាក់ទងនឹងហានិភ័យធានារ៉ាប់រងមិនទាន់ផុតកំណត់នៅកាលបរិច្ឆេទរាយការណ៍។ សំវិធានធនត្រូវបានទទួលស្គាល់ នៅពេលកិច្ចសន្យាធានារ៉ាប់រងមានប្រសិទ្ធិភាពចូលជាធរមាន និងត្រូវបានទទួលការទូទាត់ និងចាត់ទុកថាជាចំណូលបុព្វលាភក្នុងរយៈពេលនៃកិច្ចសន្យា ស្របតាមលក្ខខណ្ឌនៃការធានារ៉ាប់រងដែលបានផ្តល់ជូនក្រោមកិច្ចសន្យាធានារ៉ាប់រង។

ការធ្វើតេស្តភាពគ្រប់គ្រាន់នៃបំណុល

នាកាលបរិច្ឆេទរាយការណ៍នីមួយៗក្រុមហ៊ុនរួម និងក្រុមហ៊ុន ពិនិត្យមើលឡើងវិញពីហានិភ័យដែលមិនទាន់ផុតកំណត់របស់ពួកគេ ហើយធ្វើតេស្តពីភាពគ្រប់គ្រាន់នៃបំណុល ថាតើបំណុលកិច្ចសន្យាធានារ៉ាប់រងដែលបានទទួលស្គាល់ គឺមានភាពគ្រប់គ្រាន់ ដោយប្រើប្រាស់ការប៉ានស្មាននាពេលបច្ចុប្បន្ននៃលំហូរសាច់ប្រាក់អនាគត ស្ថិតក្រោមកិច្ចសន្យាធានារ៉ាប់រង។ ការធ្វើតេស្តនេះ កំណត់ថាតើមានការលើសពីសំណងរំពឹងទុក និងការចំណាយដែលពាក់ព័ន្ធ រួមទាំងចំណាយពន្យារ លើបុព្វលាភដែលមិនទទួលស្គាល់។
ការធ្វើតេស្តភាពគ្រប់គ្រាន់នៃបំណុលនេះ ត្រូវប៉ាន់ស្មាននាពេលបច្ចុប្បន្ននៃលំហូរសាច់ប្រាក់កិច្ចសន្យាអនាគត បន្ទាប់ពីគិតពីផលចំណូលវិនិយោគរំពឹងទុក លើទ្រព្យសកម្មទាក់ទងនឹងសំវិធានធនបច្ចេកទេសធានារ៉ាប់រងដែលពាក់ពន្ធ័ផ្សេងៗ។ ប្រសិនបើ ការប៉ាន់ស្មានទាំងនេះបង្ហាញថាតម្លៃយោងនៃបុព្វលាភរ៉ាប់រងមិនទាន់ទទួលស្គាល់ ដកចំណាយពន្យារដែលពាក់ព័ន្ធ មិនគ្រប់គ្រាន់ ចំនួនដែលមិនគ្រប់គ្រាន់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតតាមរយៈ ការទទួលសំវិធានធនសម្រាប់បុព្វលាភដែលមិនគ្រប់គ្រាន់។

៣.១០. គណនីធានារ៉ាប់រងត្រូវទូទាត់

គណនីធានារ៉ាប់រងត្រូវទូទាត់ គឺសំដៅលើបុព្វលាភដែលត្រូវទូទាត់សម្រាប់កិច្ចសន្យាធានារ៉ាប់រងបន្ត ដែលបានផ្ទេរចេញ និងការធានារ៉ាប់រងផ្សេងៗទៀតពីកិច្ចសន្យាធានារ៉ាប់រងដែលត្រូវទូទាត់ មានដូចជា សំណងធានារ៉ាប់រងកម្រៃជើងសា ពន្ធ និងប្រាក់វិភាគទាន ដែលត្រូវទូទាត់ទៅក្រុមហ៊ុនធានារ៉ាប់រង។

គណនីធានារ៉ាប់រងត្រូវទូទាត់ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្រប ហើយត្រូវបាន វាស់វែងជាបន្តបន្ទាប់តាមរំលស់ថ្លៃដើម។

ក្រុមហ៊ុនទទួលស្គាល់ការចំណាយលើកម្រៃជើងសាប្រាក់ចំណេញ ដែលត្រូវបង់ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង នៅពេលលទ្ធផលធានារ៉ាប់រងសម្រេចបានជាវិជ្ជមានសម្រាប់ឆ្នាំធានារ៉ាប់រងដែលបានកំណត់ ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងបន្ត។ ការគណនាចំណាយនេះ គិតបញ្ចូលទាំងកម្រៃគ្រប់គ្រង និងអត្រាកម្រៃជើងសា ដែលបានកំណត់តាម រយៈការចរចា និងចងក្រងជាឯកសារក្នុងលក្ខខណ្ឌនៃកិច្ចសន្យាដែលបានព្រមព្រៀង។ ដោយសារតែភាពមិនប្រាកដប្រជានៃអនុបាតការខាតបង់ដែលព្យាករណ៍ ដែលជាកត្តាជំរុញដ៏សំខាន់នៃកំណត់នូវកំរៃជើងសាប្រាក់ចំណេញ និងការទទួលស្គាល់ត្រូវបានពន្យារពេលរហូតដល់ការបញ្ចប់ការិយបរិច្ឆេទនៃការធានារ៉ាប់រង។

៣.១១. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់ ប្រសិនបើក្រុមហ៊ុនរួម និងក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬតាមកិច្ចសន្យាដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន ដែលអាចធ្វើការប៉ាន់ស្មានបានដោយពីភាពជាក់លាក់ ហើយមានភាពប្រហែលថា ការបាត់បង់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងតម្រូវឱ្យមានក្នុងការបំពេញនូវកាតព្វកិច្ចនេះ។

សំវិធានធន ត្រូវបានកំណត់ដោយអប្បហារលំហូរសាច់ប្រាក់ដែលរំពឹងថានឹងទទួលបាននាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណតាមពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ តម្លៃនៃអប្បហារ ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញវត្ថុ។

៣.១២. អត្ថប្រយោជន៍និយោជិត

(i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មរបស់និយោជិត បានបំពេញជូនក្រុមហ៊ុនរួម និងក្រុមហ៊ុន។ ចំនួនទឹកប្រាក់ដែលរំពឹងទុកថានឹងត្រូវចំណាយ ហើយត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ឬដោយប្រយោលនាពេលបច្ចុប្បន្ន ដែលត្រូវទូទាត់ ដែលជាលទ្ធផលនៃសេវាកម្មរបស់និយោជិតដែលបានបំពេញ ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មាន ។

(ii) ការកំណត់ផែនការភាគទាន - មូលនិធិសោធននិវត្តន៍

កាតព្វកិច្ចភាគទានប្រាក់សោធនរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ត្រូវកត់ត្រាជាចំណាយ នៅពេលដែលបុគ្គលិកបានបំពេញការងារជូនក្រុមហ៊ុនរួម និងក្រុមហ៊ុន និងត្រូវបានទទួលស្គាល់ជាចំណាយបុគ្គលិក នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ភាគទានបង់មុន ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម រហូតដល់សាច់ប្រាក់ត្រូវបានបង្វិលត្រឡប់មកវិញ ឬមានការកាត់បន្ថយពីការបង់ប្រាក់នាពេលអនាគត។

៣.១៣. ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល រួមមាន ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនរួម និងក្រុមហ៊ុន បានកំណត់ថា ការប្រាក់ និងការពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណូល រួមទាំងការកំណត់ពន្ធមិនច្បាស់លាស់ មិនស្របតាមនិយមន័យនៃពន្ធលើប្រាក់ចំណូលទេ ដូច្នេះវាត្រូវបានកត់ត្រាក្រោម CIAS ៣៧ ស្តីពី សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព។

(i) ពន្ធប្រចាំឆ្នាំ

ពន្ធប្រចាំឆ្នាំ រួមមានពន្ធត្រូវបង់ឬត្រូវទទួលរំពឹងទុក លើប្រាក់ចំណូលជាប់ពន្ធ ឬខាតជាប់ពន្ធសម្រាប់ការិយបរិច្ឆេទ និងការកែតម្រូវណាមួយចំពោះពន្ធត្រូវបង់ ឬត្រូវទទួល ទាក់ទងនឹងពន្ធក្នុងការិយបរិច្ឆេទមុនៗ។ ចំនួនប្រាក់ពន្ធត្រូវបង់ ឬត្រូវទទួល គឺជាចំនួនប៉ាន់ស្មានល្អបំផុតនៃចំនួនពន្ធត្រូវបង់ ឬត្រូវទទួលរំពឹងទុក ដែលឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជាទាក់ទងនឹងពន្ធលើប្រាក់ចំណូល ប្រសិនបើមាន។ ពន្ធប្រចាំឆ្នាំត្រូវបានវាស់វែងដោយប្រើអត្រាពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តជាអាទិ៍រួចមួយផ្នែកធំនាកាលបរិច្ឆេទរាយការណ៍។

(ii) ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្ដោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។
ពន្ធពន្យារ ជាទ្រព្យសកម្មដែលបានទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្ដោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្ដោះអាសន្ននោះបាន។ ពន្ធពន្យារត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។ ការកាត់បន្ថយនោះត្រូវកត់ត្រាត្រឡប់មកវិញនៅពេល ដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង។
ពន្ធពន្យារ ត្រូវបានកំណត់ដោយប្រើអត្រាពន្ធ ដែលរំពឹងថានិងប្រើលើភាពលម្អៀងជាបណ្ដោះអាសន្ននៅពេលដែលធ្វើការកែសម្រួលដោយផ្អែកលើច្បាប់ដែលបានអនុម័ត ឬបានអនុម័ត នាកាលបរិច្ឆេទរាយការណ៍។
ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងពីលទ្ធផលពន្ធ ដែលក្រុមហ៊ុនរួម និងក្រុមហ៊ុនរំពឹងថា នឹងបានទទួលមកវិញ ឬការកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលរបស់ខ្លួន នាកាលបរិច្ឆេទរាយការណ៍។ពន្ធពន្យារ ជាទ្រព្យសកម្ម និងបំណុល ត្រូវកាត់កងក្នុងករណីដែលលក្ខណៈវិនិច្ឆ័យមួយចំនួនត្រូវបានបំពេញ។

៣.១៤. បុព្វលាភធានារ៉ាប់រងដុល

បុព្វលាភធានារ៉ាប់រងដុល ដែលទាក់ទងនឹងកិច្ចសន្យាធានារ៉ាប់រងបន្ត ឆ្លុះបញ្ចាំងពីប្រតិបត្តិការអាជីវកម្មដែលកើតមានក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍។ បុព្វលាភធានារ៉ាប់រងដុល ត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនជើងសា នឹងមានការឯកភាពទាំងសងខាងតាមរយៈរបាយការណ៍គណនី (SoA) ឬឯកសារផ្សេងទៀតដែលមានលក្ខណៈស្រដៀង ដែលជាទូទៅ គឺនៅពេលដែលហានិភ័យចាប់ផ្ដើមធានាមានប្រសិទ្ធភាព។ បុព្វលាភធានារ៉ាប់រង ប្រចាំឆ្នាំ ពីកិច្ចសន្យាធានារ៉ាប់រងបន្តរួមមានបុព្វលាភធានារ៉ាប់រង និងការកែតម្រូវលើកិច្ចសន្យាធានារ៉ាប់រងបន្ត ដែលបានកើតឡើងក្នុងឆ្នាំមុន ប៉ុន្តែត្រូវបានបញ្ជាក់ទទួលយកនៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។
បុព្វលាភធានារ៉ាប់រងដុល ត្រូវបានបញ្ជីការតាមមូលដ្ឋានឆ្នាំធានា (Underwriting Year) ហើយសំវិធានធនត្រូវបានធ្វើឡើង សម្រាប់ចំណូលមិនទាន់ទទួលស្គាល់ ហៅថា “បុព្វលាភធានារ៉ាប់រង មិនទាន់ទទួលស្គាល់” ដែលជាចំណែកមួយនៃបុព្វលាភធានារ៉ាប់រង មានរយៈពេលមិនទាន់ផុតកំណត់នៃសុពលភាពធានារ៉ាប់រងនៅក្នុងការិយបរិច្ឆេទ។ ចំណូលបុព្វលាភធានារ៉ាប់រងសុទ្ធ គឺជាបុព្វលាភធានារ៉ាប់រងដុលកាត់កងជាមួយនឹង បុព្វលាភដែលបាន ផ្ទេរចេញទៅធានារ៉ាប់រងបន្ត និងបម្រែបម្រួលនៃបុព្វលាភ មិនទាន់ទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ។

៣.១៥. កម្រៃជើងសា កម្រៃជើងសាលើប្រាក់ចំណេញ និងកម្រៃជើងសាធានារ៉ាប់រងបន្ត

កម្រៃជើងសាខាងលើនេះ រួមមាន កម្រៃជើងសាដែលទទួលបាន ឬត្រូវទទួល ពីក្រុមហ៊ុនធានារ៉ាប់រងបន្ត និងក្រុមហ៊ុនជើងសា ដែលបានគណនាផ្អែកតាមអត្រាបុព្វលាភធានារ៉ាប់រងដុល និងចំណេញពីធានារ៉ាប់រង។ កម្រៃជើងសាខាងលើនេះ ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលកើតឡើង។

៣.១៦. ចំណូលហិរញ្ញវត្ថុ និងចំណូលផ្សេងៗ

ចំណូលហិរញ្ញវត្ថុ និងចំណូលផ្សេងៗ រួមមានចំណូលការប្រាក់ ចំណូលពីការជួល និងចំណូលភាគលាភ។ ចំណូលការប្រាក់ពីគណនីប្រាក់បញ្ញើតាមកាលកំណត់ពីធនាគារ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ ចំណូលភាគលាភ ត្រូវបានទទួលស្គាល់នៅពេលដែលសិទ្ធិទទួលបានការទូទាត់ភាគលាភបានកើតឡើង។ ក្រុមហ៊ុន ទទួលស្គាល់ប្រាក់ឈ្នួលដែលទទួលបានពីការជួល ជាចំណូល តាមមូលដ្ឋានថេរដោយយោងទៅតាមរយៈពេលជួល ជាផ្នែកនៃ ចំណូលផ្សេងៗ។

ក្រុមហ៊ុនរួម និងក្រុមហ៊ុនបានចាត់ទុក ការប្រាក់បានទទួលក្នុងការិយបរិច្ឆេទជាលំហូរសាច់ប្រាក់មកពីសកម្មភាពវិនិយោគនៅក្នុងរបាយការណ៍ លំហូរសាច់ប្រាក់។

៣.១៧. ការទទួលស្គាល់សំណងធានារ៉ាប់រង

សំណងធានារ៉ាប់រង រួមមាន សំណងទាំងអស់ដែលកើតឡើងក្នុងការិយបរិច្ឆេទ រួមបញ្ចូល សំណងបាន ឬមិនបានរាយការណ៍ ព្រមទាំងចំណាយលើដំណើរការដោះស្រាយសំណង ដែលកើតឡើងដោយផ្ទាល់ទាក់ទង ការទូទាត់សំណង កាត់កងតម្លៃពីការលក់កាកសំណល់ (Salvage) និងតម្លៃដែលអាចទាមទារបានមកវិញពីភាគីដែលទទួលខុសត្រូវ និងការកែតម្រូវចំពោះសំណងមិនទាន់ទូទាត់នៅការិយបរិច្ឆេទមុនៗ។

៣.១៨. ការបង្គត់តួលេខ

ចំនួនទឹកប្រាក់ជាប្រាក់ដុល្លារអាមេរិកទាំងអស់ ដែលត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក និងកំណត់សម្គាល់ ត្រូវបានបង្ហាញជាចំនួនគត់ជាប្រាក់ដុល្លារ
អាមេរិក។ ចំនួនទឹកប្រាក់ជាប្រាក់រៀលទាំងអស់ ដែលត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក និងកំណត់សម្គាល់ ត្រូវបានបង្គត់ត្រឹមខ្ទង់ពាន់រៀល លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

៤. ស្តង់ដាថ្មី និងការធ្វើវិសោធនកម្ម និងការបកស្រាយ

គោលនយោបាយគណនេយ្យ ដែលបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក គឺ ស្របគ្នា នឹងការិយបរិច្ឆេទមុន លើកលែងតែការអនុម័តដែលអាចអនុវត្តបាននៃវិសោធនកម្មទៅ CIFRSs ដូចខាងក្រោម ដែលមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥។ ក្រុមហ៊ុនរួម និងក្រុមហ៊ុន មិនទាន់បានអនុម័តស្តង់ដា ឬ វិសោធនកម្មផ្សេងទៀតដែលបានចេញប៉ុន្តែមិនទាន់មានប្រសិទ្ធភាព នៅឡើយទេ។

ការអនុម័តវិសោធនកម្មខាងក្រោមនេះមិនមានផលប៉ះពាល់ខ្លាំងទៅលើស្ថានភាពហិរញ្ញវត្ថុ និងសមត្ថភាពរបស់ក្រុមហ៊ុនឡើយ។

វិសោធនកម្មលើ CIAS ២១ - •កង្វះនៃការផ្លាស់ប្តូរ

៤.១. ស្តង់ដាដែលបានចេញផ្សាយប៉ុន្តែមិនទាន់មានប្រសិទ្ធភាព

ស្តង់ដា និងការបកស្រាយដែលត្រូវបានចេញ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព រហូតដល់កាលបរិច្ឆេទ នៃការចេញរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ត្រូវបានបង្ហាញដូចខាងក្រោម។ ក្រុមហ៊ុនរួម និងក្រុមហ៊ុន មានបំណងអនុវត្តស្តង់ដាទាំងនេះ ប្រសិនបើអាចអនុវត្តបាននៅពេលដែលស្តង់ដានោះមានប្រសិទ្ធភាព។

- វិសោធនកម្មលើស្តង់ដារគណនេយ្យ ស្តង់ដាគណនេយ្យអន្តរជាតិ ៩ និង ៧ ចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ, ចូលជាធរមាននា ឬ ក្រោយ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦
- វិសោធនកម្មលើស្តង់ដារគណនេយ្យ ស្តង់ដាគណនេយ្យអន្តរជាតិ ៩ និង ស្តង់ដាគណនេយ្យអន្តរជាតិ កិច្ចសន្យាយោងលើថាមពលអគ្គិសនីដែលអាស្រ័យលើធម្មជាតិ (ពីមុន កិច្ចព្រមព្រៀងក្នុងការទិញថាមពល), ចូលជាធរមាននា ឬ ក្រោយ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦
- ការកែលម្អទៅលើស្តង់ដារគណនេយ្យ ស្តង់ដាគណនេយ្យអន្តរជាតិ - លេខ ១១, ចូលជាធរមាននា ឬ ក្រោយ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦
- ស្តង់ដាគណនេយ្យអន្តរជាតិ ១៨ ការបង្ហាញ និងការលាតត្រដាងឧបករណ៍ហិរញ្ញវត្ថុ, ចូលជាធរមាន ចូលជា ធរមាននា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២៧
  ក្រុមហ៊ុនរួម និងក្រុមហ៊ុន មិនរំពឹងថាមានផលប៉ះពាល់ជាសារវន្តចំពោះព័ត៌មានដែលត្រូវបានលាតត្រដាងបច្ចុប្បន្ន នៅក្នុងកំណត់សម្គាល់នេះទេ ពីព្រោះតម្រូវការក្នុងការលាតត្រដាងព័ត៌មានជាសារវន្ត មិនមានការប្រែប្រួល។ ទោះជាយ៉ាងនេះក្តី វិធីសាស្ត្រនៃការប្រមូលផ្តុំព័ត៌មានអាចនឹងមានការប្រែប្រួល ទៅតាមគោលការណ៍នៃការប្រមូលផ្តុំ/ការបំបែកលម្អិត។
- ស្តង់ដាគណនេយ្យអន្តរជាតិ ១៩ ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលគ្មានគណនេយ្យភាពសាធារណៈ ការបង្ហាញ, ចូលជា ធរមាននា ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២៧
- វិសោធនកម្មលើ CIAS ២១ ការប្តូរទៅជារូបិយប័ណ្ណបង្ហាញអតិផរណាខ្ពស់, ចូលជាធរមាននា ឬ ក្រោយ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៧
- ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ កិច្ចសន្យាធានារ៉ាប់រង

នៅខែឧសភា ឆ្នាំ២០១៧ IASB បានចេញ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ កិច្ចសន្យាធានារ៉ាប់រង ដែលជាស្តង់ដាគណនេយ្យថ្មីដ៏ទូលំទូលាយសម្រាប់កិច្ចសន្យាធានារ៉ាប់រង ដែលគ្របដណ្តប់លើការទទួលស្គាល់ និងការវាស់វែង ការបង្ហាញ និងការលាតត្រដាង។ នៅពេលដែលមានប្រសិទ្ធភាព ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ នឹងជំនួស ស្តង់ដាគណនេយ្យអន្តរជាតិ ៤។ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ មានប្រសិទ្ធភាពសម្រាប់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចាប់ផ្តើមនា ឬ បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។ ប្រសិទ្ធភាពនៃ IFRSs ចេញដោយ IASB គឺត្រូវបានអនុវត្តដំណាលគ្នានៅក្នុងប្រទេសកម្ពុជាជាមួយសមូលភាព CIFRSs លុះត្រាតែមានការសម្រេចចិត្តផ្សេងទៀតពីនិយ័តករ។ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ អនុវត្តចំពោះកិច្ចសន្យាធានារ៉ាប់រងគ្រប់ប្រភេទ (ឧទាហរណ៍ អាយុជីវិត មិនមែនអាយុជីវិត ការធានារ៉ាប់រងដោយផ្ទាល់ និងការធានារ៉ាប់រងបន្ត) ដោយមិនគិតពីប្រភេទនៃក្រុមហ៊ុនដែលចេញឱ្យពួកគេ ក៏ដូចជាការធានាជាក់លាក់ និងឧបករណ៍ហិរញ្ញវត្ថុ ជាមួយនឹងការចូលរួមដោយឆន្ទានុសិទ្ធិដែលមានលក្ខណៈពិសេស។ការលើកលែងវិសាលភាពមួយចំនួននឹងត្រូវបានអនុវត្ត។
គោលបំណងរួមនៃ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ គឺដើម្បីផ្តល់នូវគំរូគណនេយ្យសម្រាប់កិច្ចសន្យាធានារ៉ាប់រងដែលមានប្រយោជន៍ជាង និងស្របសម្រាប់អ្នកធានារ៉ាប់រង។
ផ្ទុយទៅនឹងតម្រូវការនៅក្នុង ស្តង់ដាគណនេយ្យអន្តរជាតិ ៤ ដែលភាគច្រើនផ្អែកលើគោលនយោបាយគណនេយ្យ ក្នុងស្រុកពីមុន ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ ផ្តល់នូវគំរូដ៏ទូលំទូលាយសម្រាប់កិច្ចសន្យាធានារ៉ាប់រង ដែលគ្របដណ្តប់គ្រប់ទិដ្ឋភាពគណនេយ្យពាក់ព័ន្ធទាំងអស់។

- ម៉ូឌែលទូទៅនៃភាពគ្មានលទ្ធភាពសងសម្រាប់កិច្ចសន្យាជាច្រើន ដែលវាស់វែងបំណុលធានារ៉ាប់រងដោយប្រើ "building blocks" ចំនួន៤ (ម៉ូឌែលវាស់វែងទូទៅ/វិធីសាស្រ្ត Building Block)។
- ការសម្របខ្លួនជាក់លាក់មួយសម្រាប់កិច្ចសន្យា ដែលមានលក្ខណៈជាការចូលរួមដោយ ផ្ទាល់ (វិធីសាស្រ្តតម្លៃអថេរ)។
- វិធីសាស្រ្តសាមញ្ញ (វិធីសាស្រ្តបែងចែកបុព្វលាភ) ជាចម្បងសម្រាប់កិច្ចសន្យារយៈពេលខ្លី។

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ACAR បានចេញផ្សាយនូវសេចក្តីណែនាំដែលអនុញ្ញាតក្នុងការពន្យារពេលអនុវត្តលើ ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ និង ៩ សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ដែលមានប្រសិទ្ធភាពសម្រាប់របាយការណ៍ប្រចាំឆ្នាំ ចាប់ផ្តើមនា ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ACAR បានចេញផ្សាយនូវសេចក្តីជូនដំណឹងផ្សេងទៀត ក្នុងការពន្យារពេលបន្ថែមលើការអនុវត្តរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៨។ការពិនិត្យឡើងវិញអំពីភាពពាក់ព័ន្ធ និងផលប៉ះពាល់នៃការអនុម័តស្តង់ដានេះកំពុងបន្ត។

- ស្តង់ដាគណនេយ្យអន្តរជាតិ ៩ ឧបករណ៍ហិរញ្ញវត្ថុ

 ស្តង់ដាគណនេយ្យអន្តរជាតិ ៩ កំណត់អំពីតម្រូវការក្នុងការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាខ្លះសម្រាប់ការទិញ ឬលក់ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ស្តង់ដានេះបានជំនួសការណែនាំពីមុនរបស់ CIAS ៣៩ ឧបករណ៍ហិរញ្ញវត្ថុ ៖ ការទទួលស្គាល់ និងការវាស់វែង។ ស្តង់ដានេះមានសុពលភាពសម្រាប់របាយការណ៍ប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ជាមួយកការអនុវត្តមុនកាលកំណត់ ត្រូវបានអនុញ្ញាត និងត្រូវអនុវត្តគោលការណ៍សម្រាប់ការផ្លាស់ប្តូរនេះ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ក្រុមហ៊ុនទាំងឡាយណាដែលមានប្រតិបត្តិការអាជីវកម្មផ្តោតលើសកម្មភាពធានារ៉ាប់រង អាចមានជម្រើសពន្យារពេលអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិ ៩ រហូតដល់កាលបរិច្ឆេទអនុវត្ត ស្តង់ដាគណនេយ្យអន្តរជាតិ ១៧។

 ស្តង់ដាគណនេយ្យអន្តរជាតិ ៩ រួមបញ្ចូលនូវចំណាត់ថ្នាក់ថ្មី និងវិធីសាស្រ្តវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងពីទម្រង់ អាជីវកម្ម ដែលគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខណៈនៃលំហូរសាច់ប្រាក់របស់វា។ CIFR ៩ រួមបញ្ចូលប្រភេទ ចំណាត់ថ្នាក់សំខាន់ៗចំនួនបីសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ វាស់វែងតាមរំលស់ថ្លៃដើម តម្លៃសមស្របក្នុងរបាយការណ៍លទ្ធផលពេញលេញ (FVOCI) និងតម្លៃសមស្របក្នុងរបាយការណ៍ចំណេញ ឬខាត (FVTPL)។ ស្តង់ដានេះបានលុបបំបាត់ប្រភេទចំណាត់ថ្នាក់នៃទ្រព្យសកម្មដែលកាន់កាប់ដល់កាលកំណត់ ឥណទាន និងគណនីត្រូវទទួល និងទ្រព្យសកម្មសម្រាប់លក់ ដែលមានចែងក្នុង CIAS ៣៩។

 ស្តង់ដាគណនេយ្យអន្តរជាតិ ៩ ជំនួសគំរូ 'ការខាតបង់ដែលបានកើតឡើង' ក្នុង CIAS ៣៩ ជាមួយនឹងគំរូ 'ការខាតបង់ឥណទានរំពឹងទុក' (ECL) នាពេលអនាគត។ ស្តង់ដានេះតម្រូវឱ្យពិចារណាចំពោះការវិនិច្ឆ័យអំពីផលប៉ះពាល់នៃការកែប្រែកត្តាសេដ្ឋកិច្ចទៅលើ ECL ដែលត្រូវបានកំណត់តាមមូលដ្ឋានថ្លឹងប្រូបាប។

 គម្រូឱនភាពថ្មីត្រូវអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI លើកលែងតែការវិនិយោគឧបករណ៍មូលធន និងទ្រព្យសកម្មក្នុងកិច្ចសន្យា។

 ក្រោម ស្តង់ដាគណនេយ្យអន្តរជាតិ ៩ សំវិធានធនសម្រាប់ការខាតបង់ ត្រូវវាស់វែងតាម មូលដ្ឋានដូចខាងក្រោម៖

  - ECL ១២ខែ៖ ECL ទាំងនេះគឺជាលទ្ធផលបានមកពីព្រឹត្តិការណ៍នៃការខកខានសងប្រាក់ ក្នុងអំឡុងពេល១២ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និង
  - ECL ពេញមួយអាយុកាល៖ ECL ទាំងនេះគឺជាលទ្ធផលបានមកពីព្រឹត្តិការណ៍នៃការខកខានសងប្រាក់ ក្នុងអំឡុងពេលនៃអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ។

ECL ពេញមួយអាយុកាលត្រូវបានអនុវត្ត ប្រសិនបើមានកំណើនហានិភ័យឥណទានជាសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅកាលបរិច្ឆេទរាយការណ៍ ចាប់តាំងពីការទទួលស្គាល់ដំបូង ហើយប្រសិនបើមិនដូច្នោះទេ ត្រូវអនុវត្តតាមការវាស់វែង ECL ១២ខែ។ ក្រុមហ៊ុនអាចកំណត់ថាហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ មិនបានកើនឡើងជាសារវន្តប្រសិនបើទ្រព្យសកម្មមានកម្រិតហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍។ ទោះជាយ៉ាងណាក៏ដោយ ECL ពេញមួយអាយុកាល តែងតែអនុវត្តចំពោះគណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ ដោយមិនរួមបញ្ចូល សមាសធាតុហិរញ្ញវត្ថុសារវន្តទេ។

៥. ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យសំខាន់ៗ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ចំពោះការអនុវត្តគោលការណ៍គណនេយ្យ និងចំនួនទ្រព្យសកម្ម និងបំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាននិងការសន្មតមូលដ្ឋាន ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែសម្រួលចំពោះការប៉ាន់ស្មានត្រូវបានទទួលស្គាល់តាមមូលដ្ឋានសម្រាប់ពេលខាងមុខ។

<u>ការប៉ាន់ស្មាន</u>

ការវាយតម្លៃបំណុលកិច្ចសន្យាធានារ៉ាប់រង

ចំពោះកិច្ចសន្យាធានារ៉ាប់រង ការប៉ាន់ស្មានត្រូវបានធ្វើឡើងសម្រាប់ការចំណាយរំពឹងទុកចុងក្រោយ ក្នុងការទូទាត់សំណងធានារ៉ាប់រងនាកាលបរិច្ឆេទរាយការណ៍ និងការទូទាត់សំណងរំពឹងទុកចុងក្រោយដែលបានកើតឡើង ប៉ុន្តែមិនទាន់រាយការណ៍ (IBNR) នាកាលបរិច្ឆេទរាយការណ៍។ វាអាចចំណាយពេលយូរមុនពេលទូទាត់សំណងចុងក្រោយប្រកបដោយភាពច្បាស់លាស់ ហើយប្រភេទកិច្ចសន្យាធានារ៉ាប់រងខ្លះទៀត សំណង IBNR គឺជាផ្នែកដ៏ធំនៃបំណុលកិច្ចសន្យាធានារ៉ាប់រងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ការចំណាយចុងក្រោយលើសំណងមិនទាន់ទូទាត់ ត្រូវបានប៉ាន់ស្មានដោយប្រើប្រាស់វិធីសាស្ត្រព្យាករសំណងហានិភ័យស្តង់ដា។ ជាចម្បង វិធីសាស្ត្រទាំងនេះប្រើនិន្នាការនៃប្រវត្តិទូទាត់សំណង ជាមូលដ្ឋានសម្រាប់ប៉ាន់ស្មានចំនួនទឹកប្រាក់សំណងដែលត្រូវទូទាត់នាពេលអនាគត។ ការបង្កើតនិន្នាការនៃប្រវត្តិទូទាត់សំណង ត្រូវបានវិភាគជាចម្បងតាមឆ្នាំធានារ៉ាប់រង តាមប្រភេទអាជីវកម្ម និងភូមិសាស្ត្រ។ សំណងធំៗត្រូវបានដោះស្រាយដាច់ដោយឡែក ដោយប្រើប្រាស់ របាយការណ៍ឯករាជ្យរបស់អ្នកវាយតម្លៃការខូចខាត និងប្រវត្តិនៃគំរូតារាងសំណងធំៗ។

ការវិនិច្ឆ័យបែបគុណភាពផ្សេងទៀត ត្រូវការជាចាំបាច់ក្នុងការប៉ាន់ស្មាន ដោយសារនៅតែមានភាពមិនច្បាស់លាស់ជាសារវន្ត ដូចជាការផ្លាស់ប្តូរអត្រាអតិផរណា ស្ថានភាពសេដ្ឋកិច្ច លក្ខណៈទូទៅនៃការទាមទារសំណង អត្រាប្តូរប្រាក់បរទេស ការប្រែប្រួលលក្ខខណ្ឌច្បាប់ និង កិច្ចដំណើរការនៃប្រតិបត្តិការអាជីវកម្ម។

ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតស្រដៀងគ្នានេះ ក៏ត្រូវបានអនុវត្តក្នុងការវាយតម្លៃភាពគ្រប់គ្រាន់នៃសំវិធានធនសម្រាប់បុព្វលាភមិនទាន់ទទួលស្គាល់ផងដែរ។ ការវិនិច្ឆ័យក៏ត្រូវបានតម្រូវសម្រាប់ការកំណត់គំរូសេវា ដែលត្រូវផ្តល់ក្នុងកិច្ចសន្យាធានារ៉ាប់រង ដែលតម្រូវឱ្យដករំលស់បុព្វលាភមិនទាន់ទទួលស្គាល់ តាមមូលដ្ឋានមួយក្រៅពីវិធីសាស្ត្របែងចែកតាមពេលវេលា។

ការកំណត់បំណុលកិច្ចសន្យាធានារ៉ាប់រងគឺផ្អែកលើការសន្មត។ ការប៉ាន់ស្មានទាំងនេះត្រូវបានពិនិត្យឡើងវិញ និងកែសម្រួល (ប្រសិនបើ ចាំបាច់) ជារៀងរាល់ឆ្នាំ ដើម្បីបង្កើតបំណុលកិច្ចសន្យាធានារ៉ាប់រង ដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មានដ៏ល្អបំផុត។

ចំណាយកម្រៃជើងសាលើប្រាក់ចំណេញ

ដោយសារភាពមិនប្រាកដប្រជានៃការសន្មតអនុបាតការខាតបង់ និងមានផលប៉ះពាល់តិចតួចចំពោះប្រាក់ចំណេញ ការទទួលស្គាល់ត្រូវបានពន្យាររហូតដល់ពេលបញ្ចប់ឆ្នាំធានារ៉ាប់រង។

ការវិនិច្ឆ័យ

ព័ត៌មានអំពីការវិនិច្ឆ័យដែលបានធ្វើឡើង ក្នុងការអនុវត្តគោលការណ៍គណនេយ្យ គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យដូចខាងក្រោម លើកលែងតែចំពោះករណីដែលពាក់ព័ន្ធនឹងការប៉ាន់ស្មាន ដែលមានផលប៉ះពាល់ជាសារវន្តចំពោះចំនួនដែលបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ៖

ការចាត់ថ្នាក់នៃផលិតផល

ក្នុងគោលការណ៍ណែនាំទូទៅ ក្រុមហ៊ុនរួម និងក្រុមហ៊ុន បានកំណត់ថា តើវាមានហានិភ័យធានារ៉ាប់រងដ៏សំខាន់ ដោយប្រៀបធៀបអត្ថប្រយោជន៍ដែលនឹងត្រូវបង់ លើការកើតឡើងនៃព្រឹត្តិការណ៍ ធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដែលនឹងត្រូវបង់ ប្រសិនបើព្រឹត្តិការណ៍ធានារ៉ាប់រង មិនបានកើតឡើង។ ក្រុមហ៊ុនរួម និងក្រុមហ៊ុន បានកំណត់ថាគោលនយោបាយធានារ៉ាប់រង ដែលខ្លួនចេញមានហានិភ័យធានារ៉ាប់រងជាសារវន្ត ហេតុដូច្នេះហើយបានបំពេញតាមនិយមន័យ នៃកិច្ចសន្យា ធានារ៉ាប់រង ហើយគួរតែត្រូវយកមកគិតទុក។

តម្លៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ

គោលការណ៍គណនេយ្យ និងការលាតត្រដាងព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន តម្រូវឱ្យមានការវាស់វែងតាមតម្លៃសមស្របទាំងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ និងទ្រព្យសកម្មនិងបំណុលមិនមែនហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងត្រួតពិនិត្យលើទិន្នន័យសំខាន់ៗដែលមិនអាចសង្កេតបាន ហើយនិយ័តកម្មលើការវាស់វែងតម្លៃត្រូវបានត្រួតពិនិត្យជាប្រចាំ។ ប្រសិនបើជាព័ត៌មានពីភាគីទីបី ដូចជា សម្រង់តម្លៃពីឈ្មួញកណ្តាល ឬសេវាកម្មផ្តល់តម្លៃត្រូវបានប្រើសម្រាប់ការវាស់វែងតម្លៃសមស្រប នោះគណៈគ្រប់គ្រងនឹងវាយតម្លៃលើភស្តុតាងដែលបានមកពីភាគីទីបី ដើម្បីផ្តល់អំណះអំណាងដល់ការសន្និដ្ឋានថាតើការវាយតម្លៃនោះត្រឹមត្រូវទៅតាមតម្រូវការ នៃ ស្តង់ដាគណនេយ្យអន្តរជាតិ ជាមួយនឹងការពន្យារពេលអនុវត្ត ស្តង់ដាគណនេយ្យអន្តរជាតិ ១៧ និង ស្តង់ដាគណនេយ្យអន្តរជាតិ ៩ រួមទាំងលំដាប់ខុសៗគ្នានៃតម្លៃសមស្រប ដែលការវាយតម្លៃនេះបានចាត់ថ្នាក់។

ពេលវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុល ក្រុមហ៊ុនរួម និងក្រុមហ៊ុនបានប្រើព័ត៌មានទីផ្សារដែលអាចសង្កេតបាន ភាគច្រើនតាមដែលអាចធ្វើបាន។ តម្លៃសមស្របត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នានៃលំដាប់តម្លៃសមស្រប ដោយយោងទៅលើទិន្នន័យដែលប្រើប្រាស់ក្នុងវិធីសាស្ត្រវាយតម្លៃ ដូចខាងក្រោម៖

- **កម្រិតទី១៖** តម្លៃដកស្រង់ (មិនទាន់មាននិយ័តកម្ម) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលប្រហាក់ប្រហែលគ្នា។
- **កម្រិតទី២៖** ធាតុចូលដទៃទៀតក្រៅពីតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី១ ដែលអាចធ្វើការសង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬមិនផ្ទាល់ (ឧទាហរណ៍កើតចេញពីតម្លៃ)។
- **កម្រិតទី៣៖** ធាតុចូលនៃទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុចូលមិនអាចសង្កេតបាន)។

ប្រសិនបើធាតុចូលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល ដែលត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នានៃលំដាប់តម្លៃសមស្រប នោះការវាស់វែងតម្លៃសមស្របត្រូវបានចាត់ថ្នាក់ជារួមក្នុងកម្រិតលំដាប់តម្លៃសមស្របតែមួយ ជាធាតុចូលកម្រិតទាបបំផុតដែលមានលក្ខណៈជាសារវន្តសម្រាប់ការវាស់វែងទាំងមូល។

ក្រុមហ៊ុនរួម និងក្រុមហ៊ុនទទួលស្គាល់ការផ្ទេរផ្សេងៗ រវាងកម្រិតនៃលំដាប់តម្លៃសមស្របនាចុងការិយបរិច្ឆេទរាយការណ៍ ដែលមានប្រតិបត្តិការផ្លាស់ប្តូរនោះបានកើតឡើង។

ព័ត៌មានពីការសន្មតដែលបានធ្វើឡើងក្នុងការវាស់វែងតម្លៃសមស្របត្រូវបានរួមបញ្ចូលនៅក្នុងកំណត់សម្គាល់ ៣១ ស្តីពី ការគ្រប់គ្រងតម្លៃសមស្រប។

៦. ប្រាក់តម្កល់ធានាអាជីវកម្ម

ប្រាក់តម្កល់ធានាអាជីវកម្ម ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្ថិតក្រោមគណនីរបស់និយ័តករធានារ៉ាប់រងកម្ពុជា (IRC) ដោយអនុលោមតាមប្រកាសលេខ ០៦១ ស្តីពី កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ដែលចេញដោយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រាក់តម្កល់ស្មើនឹង ១០% នៃដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុន ដែលមិនទទួលបានការប្រាក់ ហើយនឹងបង្វិលសងវិញនៅពេល ក្រុមហ៊ុន បញ្ឈប់ដំណើរការនៅក្នុងប្រទេសកម្ពុជា។

ចំពោះក្រុមហ៊ុនបុត្រសម្ព័ន្ធ ប្រាក់តម្កល់ធានាអាជីវកម្មមានចំនួនស្មើនឹង ១០.០០០ ដុល្លារអាម៉េរិក ដែលតម្រូវទៅតាមប្រកាសលេខ ០៦០ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ដែលចេញដោយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៧. ទ្រព្យសកម្មអរូបី

	២០២៥	*២០២៤*
	ដុល្លារអាម៉េរិក	*ដុល្លារអាម៉េរិក*
ក្រុមហ៊ុនរួម		
ថ្លៃដើម		
គិតត្រឹមថ្ងៃទី១ ខែមករា	៨៥.៥៦១	៨១.៣០០
ទិញបន្ថែម	-	៤.២៦១
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៨៥.៥៦១**	**៨៥.៥៦១**
រំលស់បង្គរ		
គិតត្រឹមថ្ងៃទី១ ខែមករា	៥៣.០៤៣	៤៤.៧៥៥
រំលស់ក្នុងគ្រា *(កំណត់សម្គាល់លេខ ២៧)*	៨.៤៦៧	៨.២៨៨
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៦១.៥១០**	**៥៣.០៤៣**
តម្លៃយោងសុទ្ធ	**២៤.០៥១**	**៣២.៥១៨**
សមមូលពាន់រៀល	**៩៦.៥១៧**	**១៣០.៨៨៥**

	២០២៥	*២០២៤*
	ដុល្លារអាម៉េរិក	*ដុល្លារអាម៉េរិក*
ក្រុមហ៊ុន		
ថ្លៃដើម		
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៨១.៣០០**	**៨១.៣០០**
រំលស់បង្គរ		
គិតត្រឹមថ្ងៃទី១ ខែមករា	៥២.៨៨៥	៤៤.៧៥៥
រំលស់ក្នុងគ្រា *(កំណត់សម្គាល់លេខ ២៧)*	៨.០៤០	៨.១៣០
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៦០.៩២៥**	**៥២.៨៨៥**
តម្លៃយោងសុទ្ធ	**២០.៣៧៥**	**២៨.៤១៥**
សមមូលពាន់រៀល	**៨១.៧៦៥**	**១១៤.៣៧០**

៨. ទ្រព្យ និងបរិក្ខារ

២០២៥	ដី	អគារការិយាល័យ	កុំព្យូទ័រ និងបរិក្ខារការិយាល័យ	សម្ភារៈ និង បរិក្ខារបំពាក់	យានយន្ត	ទ្រព្យសកម្មកំពុងសាងសង់	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ក្រុមហ៊ុនរួម							
ថ្លៃដើម							
គិតត្រឹមថ្ងៃទី១ ខែមករា	៥.៩៩២.៦២៤	២៨៤.៥៦៨	១៥៨.៥០៨	៣៣.៥១៨	៤៨៥.០៧៥	-	៦.៩៥៤.២៩៣
ទិញបន្ថែម	-	-	១៥.០៤១	៩៨៧	៦១.៩៩០	២.៩៩៧.៩៣៧	៣.០៧៥.៩៥៥
ការកាត់ចេញទ្រព្យសកម្ម	-	-	(២៦.០០៨)	(២.០៣៥)	-	-	(២៨.០៤៣)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៥.៩៩២.៦២៤**	**២៨៤.៥៦៨**	**១៤៧.៥៤១**	**៣២.៤៧០**	**៥៤៧.០៦៥**	**២.៩៩៧.៩៣៧**	**១០.០០២.២០៥**
រំលស់បង្គរ							
គិតត្រឹមថ្ងៃទី១ ខែមករា	-	១៦៧.២៣៨	៩៧.០៦១	២១.៦៩០	៣២៧.៨១៥	-	៦១៣.៨០៤
រំលស់ក្នុងគ្រា *(កំណត់សម្គាល់លេខ ២៧)*	-	១៤.០៧២	៣១.៩១០	២.៨៤៥	៤៨.៤៥១	-	៩៧.២៧៨
ការកាត់ចេញទ្រព្យសកម្ម	-	-	(២៥.៩៦៦)	(១.៨៩១)	-	-	(២៧.៨៥៧)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	-	**១៨១.៣១០**	**១០៣.០០៥**	**២២.៦៤៤**	**៣៧៦.២៦៦**	-	**៦៨៣.២២៥**
តម្លៃយោងសុទ្ធ	**៥.៩៩២.៦២៤**	**១០៣.២៥៨**	**៤៤.៥៣៦**	**៩.៨២៦**	**១៧០.៧៩៩**	**២.៩៩៧.៩៣៧**	**៩.៣១៨.៩៨០**
សមមូលពាន់រៀល	**២៤.០៤៨.៤១៦**	**៤១៤.៣៧៤**	**១៧៨.៧២៣**	**៣៩.៤៣២**	**៦៨៥.៤១៧**	**១២.០៣០.៧២១**	**៣៧.៣៩៧.០៨៣**

៨. ទ្រព្យ និងបរិក្ខារ (ត)

២០២៥	ដី	អគារការិយាល័យ	កុំព្យូទ័រ និងបរិក្ខារការិយាល័យ	សង្ហារិម និង បរិក្ខារបំពាក់	យានយន្ត	ទ្រព្យសកម្មកំពុងសាងសង់	សរុប
	ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*
ក្រុមហ៊ុន							
ថ្លៃដើម							
គិតត្រឹមថ្ងៃទី១ ខែមករា	៥.៩៩២.៦២៨	២៨៤.៥៦៨	១៤៨.២៦១	៣៣.៥១៨	៤៨៥.០៧៥	-	៦.៩៤៤.០៥០
ទិញបន្ថែម	-	-	៨.២៣០	៨០០	៦១.៩៩០	២.៩៩៧.៩៣៧	៣.០៦៨.៩៥៧
ការកាត់ចេញទ្រព្យសកម្ម	-	-	(២៦.០៤៨)	(២.០៣៥)	-	-	(២៨.០៨៣)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៥.៩៩២.៦២៨**	**២៨៤.៥៦៨**	**១៣០.៤៤៣**	**៣២.២៨៣**	**៥៤៧.០៦៥**	**២.៩៩៧.៩៣៧**	**៩.៩៨៤.៩២៤**
រំលស់បង្គរ							
គិតត្រឹមថ្ងៃទី១ ខែមករា	-	១៦៧.២៣៨	៩៣.៩៤៥	២១.៦៩០	៣២៧.៨១៥	-	៦១០.៦៨៨
រំលស់ក្នុងគ្រា *(កំណត់សម្គាល់លេខ ២៧)*	-	១៤.០៧២	២៧.០៦៩	២.៨៣៦	៤៨.៤៥១	-	៩២.៤២៨
ការកាត់ចេញទ្រព្យសកម្ម	-	-	(២៥.៩៦៦)	(១.៨៩១)	-	-	(២៧.៨៥៧)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	-	**១៨១.៣១០**	**៩៥.០៤៨**	**២២.៦៣៥**	**៣៧៦.២៦៦**	-	**៦៧៥.២៥៩**
តម្លៃយោងសុទ្ធ	**៥.៩៩២.៦២៨**	**១០៣.២៥៨**	**៣៥.៣៩៥**	**៩.៦៤៨**	**១៧០.៧៩៩**	**២.៩៩៧.៩៣៧**	**៩.៣០៩.៦៦៥**
សមមូលពាន់រៀល	**២៤.០៤៨.៤១៦**	**៤១៤.៣៧៤**	**១៤២.០៤០**	**៣៨.៧១៧**	**៦៨៥.៤១៦**	**១២.០៣០.៧២៣**	**៣៧.៣៥៩.៦៨៦**

៨. ទ្រព្យ និងបរិក្ខារ (ត)

២០២៤	ដី	អគារការិយាល័យ	កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ	សង្ហារិម និង បរិក្ខារបំពាក់	យានយន្ត	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ក្រុមហ៊ុនរួម						
ថ្លៃដើម						
គិតត្រឹមថ្ងៃទី១ ខែមករា	៥.៩៩២.៦២៨	២៩៤.៦៦៨	៨០.៥៦៥	៣៣.៤១៨	៤៨៥.០៧៥	៦.៨៨៦.៣៥៤
ទិញបន្ថែម	-	-	៦៧.៩៤៣	-	-	៦៧.៩៤៣
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៥.៩៩២.៦២៨**	**២៩៤.៦៦៨**	**១៤៨.៥០៨**	**៣៣.៤១៨**	**៤៨៥.០៧៥**	**៦.៩៥៤.២៩៧**
រំលស់បង្គរ						
គិតត្រឹមថ្ងៃទី១ ខែមករា	-	១៥៣.១០០	៧៧.៩៨៩	១៧.៧៤៧	២៧៥.៣៥៥	៥២៤.១៩១
រំលស់ក្នុងគ្រា *(កំណត់សម្គាល់លេខ ២៧)*	-	២៤.២៣៨	៩.០៧២	៣.៨៤៣	៥២.៤៦០	៨៩.៦១៣
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	-	**១៧៧.៣៣៨**	**៨៧.០៦១**	**២១.៥៩០**	**៣២៧.៨១៥**	**៦១៣.៨០៤**
តម្លៃយោងសុទ្ធ	**៥.៩៩២.៦២៨**	**១១៧.៣៣០**	**៦១.៤៤៧**	**១១.៨២៨**	**១៥៧.២៦០**	**៦.៣៤០.៤៩៣**
សមមូលពាន់រៀល	**២៤.១២០.៣២៨**	**៤៧២.២៥៣**	**២៤៧.៣២៣**	**៤៧.៦០៨**	**៦៣២.៩៧២**	**២៥.៥២០.៤៨៤**

៨. ទ្រព្យ និងបរិក្ខារ (ត)

២០២៤	ដី	អគារការិយាល័យ	កុំព្យូទ័រ និងបរិក្ខារ ការិយាល័យ	សម្ភារៈ និង បរិក្ខាបំពាក់	យានយន្ត	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
ក្រុមហ៊ុន						
ថ្លៃដើម						
គិតត្រឹមថ្ងៃទី១ ខែមករា	៥.៩៩២.៦២៨	២៨៤.៥៦៨	៩០.៥៦៥	៣៣.៥១៤	៤៨៥.០៧៥	៦.៨៨៦.៣៥៥
ទិញបន្ថែម	-	-	៥៧.៦៥៦	-	-	៥៧.៦៥៦
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៥.៩៩២.៦២៨**	**២៨៤.៥៦៨**	**១៤៨.២២១**	**៣៣.៥១៤**	**៤៨៥.០៧៥**	**៦.៩៤៤.០៥០**
រំលស់បង្គរ						
គិតត្រឹមថ្ងៃទី១ ខែមករា	-	១៥៣.០១០	៧៧.៨៤៩	១៧.៧៤៧	២៧៥.៣៥៥	៥២៤.១៩១
រំលស់ក្នុងគ្រា *(កំណត់សម្គាល់លេខ ២៧)*	-	១៤.២២៨	១៥.៥៥៦	៣.៨៤៣	៥២.៤៦០	៨៦.៥៤៧
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	-	**១៦៧.២៣៨**	**៩៣.៨៥៥**	**២១.៥៩០**	**៣២៧.៨១៥**	**៦១០.៦៨៨**
តម្លៃយោងសុទ្ធ	**៥.៩៩២.៦២៨**	**១១៧.៣៣០**	**៥៤.៣១៦**	**១១.៩២៤**	**១៥៧.២៦០**	**៦.៣៣៣.៣៦២**
សមមូលពាន់រៀល	**២៤.១២០.៣២៨**	**៤៧២.២៥៣**	**២១៨.៦២១**	**៤៧.៦០៨**	**៦៣២.៨៧២**	**២៥.៤៩១.៧៨២**

៩. ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

គណនីនេះសំដៅលើការវិនិយោគមូលធនចំនួន ៥១% ស្មើនឹង ២៥៥.០០០ដុល្លារអាម៉េរិក លើក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា។ក្រុមហ៊ុនបុត្រសម្ព័ន្ធបានចុះបញ្ជីពាណិជ្ជកម្មលេខ Co.000២M/២០២៣ ចេញដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣។

ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនេះមានចំនួន ៥០០.០០០ ដុល្លារអាម៉េរិក ដោយបែងចែកជា ៥០០.០០០ ភាគហ៊ុន និងមានតម្លៃចារឹក ១ដុល្លារអាម៉េរិកក្នុងមួយភាគហ៊ុន។ សកម្មភាពអាជីវកម្មចម្បងរបស់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺផ្តល់សេវាលើការគ្រប់គ្រងសំណងធានារ៉ាប់រង និងសេវាផ្សេងៗទៀត ដែលបានអនុម័តដោយនិយ័តករធានារ៉ាប់រងកម្ពុជា ។

១០. ការវិនិយោគ

	កំណត់សម្គាល់	ក្រុមហ៊ុនរួម			
		២០២៥		២០២៤	
		ដុល្លារអាម៉េរិក	ពាន់រៀល	ដុល្លារអាម៉េរិក	ពាន់រៀល
មូលបត្រកម្មសិទ្ធិចុះបញ្ជីវាស់វែងតាមតម្លៃសមស្រប ក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ					
មូលបត្រអាចផ្ទេរបាន	(ក)	៣៨៤.៦៣៤	១.៥៤៣.៥៣៦	៣៤២.០៦១	១.៣៧៦.៧៩៦
ឧបករណ៍ហិរញ្ញវត្ថុមិនដាក់លក់លើទីផ្សារ វាស់វែងតាមរំលស់ថ្លៃដើម					
ប្រាក់បញ្ញើមានកាលកំណត់	(ខ)	២៣.២២៨.៣៩៦	៩៣.២១៥.៥៥៣	២៦.៧៧៧.៨៧២	១០៧.៧៨០.៩៣៤
សញ្ញាប័ណ្ណសាជីវកម្ម	(គ)	១៥៤.៣៦០	៦១៩.៤៤៧	១៤៩.៧៨៣	៦០២.៨៧៧
សញ្ញាប័ណ្ណរដ្ឋ	(ឃ)	២.៦៩៩.៦២១	១០.៨៣៣.៥៧៩	១.៩៩៥.២០១	៨.០៣០.៦៨៤
		២៦.០៨២.៣៧៧	**១០៤.៦៦៨.៥៧៩**	**២៨.៩២២.៨៥៦**	**១១៦.៤១៤.៤៩៥**
ការវិនិយោគសរុប		**២៦.៤៦៧.០១១**	**១០៦.២១២.១១៥**	**២៩.២៦៤.៩១៧**	**១១៧.៧៩១.២៩១**
រយៈពេលខ្លី		៨.៩១៦.៦៤៥	៣៥.៧៨២.៤៩៦	៨.១៤៤.៥៣២	៣២.៧៨១.៧៤១
រយៈពេលវែង		១៧.៥៥០.៣៦៦	៧០.៤២៩.៦១៩	២១.១២០.៣៨៥	៨៥.០០៩.៥៥០
		២៦.៤៦៧.០១១	**១០៦.២១២.១១៥**	**២៩.២៦៤.៩១៧**	**១១៧.៧៩១.២៩១**

១០. ការវិនិយោគ (ត)

	កំណត់សម្គាល់	ក្រុមហ៊ុន			
		២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មូលបត្រកម្មសិទ្ធិចុះបញ្ជីវាស់វែងតាមតម្លៃសមស្រប ក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ					
មូលបត្រអាចជួញដូរបាន	(ក)	៣៨៤.៦៣៤	១.៥៤៣.៥៣៦	៣៩២.០៦១	១.៣៧៦.៧៩៦
ឧបករណ៍ហិរញ្ញវត្ថុមិនដាក់លក់លើទីផ្សារ វាស់វែងតាមរំលស់ថ្លៃដើម					
ប្រាក់បញ្ញើមានកាលកំណត់	(ខ)	២៣.២២៨.៣៩៦	៩៣.២១៥.៥៥៣	២៦.៦៧៥.១៦១	១០៧.៣៦៧.៥២២
សញ្ញាប័ណ្ណសាជីវកម្ម	(គ)	១៥៤.៣៦០	៦១៩.៤៤៧	១៤៩.៧៨៣	៦០២.៨៧៧
សញ្ញាប័ណ្ណរដ្ឋ	(ឃ)	២.៦៩៩.៦២១	១០.៨៣៣.៥៧៩	១.៩៩៥.២០១	៨.០៣០.៦៨៤
		២៦.០៨២.៣៧៧	**១០៤.៦៦៨.៥៧៩**	**២៨.៨២០.១៤៥**	**១១៦.០០១.០៨៣**
ការវិនិយោគសរុប		**២៦.៤៦៧.០១១**	**១០៦.២១២.១១៥**	**២៩.២១២.២០៦**	**១១៧.៣៧៧.៨៧៩**
រយៈពេលខ្លី		៨.៩១៦.៦៤៥	៣៥.៧៨២.៤៩៦	៨.១៩៤.៥៣២	៣២.៧៨១.៧៤១
រយៈពេលវែង		១៧.៥៥០.៣៦៦	៧០.៤២៩.៦១៩	២១.០១៧.៦៧៤	៨៤.៥៩៦.១៣៨
		២៦.៤៦៧.០១១	**១០៦.២១២.១១៥**	**២៩.២១២.២០៦**	**១១៧.៣៧៧.៨៧៩**

(ក) មូលបត្រអាចជួញដូរបាន

	ក្រុមហ៊ុនរួម និងក្រុមហ៊ុន			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ថ្លៃដើម	៣៩២.០៦១	១.៣៧៦.៧៩៦	៣៦៦.៧៧៥	១.៤៩៨.២៧៦
ចំណេញ/(ខាត)តាមតម្លៃទីផ្សារ	៩២.៥៧៣	១៧០.៧៦០	(២៤.៧១៤)	(១០០.៦១១)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៤.០២០)	-	(២០.៨៦៩)
	៣៨៤.៦៣៤	**១.៥៤៣.៥៣៦**	**៣៩២.០៦១**	**១.៣៧៦.៧៩៦**

មូលបត្រអាចជួញដូរបានសំដៅលើមូលបត្រកម្មសិទ្ធិចំនួន ១១៩.១០០ ហ៊ុន នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) ដែលបានទិញនៅទីផ្សារបន្ទាប់។ នាចុងខែនីមួយៗ ក្រុមហ៊ុនរួម និងក្រុមហ៊ុន បានធ្វើការវាយតម្លៃ 'តាមតម្លៃទីផ្សារ' ទៅលើមូលបត្រកម្មសិទ្ធិដែលបានទិញ។

ក្រុមហ៊ុនរួម និងក្រុមហ៊ុន មិនមានបំណងកាន់កាប់មូលបត្រកម្មសិទ្ធិ ដើម្បីបង្កើតប្រាក់ចំណេញពីការប្រែប្រួលតម្លៃរយៈពេលខ្លី ឬចំណូលពីការលក់បន្ត។ ហេតុដូច្នេះហើយ ការវិនិយោគទៅលើមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័ត ក្រុងព្រះសីហនុ ("PAS") ត្រូវបានចាត់ថ្នាក់ថាជាទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់។

១០. ការវិនិយោគ (ត)

(ខ) ប្រាក់បញ្ញើមានកាលកំណត់

ប្រាក់បញ្ញើមានកាលកំណត់ជាមួយធនាគារពាណិជ្ជក្នុងប្រទេសកម្ពុជាមានរយៈពេលចន្លោះពី ១២ខែ ទៅ៦០ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ប្រាក់បញ្ញើ និងទទួលបានអត្រាការប្រាក់ក្នុងចន្លោះពី ៥,៧៥% ទៅ ៩,០០% (២០២៤ ៖ ៥,០០% ទៅ ៩,០០%) ក្នុងមួយឆ្នាំ។ ចំណូលការប្រាក់ពីប្រាក់បញ្ញើមានកាលកំណត់ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ មានចំនួន ១.៦០៩.៩៧២ ដុល្លារអាម៉េរិក ឬ ៦.៤៥៧.៥៩៨ ពាន់រៀល (២០២៤ ៖ ១.៧៤៦.៧៥៤ ដុល្លារអាម៉េរិក ឬ ៧.១១១.០៣៦ ពាន់រៀល)។ (កំណត់សម្គាល់លេខ ២៥)

(គ) សញ្ញាប័ណ្ណសាជីវកម្ម

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ក្រុមហ៊ុនបានទិញសញ្ញាប័ណ្ណចំនួន ៦.០០០ ប័ណ្ណ ដែលមានតម្លៃ ១០០.០០០ រៀលក្នុងមួយសន្លឹក ហើយមានតម្លៃស្មើនឹង ៦០០.០០០.០០០ រៀល (ប្រមាណ ១៤៥.៧៣៧ ដុល្លារអាម៉េរិក) ដែលបានបោះផ្សាយដោយក្រុមហ៊ុន ហ្គោលដិន ទ្រី។

សញ្ញាប័ណ្ណនេះទទួលបានការប្រាក់ ៧% ក្នុងមួយឆ្នាំ ដែលមានរយៈពេលប្រាំឆ្នាំ (២០២២ - ២០២៧) ចាប់ពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ ហើយត្រូវទូទាត់ការប្រាក់ប្រចាំឆមាស រៀងរាល់ថ្ងៃទី៦ ខែមិថុនា និងថ្ងៃទី៦ ខែធ្នូ នៃឆ្នាំនីមួយៗ។ ចំណូលការប្រាក់ពីសញ្ញាប័ណ្ណសាជីវកម្ម មានចំនួន ៨០.៥៧៤ ដុល្លារអាម៉េរិក ឬ ៣២៣.១៨២ ពាន់រៀល (២០២៤ ៖ ៤៥.៩៧១ ដុល្លារអាម៉េរិក ឬ ១៨៧.១៤៨ ពាន់រៀល)។ (កំណត់សម្គាល់លេខ ២៥)

(ឃ) សញ្ញាប័ណ្ណរដ្ឋ

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤ និងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ ក្រុមហ៊ុនបានទិញសញ្ញាប័ណ្ណចំនួន ៤.០០០ ប័ណ្ណក្នុងឆ្នាំ២០២៣ និងឆ្នាំ២០២៤ និងចំនួន ២.៨០០ ប័ណ្ណ ក្នុងឆ្នាំ២០២៥ ដែលមានតម្លៃ ១.០០០.០០០ រៀលក្នុងមួយសន្លឹកប័ណ្ណ មានតម្លៃស្មើនឹង ១០.៨០០.០០០.០០០ រៀល ដែលបោះផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សញ្ញាបណ្ណទាំងនេះមានរយៈពេល ៥ ឆ្នាំ និងមានអត្រាការប្រាក់ប្រចាំឆ្នាំ ៤,០០% ហើយការប្រាក់នឹងត្រូវទូទាត់ប្រចាំឆមាសតាមកាលវិភាគដូចខាងក្រោម៖

(i) ថ្ងៃទី២២ ខែមិថុនា និងថ្ងៃទី២២ ខែធ្នូ ជារៀងរាល់ឆ្នាំ

(ii) ថ្ងៃទី៣០ ខែមេសា និងថ្ងៃទី៣០ ខែតុលា ជារៀងរាល់ឆ្នាំ

(iii) ថ្ងៃទី២៣ ខែមិថុនា និងថ្ងៃទី២៣ ខែធ្នូ ជារៀងរាល់ឆ្នាំ

ចំណូលការប្រាក់ពីសញ្ញាប័ណ្ណរដ្ឋដែលបោះផ្សាយ ដោយរាជរដ្ឋាភិបាលកម្ពុជា មានចំនួន ១៣.៩៦៩ ដុល្លារអាម៉េរិក ឬ ៥៦.០៣០ ពាន់រៀល (២០២៤ ៖ ៩.៨៤៩ ដុល្លារ-អាម៉េរិក ឬ៤០.០៩៥ ពាន់រៀល)។ (កំណត់សម្គាល់លេខ ២៥)

១១. គណនីធានារ៉ាប់រងត្រូវទទួល

	ក្រុមហ៊ុនរួម			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កិច្ចសន្យាធានារ៉ាប់រងមិនមែនអាយុជីវិត				
បុព្វលាភធានារ៉ាប់រងដុលត្រូវទទួល	៥.២៩៣.៥៣៤	២១.២៤២.៩៥២	៤.៥០២.២៨៤	១៨.១២១.៦៩៣
គណនីធានារ៉ាប់រងបន្តត្រូវទទួល	៥៩១.០៨០	២.៣៧២.០០៤	៣.៥០៧.១២៨	១៤.១១៦.១៦០
គណនីធានារ៉ាប់រងត្រូវទទួលផ្សេងៗ	១.០០៧.៥៤៥	៤.០៤៣.២៧៨	៩០៧.៨៧៩	៣.៦៥៤.២១៣
	៦.៨៩២.១៥៩	**២៧.៦៥៨.២៣៤**	**៨.៩១៧.២៩១**	**៣៥.៨៩២.០៦៦**
កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត				
បុព្វលាភធានារ៉ាប់រងដុលត្រូវទទួល	២៣១.១៨៦	៩២៧.៧៤៩	២២៩.៣១៧	៩២៣.០០១
គណនីធានារ៉ាប់រងបន្តត្រូវទទួល	៨.៩៩៩	៣៦.១១៣	៩.១០៩	៣៦.៦៦៤
គណនីធានារ៉ាប់រងត្រូវទទួលផ្សេងៗ	១៦.២៩៩	៦៥.៤០៨	១៨.៤៤៤	៧៤.២៣៧
	២៥.៤៨៤	**១.០២៩.២៧០**	**២៥៦.៨៧០**	**១.០៣៣.៩០២**
	៧.១៤៨.៦៤៣	**២៨.៦៨៧.៥០៤**	**៩.១៧៤.១៦១**	**៣៦.៩២៥.៩៦៨**

	ក្រុមហ៊ុន			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កិច្ចសន្យាធានារ៉ាប់រងមិនមែនអាយុជីវិត				
បុព្វលាភធានារ៉ាប់រងដុលត្រូវទទួល	៥.២៦៨.១៦៥	២១.១៤១.១៤៧	៤.៥០២.២៨៤	១៨.១២១.៦៩៣
គណនីធានារ៉ាប់រងបន្តត្រូវទទួល	៥៩១.០៨០	២.៣៧២.០០៤	៣.៥០៧.១២៨	១៤.១១៦.១៦០
គណនីធានារ៉ាប់រងត្រូវទទួលផ្សេងៗ	១.០០៧.៥៤៥	៤.០៤៣.២៧៨	៩០៧.៨៧៩	៣.៦៥៤.២១៣
	៦.៨៦៦.៧៩០	**២៧.៥៥៦.៤២៩**	**៨.៩១៧.២៩១**	**៣៥.៨៩២.០៦៦**
កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត				
បុព្វលាភធានារ៉ាប់រងដុលត្រូវទទួល	២៣១.១៨៦	៩២៧.៧៤៩	២២៩.៣១៧	៩២៣.០០១
គណនីធានារ៉ាប់រងបន្តត្រូវទទួល	៨.៩៩៩	៣៦.១១៣	៩.១០៩	៣៦.៦៦៤
គណនីធានារ៉ាប់រងត្រូវទទួលផ្សេងៗ	១៦.២៩៨	៦៥.៤០៤	១៨.៤៤៤	៧៤.២៣៧
	២៥៦.៤៨៣	**១.០២៩.២៦៦**	**២៥៦.៨៧០**	**១.០៣៣.៩០២**
	៧.១២៣.២៧៣	**២៨.៥៨៥.៦៩៥**	**៩.១៧៤.១៦១**	**៣៦.៩២៥.៩៦៨**

១២. ទ្រព្យសកម្មធានារ៉ាប់រងបន្ត

	ក្រុមហ៊ុនរួម និងក្រុមហ៊ុន			
	២០២៥		*២០២៤*	
	ដុល្លារអាម៉េរិក	*ពាន់រៀល*	*ដុល្លារអាម៉េរិក*	*ពាន់រៀល*
កិច្ចសន្យាធានារ៉ាប់រងមិនមែនអាយុជីវិត				
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	១.៨៩៨.៧៧៤	៧.៦១៩.៧៨០	១.៨២៧.៣៨៦	៧.៣៥៥.២២៩
សំណងមិនទាន់ទូទាត់	៧៦១.០៥៨	៣.០៥៤.១២៦	១៥៥.១៣៨	៦២៤.៤៣០
សំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍	២៧៥.៧៧៩	១.១០៦.៧០១	៤១៧.៦០៥	១.៦៨០.៨៦០
	២.៩៣៥.៦១១	**១១.៧៨០.៦០៧**	**២.៤០០.១២៩**	**៩.៦៦០.៥១៩**
កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត				
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	២៨៣	១.១៣៦	៦៣៧	២.៥៦៤
សំណងដែលមិនទាន់ទូទាត់	៤.៣១៣	១៧.៣០៨	-	-
សំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍	១.៥៧៦	៦.៣២៤	១៨៤	៧៤១
ទុនបម្រុងក្នុងការវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល	២.៨៦៤	១១.៤៩៣	៦.១០២	២៤.៥៦០
	៩.០៣៦	**៣៦.២៦១**	**៦.៩២៣**	**២៧.៨៦៥**
	២.៩៤៤.៦៤៧	**១១.៨១៦.៨៦៨**	**២.៤០៧.០៥២**	**៩.៦៨៨.៣៨៤**
រយៈពេលខ្លី	២.៩៣៥.៦១១	១១.៧៨០.៦០៧	២.៤០០.១២៩	៩.៦៦០.៥១៩
រយៈពេលវែង	៩.០៣៦	៣៦.២៦១	៦.៩២៣	២៧.៨៦៥
	២.៩៤៤.៦៤៧	**១១.៨១៦.៨៦៨**	**២.៤០៧.០៥២**	**៩.៦៨៨.៣៨៤**

១៣. ទ្រព្យសកម្មផ្សេងៗ

	ក្រុមហ៊ុនរួម			
	២០២៥		*២០២៤*	
	ដុល្លារអាម៉េរិក	*ពាន់រៀល*	*ដុល្លារអាម៉េរិក*	*ពាន់រៀល*
ប្រាក់តម្កល់	១.១៩៩	៤.៨១២	១.១៩៩	៤.៨២៦
ចំណាយបង់មុន	៧៤.៤១៩	២៩៨.៦៤៣	៩.៩៥៥	៤០.០៦៩
គណនីត្រូវទទួលផ្សេងៗ	៧.៦៨៣	៣០.៨៣២	១៧.០៦៥	៦៨.៦៨៧
	៨៣.៣០១	**៣៣៤.២៨៧**	**២៨.២១៩**	**១១៣.៥៨២**
រយៈពេលខ្លី	៨២.១០២	៣២៩.៤៧៥	២៧.០២០	១០៨.៧៥៦
រយៈពេលវែង	១.១៩៩	៤.៨១២	១.១៩៩	៤.៨២៦
	៨៣.៣០១	**៣៣៤.២៨៧**	**២៨.២១៩**	**១១៣.៥៨២**

១៣.ទ្រព្យសកម្មផ្សេងៗ (ត)

	ក្រុមហ៊ុន			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	*ពាន់រៀល*	*ដុល្លារអាមេរិក*	*ពាន់រៀល*
ប្រាក់តម្កល់	១.១៩៩	៤.៨១២	១.១៩៩	៤.៨២៦
ចំណាយបង់មុន	៥៦.១៧៨	២២៥.៤៤២	៩.៩៥៥	៤០.០៦៩
គណនីត្រូវទទួលផ្សេងៗ	៨៩៨	៣.៦០៤	៨៩៨	៣.៦១៤
	៥៨.២៧៥	**២៣៣.៨៥៨**	**១២.០៥២**	**៤៨.៥០៩**
រយៈពេលខ្លី	៥៧.០៧៦	២២៩.០៤៦	១០.៨៥៣	៤៣.៦៨៣
រយៈពេលវែង	១.១៩៩	៤.៨១២	១.១៩៩	៤.៨២៦
	៥៨.២៧៥	**២៣៣.៨៥៨**	**១២.០៥២**	**៤៨.៥០៩**

១៤.សាច់ប្រាក់ និងសាច់ប្រាក់សមមូល

	២០២៥		២០២៤	
	ដុល្លារអាមេរិក	*ពាន់រៀល*	*ដុល្លារអាមេរិក*	*ពាន់រៀល*
ក្រុមហ៊ុនរួម				
សាច់ប្រាក់ក្នុងដៃ	១.០០០	៤.០៩៣	១.០០០	៤.០២៥
គណនីចរន្ត និងគណនីសន្សំ	៥១០.៨៧៤	២.០៥០.១៣៧	៨៩៧.៧៤៣	៣.៦១៣.៤១៦
	៥១១.៨៧៤	**២.០៥៤.១៥០**	**៨៩៨.៧៤៣**	**៣.៦១៧.៤៤១**
ក្រុមហ៊ុន				
សាច់ប្រាក់ក្នុងដៃ	១.០០០	៤.០៩៣	១.០០០	៤.០២៥
គណនីចរន្ត និងគណនីសន្សំ	៤៧៩.៦៩១	១.៩២៥.០០០	៧៦៩.៤៨១	៣.០៩៧.៩៦១
	៤៨០.៦៩១	**១.៩២៩.០៩៣**	**៧៧០.៤៨១**	**៣.១០១.៩៨៦**

គណនីចរន្ត និងគណនីសន្សំមានការប្រាក់ក្នុងចន្លោះពី 0% ទៅ ១,៥% ក្នុងមួយឆ្នាំ (២០២៤ ៖ 0% ទៅ 0,៥% ក្នុងមួយឆ្នាំ)។

១៥.ដើមទុន

	ក្រុមហ៊ុនរួម			
	២០២៥		២០២៤	
	ដុល្លារអាម៉េរិក	ពាន់រៀល	ដុល្លារអាម៉េរិក	ពាន់រៀល
បានចុះបញ្ជី បោះផ្សាយ និងមិនទាន់ទូទាត់ ៥៦០.០០០ ភាគហ៊ុន មានតម្លៃចារឹក ២៥ ដុល្លារអាម៉េរិក ក្នុងមួយហ៊ុន	**១៤.០០០.០០០**	**៥៦.០០០.០០០**	**១៤.០០០.០០០**	**៥៦.០០០.០០០**

ភាគទុនិករបស់ក្រុមហ៊ុនរួមនិងក្រុមហ៊ុន និងអត្ថប្រយោជន៍របស់ភាគទុនិក មានដូចខាងក្រោម៖

	២០២៥		
	ចំនួន ភាគហ៊ុន	ចំនួនទឹកប្រាក់ ដុល្លារអាម៉េរិក	%
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (រាជរដ្ឋាភិបាលកម្ពុជា) (MEF)	៣៣៧.១៦៨	៨.៤២៩.២០០	៦០,២១
ក្រុមហ៊ុន Asia Insurance International (Holding) Co.. Ltd (AII)	៩៦.៤៤៤	២.៤១១.១០០	១៧,២២
ក្រុមហ៊ុន ហ្វតតេ អ៊ិនវេសម៉ិន ហូលឌីង ឯ.ក	១៤.៣៨៨	៣៥៩.៧០០	២,៥៧
ក្រុមហ៊ុន សុវណ្ណភូមិ ឡាយហ្វ៍ អ៊ីស្សួរិនស៍ ភីអិលស៊ី	៥៦.០០០	១.៤០០.០០០	១០,០០
ក្រុមហ៊ុន Thai Reinsurance Public Company Limited	៥៦.០០០	១.៤០០.០០០	១០,០០
	៥៦០.០០០	**១៤.០០០.០០០**	**១០០**
សមមូលពាន់រៀល		**៥៦.០០០.០០០**	

	២០២៤		
	ចំនួន ភាគហ៊ុន	ចំនួនទឹកប្រាក់ ដុល្លារអាម៉េរិក	%
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (រាជរដ្ឋាភិបាលកម្ពុជា) (MEF)	៣៣៧.១៦៨	៨.៤២៩.២០០	៦០,២១
ក្រុមហ៊ុន Asia Insurance International (Holding) Co.. Ltd (AII)	៩៦.៤៤៤	២.៤១១.១០០	១៧,២២
ក្រុមហ៊ុន ហ្វតតេ អ៊ិនវេសម៉ិន ហូលឌីង ឯ.ក	៩៦.៤៤៤	២.៤១១.១០០	១៧,២២
ក្រុមហ៊ុន សុវណ្ណភូមិ ឡាយហ្វ៍ អ៊ីស្សួរិនស៍ ភីអិលស៊ី	២៩.៩៤៤	៧៤៨.៦០០	៥,៣៥
	៥៦០.០០០	**១៤.០០០.០០០**	**១០០**
សមមូលពាន់រៀល		**៥៦.០០០.០០០**	

១៦.ទុនបម្រុង

គោលការណ៍ភាគលាភត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ និងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ ដោយយោងតាមមូលដ្ឋានដូចខាងក្រោម៖

ក) តាមឆន្ទានុសិទ្ធិនៃសំណើរបស់ក្រុមប្រឹក្សាភិបាល ដែលត្រូវមានការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុមហ៊ុន អាចបែងចែកជាអតិបរមា ៧០% នៃប្រាក់ចំណូលដែលអាចបែងចែកបានជូនភាគទុនិកធម្មតា។

ខ) ប្រាក់ចំណូលដែលអាចបែងចែកបាន ត្រូវបានកំណត់ថាជាប្រាក់ចំណូលសុទ្ធក្រោយបង់ពន្ធ និងត្រូវកាត់កង ដូចខាងក្រោម៖

- ទូទាត់លទ្ធផលខាតក្នុងឆ្នាំមុនៗ (ប្រសិនបើមាន)
- ផ្តល់ប្រាក់រង្វាន់ជូនគណៈគ្រប់គ្រង និងនិយោជិត ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល
- បែងចែក ១០% សម្រាប់ទុនបម្រុងគ្រោះមហន្តរាយ
- បែងចែក ២% ឬអតិបរមា ៥០.០០០ ដុល្លារអាមេរិក សម្រាប់ការបង្កើត និងបង្គរមូលនិធិសង្គម និងការអភិវឌ្ឍ។

	ក្រុមហ៊ុនរួម និងក្រុមហ៊ុន			
	ទុនបម្រុងសម្រាប់គ្រោះមហន្តរាយ	*ទុនបម្រុងសម្រាប់សង្គម និងការអភិវឌ្ឍ*	*សរុប*	
	ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ពាន់រៀល*
២០២៥				
គិតត្រឹមថ្ងៃទី១ ខែមករា	៥.៨៤៤.៩៧៥	១២៣.៩៨៨	៥.៩៦៨.៩៦៣	២៤.០៧៣.២៨៤
ផ្ទេរពីប្រាក់ចំណេញរក្សាទុក	៨៨.២៩១	១៧.៦៥៨	១០៥.៩៤៩	៤២៥.១៧៤
ការប្រើប្រាស់ក្នុងគ្រា	-	(៣៣.៧៩៥)	(៣៣.៧៩៥)	(១៣៥.៥៥២)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៥.៩៣៣.២៦៦**	**១០៧.៨៥១**	**៦.០៤១.១១៧**	**២៤.៣៦២.៩០៦**
២០២៤				
គិតត្រឹមទី១ ខែមករា	៥.៧០៧.៧៥៤	១២៤.១៤០	៥.៨៣១.៨៩៤	២៣.៥២២.៨៥០
ផ្ទេរពីប្រាក់ចំណេញរក្សាទុក	១៣៧.២២១	២៧.៤៤៦	១៦៤.៦៦៧	៦៦២.៧៨៥
ការប្រើប្រាស់ក្នុងគ្រា	-	(២៧.៥៩៨)	(២៧.៥៩៨)	(១១២.៣៥១)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**៥.៨៤៤.៩៧៥**	**១២៣.៩៨៨**	**៥.៩៦៨.៩៦៣**	**២៤.០៧៣.២៨៤**

១៧.ទុនបម្រុងពីការវាយតម្លៃឡើងវិញ

	ក្រុមហ៊ុនរួម និងក្រុមហ៊ុន			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	*ពាន់រៀល*	*ដុល្លារអាមេរិក*	*ពាន់រៀល*
គិតត្រឹមទី១ ខែមករា	១៩២.១១៤	៧៧៩.២៥៥	២១៦.៨២៨	៨៧៩.៨៦៦
ចំណេញ/(ខាត)លើតម្លៃទីផ្សារនៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់	៤២.៥៧៣	១៧០.៧៦០	(២៤.៧១៤)	(១០០.៦១១)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**២៣៤.៦៨៧**	**៩៥០.០១៥**	**១៩២.១១៤**	**៧៧៩.២៥៥**

ទុនបម្រុងសម្រាប់ការវាយតម្លៃឡើងវិញ សំដៅដល់ភាពខុសគ្នារវាងរំលស់ថ្លៃដើម ជាមួយនឹងតម្លៃសមស្រប នៃទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់។

១៨.ភាគលាភ

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ ភាគទុនិកក្រុមហ៊ុនបានអនុម័តលើការបែងចែកភាគលាភ ដោយដកចេញពីប្រាក់ចំណេញសុទ្ធសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ចំនួន ៨៤០.០០០ ដុល្លារ អាមេរិក (ស្មើនឹង ១,៥ ដុល្លារអាមេរិកក្នុងមួយហ៊ុន) (២០២៤ ៖ ១.៤០០.០០០ ដុល្លារអាមេរិក ស្មើនឹង ២,៥ ដុល្លារអាមេរិកក្នុងមួយហ៊ុន)។ ការបែងចែកភាគលាភ ត្រូវបានអនុម័តដោយនិយ័តករធានារ៉ាប់រងកម្ពុជា នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៥ និងបានទូទាត់រួចរាល់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥។
នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦ ក្រុមប្រឹក្សាភិបាលបានស្នើសុំបែងចែកភាគលាភចំនួន ៥៤៣.២០០ ដុល្លារអាមេរិក (ស្មើនឹង ០,៩៧ ដុល្លារអាមេរិក ក្នុងមួយហ៊ុន) ដោយដកចេញពីប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ ការស្នើសុំបែងចែកភាគលាភនេះត្រូវបានអនុម័តក្នុងកិច្ចប្រជុំភាគទុនិកនាកាលបរិច្ឆេទដដែល ដែលការបែងចែកភាគលាភនេះ ត្រូវសុំការអនុម័តពីនិយ័តករធានារ៉ាប់រងកម្ពុជា។

១៩.បំណុលកិច្ចសន្យាធានារ៉ាប់រង

	ក្រុមហ៊ុនរួម			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	*ពាន់រៀល*	*ដុល្លារអាមេរិក*	*ពាន់រៀល*
កិច្ចសន្យាធានារ៉ាប់រងមិនមែនអាយុជីវិត				
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	៨.៣៤២.៨១០	៣៣.៤៧៩.៦៩៧	៨.១១៤.៣៨៣	៣២.៦៦០.៣៩២
សំណងមិនទាន់ទូទាត់	២.៤៥៣.៥២៤	៩.៨៤៥.៩៩២	៩០៨.១២៣	៣.៦៥៥.១៩៥
សំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍	២.២០៩.៥៦៦	៨.៨៦៦.៩៨៨	១.៧៣៤.៨៣៥	៦.៩៨២.៧១១
	១៣.០០៥.៩០០	**៥២.១៩២.៦៧៧**	**១០.៧៥៧.៣៤១**	**៤៣.២៩៨.២៩៨**

១៩.បំណុលកិច្ចសន្យាធានារ៉ាប់រង (ត)

	ក្រុមហ៊ុនរួម			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត				
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	៦៤.០៤៥	២៥៧.០១៣	១៤៦.៥៣៨	៥៨៩.៨១៥
សំណងមិនទាន់ទូទាត់	៨.៣៣៨	៣៣.៤៦០	១០០.៣៤៣	៤០៣.៨៨១
សំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍	១១០.៣៣១	៤៤២.៧៥៨	៤៦២.៣៦៩	១.៨៦១.០៣៥
ទុនបម្រុងក្នុងការវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល	៣១.២០២	១២៥.២១៤	៨០.១០៤	៣២២.៤១៨
	២១៣.៩១៦	**៨៥៨.៤៤៥**	**៧៨៩.៣៥៤**	**៣.១៧៧.១៤៩**
	១៣.២១៩.៨១៦	**៥៣.០៥១.១២២**	**១១.៥៤៦.៦៩៥**	**៤៦.៤៧៥.៤៤៧**
រយៈពេលខ្លី	១៣.០០៥.៩០០	៥២.១៩២.៦៧៧	១១.១៦១.០៥៦	៤៤.៩២៣.២៥០
រយៈពេលវែង	២១៣.៩១៦	៨៥៨.៤៤៥	៣៨៥.៦៣៩	១.៥៥២.១៩៧
	១៣.២១៩.៨១៦	**៥៣.០៥១.១២២**	**១១.៥៤៦.៦៩៥**	**៤៦.៤៧៥.៤៤៧**

	ក្រុមហ៊ុន			
	២០២៥		២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
កិច្ចសន្យាធានារ៉ាប់រងមិនមែនអាយុជីវិត				
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	៨.២៨៧.៣០៨	៣៣.២៥៦.៩៦៧	៨.១១៤.៣៨៣	៣២.៦៦០.៣៩២
សំណងមិនទាន់ទូទាត់	២.៤៥៣.៥២៤	៩.៨៤៥.៩៩២	៩០៨.១២៣	៣.៦៥៥.១៩៥
សំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍	២.២០៩.៥៦៦	៨.៨៦៦.៩៨៨	១.៧៣៤.៨៣៥	៦.៩៨២.៧១១
	១២.៩៥០.៣៩៨	**៥១.៩៦៩.៩៤៧**	**១០.៧៥៧.៣៤១**	**៤៣.២៩៨.២៩៨**
កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត				
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	៦៤.០៤៥	២៥៧.០១៣	១៤៦.៥៣៨	៥៨៩.៨១៥
សំណងមិនទាន់ទូទាត់	៨.៣៣៨	៣៣.៤៦០	១០០.៣៤៣	៤០៣.៨៨១
សំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍	១១០.៣៣១	៤៤២.៧៥៨	៤៦២.៣៦៩	១.៨៦១.០៣៥
ទុនបម្រុងក្នុងការវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល	៣១.២០២	១២៥.២១៤	៨០.១០៤	៣២២.៤១៨
	២១៣.៩១៦	**៨៥៨.៤៤៥**	**៧៨៩.៣៥៤**	**៣.១៧៧.១៤៩**
	១៣.១៦៤.៣១៤	**៥២.៨២៨.៣៩២**	**១១.៥៤៦.៦៩៥**	**៤៦.៤៧៥.៤៤៧**
រយៈពេលខ្លី	១២.៩៥០.៣៩៨	៥១.៩៦៩.៩៤៧	១១.១៦១.០៥៦	៤៤.៩២៣.២៥០
រយៈពេលវែង	២១៣.៩១៦	៨៥៨.៤៤៥	៣៨៥.៦៣៩	១.៥៥២.១៩៧
	១៣.១៦៤.៣១៤	**៥២.៨២៨.៣៩២**	**១១.៥៤៦.៦៩៥**	**៤៦.៤៧៥.៤៤៧**

១៩.បំណុលកិច្ចសន្យាធានារ៉ាប់រង (ត)

បម្រែបម្រួលនៃបំណុលកិច្ចសន្យាធានារ៉ាប់រង និងទ្រព្យសកម្មធានារ៉ាប់រងបន្តមានដូចខាងក្រោម៖

	ក្រុមហ៊ុនរួម		
	បំណុលកិច្ចសន្យាធានារ៉ាប់រង	*ទ្រព្យសកម្មធានារ៉ាប់រងបន្ត*	*ចំនួនសុទ្ធ*
	ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*
២០២៥			
គិតត្រឹមថ្ងៃទី១ ខែមករា	១១.៥៤៦.៦៩៥	(២.៤០៧.០៥២)	៩.១៣៩.៦៤៣
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	១៤៥.៩៣៣	(៧១.០៣៤)	៧៤.៨៩៩
បំណុលកិច្ចសន្យាធានារ៉ាប់រងផ្សេងៗ	១.៥២៧.១៨៨	(៤៦៦.៥៦១)	១.០៦០.៦២៧
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**១៣.២១៩.៨១៦**	**(២.៩៤៤.៦៤៧)**	**១០.២៧៥.១៦៩**
សមមូលពាន់រៀល	**៥៣.០៥១.៩២២**	**(១១.៨១៦.៨៦៨)**	**៤១.២៣៤.២៥៤**
២០២៤			
គិតត្រឹមថ្ងៃទី០១ ខែមករា	១១.៨៥៦.៦៣៨	(២.៩៤០.៤៣៥)	៨.៩១៦.២០៣
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	៣៨៦.៧៦៧	(១៦.៧០០)	៣៧០.០៦៧
បំណុលកិច្ចសន្យាធានារ៉ាប់រងផ្សេងៗ	(៦៩៦.៧១០)	៥៥០.០៨៣	(១៤៦.៦២៧)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**១១.៥៤៦.៦៩៥**	**(២.៤០៧.០៥២)**	**៩.១៣៩.៦៤៣**
សមមូលពាន់រៀល	**៤៦.៤៧៥.៤៤៧**	**(៩.៦៨៨.៣៨៤)**	**៣៦.៧៨៧.០៦៣**

	ក្រុមហ៊ុន		
	បំណុលកិច្ចសន្យាធានារ៉ាប់រង	*ទ្រព្យសកម្មធានារ៉ាប់រងបន្ត*	*ចំនួនសុទ្ធ*
	ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*
២០២៥			
គិតត្រឹមថ្ងៃទី១ ខែមករា	១១.៥៤៦.៦៩៥	(២.៤០៧.០៥២)	៩.១៣៩.៦៤៣
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	៩០.៤៣១	(៧១.០៣៤)	១៩.៣៩៧
បំណុលកិច្ចសន្យាធានារ៉ាប់រងផ្សេងៗ	១.៥២៧.១៨៨	(៤៦៦.៥៦១)	១.០៦០.៦២៧
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**១៣.១៦៤.៣១៤**	**(២.៩៤៤.៦៤៧)**	**១០.២១៩.៦៦៧**
សមមូលពាន់រៀល	**៥២.៨២៨.៣៩២**	**(១១.៨១៦.៨៦៨)**	**៤១.០១១.៥២៤**
២០២៤			
គិតត្រឹមថ្ងៃទី០១ ខែមករា	១១.៨៥៦.៦៣៨	(២.៩៤០.៤៣៥)	៨.៩១៦.២០៣
ទុនបម្រុងបុព្វលាភមិនទាន់ទទួលស្គាល់	៣៨៦.៧៦៧	(១៦.៧០០)	៣៧០.០៦៧
បំណុលកិច្ចសន្យាធានារ៉ាប់រងផ្សេងៗ	(៦៩៦.៧១០)	៥៥០.០៨៣	(១៤៦.៦២៧)
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ	**១១.៥៤៦.៦៩៥**	**(២.៤០៧.០៥២)**	**៩.១៣៩.៦៤៣**
សមមូលពាន់រៀល	**៤៦.៤៧៥.៤៤៧**	**(៩.៦៨៨.៣៨៤)**	**៣៦.៧៨៧.០៦៣**

១៩.បំណុលកិច្ចសន្យាធានារ៉ាប់រង (ត)

សំណងត្រូវទូទាត់

ទុនបម្រុងលើការខាតបង់ គឺជាកាតព្វកិច្ចទូទាត់ពីការខាតបង់នៃធានារ៉ាប់រងបន្ត ដែលបានកើតឡើងប៉ុន្តែមិនទាន់បានទូទាត់។ វាត្រូវបានបែងចែកបន្ថែមទៀត ទៅជាទុនបម្រុងសម្រាប់ការខាតបង់លើការធានារ៉ាប់រងបន្តដែលបានរាយការណ៍រួចហើយនាកាលបរិច្ឆេទរាយការណ៍ និងទុនបម្រុងសម្រាប់ការខាតបង់លើការធានារ៉ាប់រងបន្តដែលមិនទាន់បានរាយការណ៍ (IBNR) នាកាលបរិច្ឆេទរាយការណ៍។ ទុនបម្រុងសម្រាប់ការខាតបង់ គឺផ្អែកទៅលើការប៉ាន់ស្មានដែលអាចខុសគ្នាពីចំនួនជាក់ស្តែងដែលត្រូវបង់។
សំវិធានធនសម្រាប់ IBNR ត្រូវបានគណនាដោយផ្អែកលើការវាយតម្លៃរបស់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រងចំពោះការវិវត្តតម្លៃនៃការទាមទារសំណង រួមបញ្ចូលនូវគ្រប់កម្រិតហានិភ័យទាំងអស់របស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន។ ការគណនានេះពាក់ព័ន្ធនឹងការព្យាកររបស់ក្រុមហ៊ុនរួមនិងក្រុមហ៊ុន អំពីបទពិសោធន៍នៃការទាមទារសំណងនាពេលអនាគត។ ក្នុងចំណោមការព្យាករទាំងអស់ មានធាតុផ្សំមួយចំនួនមានភាពមិនច្បាស់លាស់ ដែលជាហេតុនាំឱ្យបទពិសោធន៍នៃការទាមទារសំណងនាពេលអនាគត អាចខុសពីបទពិសោធន៍នៃការទាមទារសំណងពិតប្រាកដ ដោយផ្អែកលើបទពិសោធន៍នៃការទាមទារសំណងពីមុន។ ភាពមិនច្បាស់លាស់ទាំងនេះ កើតឡើងពីការផ្លាស់ប្តូរហានិភ័យជាមូលដ្ឋាន និងបម្រែបម្រួលនៃកំណើនហានិភ័យ ការព្យាករចំពោះការទាមទារសំណង ក៏ដូចជាភាពមិនច្បាស់លាស់នៃគំរូសម្រាប់ការព្យាករ និងការសន្មតជាមូលដ្ឋាន។
វិធីសាស្ត្រដែលត្រូវបានអនុវត្តសម្រាប់គណនា IBNR គឺវិធីសាស្ត្រ Chain Ladder ដែលប្រើស្ថិតិនៃការទូទាត់ និងការខាតបង់ដែលបានកើតឡើងក្នុងឆ្នាំកន្លងមក ដើម្បីប៉ាន់ស្មានការទាមទារសំណងចុងក្រោយ។ ទុនបម្រុងលើសំណងបានរាយការណ៍ប៉ុន្តែមិនបានទូទាត់ (RBNS) គឺជាចំនួនដែលបានទាមទារនាកាលបរិច្ឆេទរាយការណ៍។ ចំនួនជាក់ស្តែងបានបង់ គឺអាស្រ័យលើការវាយតម្លៃចុងក្រោយរបស់អ្នកវិភាគហានិភ័យ ដូច្នេះ វាអាចខុសគ្នាពីចំនួនដែលបានទាមទារ។

បុព្វលាភត្រូវទូទាត់

ក្រុមហ៊ុនរួមនិងក្រុមហ៊ុនបានទទួលស្គាល់បុព្វលាភដែលត្រូវទូទាត់សរុប រួមមាន អតិបរមានៃបុព្វលាភបម្រុងបុព្វលាភធានារ៉ាប់រងមិនទាន់ចាត់ទុកជាចំណូល និងប្រាក់បម្រុងហានិភ័យមិនទាន់ផុតសុពលភាព (“URR”) ស្របតាមប្រកាសលេខ ០៦៣។ UPR ត្រូវបានគណនាសម្រាប់ផលិតផលរយៈពេលខ្លីដោយផ្អែកលើវិធីសាស្ត្រ ១/៣៦៥ លើកលែងតែទិន្នន័យអាជីវកម្មដោយស្ម័គ្រចិត្តដោយសារកម្រិតទិន្នន័យមិនគ្រប់គ្រាន់។ UPR សម្រាប់អាជីវកម្មស្ម័គ្រចិត្តត្រូវបានគណនាដោយផ្អែកលើ វិធីសាស្ត្រ ១/៨ ។ បទពិសោធន៍នៃការទាមទារលើគ្រប់ចំណាត់ថ្នាក់ទាំងអស់ មានភាពអំណោយផលក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ហើយគ្មានហេតុផលណាដែលបង្ហាញពីកង្វះខាតបុព្វលាភលើថ្នាក់ទាំងនេះទេ។

បំណុលរយៈពេលវែង

ក្រុមហ៊ុនរួមនិងក្រុមហ៊ុនបានចាប់ផ្តើមគណនាប្រាក់បម្រុងគណិតវិទ្យាដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល (“GPV”) សម្រាប់ធានារ៉ាប់រងបន្តលើអាយុជីវិតរយៈពេលវែងទៅតាមលក្ខខណ្ឌតម្រូវនៃប្រកាសលេខ ០៦១។ GPV គឺជាតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍ នាពេលអនាគត និងការចំណាយដែលមានតម្លៃតិចជាងតម្លៃបច្ចុប្បន្ននៃបុព្វលាភធានារ៉ាប់រងដុល នាពេលអនាគតសម្រាប់អាជីវកម្មធានារ៉ាប់រងអាយុជីវិត។ GPV ត្រូវបានគណនាតាមមូលដ្ឋានអនាគត (Prospective Basis) ដោយប្រើការសន្មតដែលបានរំពឹងទុក រួមបញ្ចូលអត្រាមរណៈភាព/ជំងឺ អត្រាអប្បហារ និងអត្រាឃឹតយ៉ាវ ជាមួយនឹងប្រាក់ឧបត្ថម្ភសម្រាប់កម្រិតនៃគម្លាតអវិជ្ជមាន (MfAD) ដើម្បីបំពេញនូវភាពមិនច្បាស់លាស់ជុំវិញ បទពិសោធន៍នាពេលអនាគត។ GPV ចុងក្រោយ ត្រូវបានទទួលយកតាមចំនួនណាមួយដែលខ្ពស់ជាងរវាងសេណារីយ៉ូឃឹតយ៉ាវខ្ពស់ និងសេណារីយ៉ូឃឹតយ៉ាវទាប។

១៩.បំណុលកិច្ចសន្យាធានារ៉ាប់រង (ត)

បំណុលរយៈពេលវែង(ត)

ការសន្មត និងការផ្លាស់ប្តូរការសន្មត

ដំណើរការកំណត់ការសន្មតធ្វើឡើងក្នុងគោលបំណងធ្វើឱ្យការប៉ាន់ស្មាននៃលទ្ធផលមានសុក្រឹតភាពបំផុត។ ប្រភពទិន្នន័យដែលត្រូវបានប្រើជាធាតុចូលសម្រាប់ការសន្មត គឺប្រភពផ្ទៃក្នុងរបស់ក្រុមហ៊ុន ដោយផ្អែកលើការសិក្សាលម្អិតដែលត្រូវបានអនុវត្តជាទៀងទាត់។ ការសន្មតត្រូវបានត្រួតពិនិត្យដើម្បីធានាថា ការសន្មតទាំងនោះស្របទៅនឹងព័ត៌មានដែលអាចអង្កេតបានផ្សេងទៀត។ មានការសង្កត់ធ្ងន់បន្ថែមទៀតទៅលើនិន្នាការបច្ចុប្បន្នហើយនៅពេលដែលមិនមានព័ត៌មានប្រវត្តិសាស្ត្រគ្រប់គ្រាន់ការសន្មត ដោយប្រុងប្រយ័ត្នត្រូវបានយកមកអនុវត្តន៍ដោយការយកចិត្តទុកដាក់។

លក្ខណៈនៃអាជីវកម្មធានារ៉ាប់រងធ្វើឱ្យមានការលំបាក ក្នុងការប៉ាន់ស្មានលទ្ធផល នៃការទាមទារសំណងជាក់លាក់ណាមួយ និងការចំណាយចុងក្រោយ។ ការទាមទារសំណងដែលបានជូនដំណឹងនីមួយៗ ត្រូវបានវាយតម្លៃដោយផ្អែកលើករណីនីមួយៗ តាមកាលៈទេសៈ ព័ត៌មានដែលអាចរកបានពីអ្នកវាយតម្លៃលើកាខាតបង់ និងភស្តុតាងជាប្រវត្តិសាស្ត្រនៃអំណះអំណាងស្រដៀងគ្នា។ ការប៉ាន់ប្រមាណ ត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលមានព័ត៌មានថ្មី។ ផលប៉ះពាល់ដល់ការចំណាយចុងក្រោយនៃការខាតបង់ គឺមានភាពលំបាកក្នុងការប៉ាន់ស្មាន។ សំវិធានធនគឺផ្អែកលើព័ត៌មានដែលមាននាពេលបច្ចុប្បន្ន។ ទោះជាយ៉ាងណាក៏ដោយ បំណុលចុងក្រោយអាចខុសគ្នា ដោយសារលទ្ធផលនៃការវិវត្តន៍ជាបន្តបន្ទាប់។

ការចំណាយទៅលើសំណងមិនទាន់ទូទាត់ និងសំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍ ត្រូវបានប៉ាន់ប្រមាណដោយប្រើវិធីសាស្ត្រស្ថិតិគណិតវិទ្យាជាច្រើន ដែលបន្ថែមលើតារាងវិវត្តន៍នៃការទាមទារសំណងដែលបានបង់ និងសំណងកើតឡើង សម្រាប់ឆ្នាំគ្រោះថ្នាក់នីមួយៗ ដោយផ្អែកលើការអភិវឌ្ឍនៃឆ្នាំមុន និងសមាមាត្រការខាតបង់ដែលរំពឹងទុក។

វិធីសាស្ត្របន្ថែមមានការប្រើប្រាស់ព័ត៌មានអភិវឌ្ឍន៍ការទាមទារសំណងនាឆ្នាំកន្លងមក សន្មតថាលំនាំនៃការអភិវឌ្ឍ ការទាមទារសំណងនាឆ្នាំកន្លងមក នឹងកើតឡើងម្តងទៀតនាពេលអនាគត។ មានមូលហេតុដែលបញ្ហានេះ អាចមិនមែនជាករណីដែលអាចបានកំណត់អត្តសញ្ញាណត្រូវបានអនុញ្ញាត ដោយការកែប្រែវិធីសាស្ត្រដោយហេតុផល រួមមាន៖

- ការផ្លាស់ប្តូរនៅក្នុងដំណើរការ ដែលអាចជះឥទ្ធិពលដល់ការអភិវឌ្ឍ/ការកត់ត្រានៃសំណងដែលបានបង់ និងកើតឡើង (ដូចជាការផ្លាស់ប្តូរនីតិវិធីនៃការទាមទារសំណង) និង
- និន្នាការសេដ្ឋកិច្ច ច្បាប់ នយោបាយ និងសង្គម (ជាលទ្ធផលមានភាពខុសគ្នាពីកម្រិតអតិផរណាដែលរំពឹងទុក) និង
- ការផ្លាស់ប្តូរអាជីវកម្មចម្រុះ (ការផ្លាស់ប្តូរលទ្ធផលរួមទាំងផលប៉ះពាល់នៃការខាតបង់ធំ)។

ការសន្មត គឺជះឥទ្ធិពលលើការវាស់វែងសំវិធានធនទាក់ទងនឹងកិច្ចសន្យាធានារ៉ាប់រង តាមលំនាំវិវឌ្ឍន៍នៃការទាមទារសំណងដែលបានបង់ ទម្រង់វិវឌ្ឍន៍ការទាមទារសំណងដែលបានការកើតឡើង។ ការសន្មតទាំងនេះ ត្រូវបានប្រើសម្រាប់វាយតម្លៃ ការប៉ាន់ស្មានដ៏ល្អបំផុតចំពោះ សំណងកើតឡើងប៉ុន្តែមិនទាន់រាយការណ៍ដោយឆ្នាំគ្រោះថ្នាក់ និងសម្រាប់សំវិធានធនសម្រាប់ហានិភ័យដែលមិនទាន់ហួសកាលកំណត់ទៅលើមូលដ្ឋានដុល និងសុទ្ធនៃការធានារ៉ាប់រង។ ការទាមទារសំណងលើអាជីវកម្មគ្រប់ប្រភេទ មិនត្រូវបានធ្វើអប្បហារឡើយ។

ការវិភាគរំញោច

បំណុលលើសំណងធានារ៉ាប់រងទូទៅ មានភាពរំញោចនឹងការសន្មតសំខាន់ៗ នៅក្នុងតារាងខាងក្រោម។ យើងមិនអាចកំណត់បរិមាណនៃភាពរំញោច ដែលបណ្តាលមកពីការសន្មតជាក់លាក់ ដូចជាការផ្លាស់ប្តូរច្បាប់ ឬភាពមិនច្បាស់លាស់នៅក្នុងដំណើរការប៉ាន់ស្មាន។

១៩.បំណុលកិច្ចសន្យាធានារ៉ាប់រង (ត)

បំណុលរយៈពេលវែង(ត)

ការវិភាគរំញោច (ត)

ការសន្មតចម្បងដែលផ្អែកលើការប៉ាន់ស្មាននៃបំណុល គឺថាការអភិវឌ្ឍន៍ការទាមទារនាពេលអនាគតរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន នឹងធ្វើតាមគំរូស្រដៀងគ្នាទៅនឹងបទពិសោធន៍នៃការអភិវឌ្ឍន៍ការទាមទារពីមុន។ នេះរួមបញ្ចូលទាំងការសន្មតទាក់ទងនឹងគំរូនៃការអភិវឌ្ឍន៍ការខាតបង់ និងបម្រែបម្រួលនៃសមាមាត្រការខាតបង់។ ការវិនិច្ឆ័យគុណភាពបន្ថែម ត្រូវបានប្រើដើម្បីវាយតម្លៃពីវិសាលភាពដែលនិន្នាការអតីតកាលមិនអាចអនុវត្តនាពេលអនាគត ឧទាហរណ៍ ការកើតឡើងដាច់ដោយឡែក ការផ្លាស់ប្តូរកត្តាទីផ្សារ ដូចជាអាកប្បកិរិយាសាធារណៈចំពោះការទាមទារ លក្ខខណ្ឌ សេដ្ឋកិច្ច ក៏ដូចជាកត្តាខាងក្នុង ដូចជាផលប័ត្រជាដើម។ ការលាយបញ្ចូលគ្នា លក្ខខណ្ឌគោលនយោបាយ និងនីតិវិធីដោះស្រាយការទាមទារ។

	ក្រុមហ៊ុនរួម និងក្រុមហ៊ុន			
	ការផ្លាស់ប្តូរការសន្មត	កំណើន (តំហយ) បំណុលដុល	កំណើន (តំហយ) បំណុលសុទ្ធ	ប្រាក់ចំណេញមុនគិតពន្ធ
	%	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
២០២៥				
ធានារ៉ាប់រងទូទៅ (រាប់បញ្ចូលការធានារ៉ាប់រងអាយុជីវិតជាក្រុម)				
ការបាត់បង់អតិបរិមា	១%	២០១.៦០០	១៥៥.៣៨៣	(១៥៥.៣៨៣)
ការបាត់បង់អតិបរិមា	-១%	(២០១.៦០០)	(១៥៥.៣៨៣)	១៥៥.៣៨៣
ធានារ៉ាប់រងអាយុជីវិត				
អត្រាអប្បហារ	១%	(៩៧៣)	(៨៣២)	៨៣២
អត្រាអប្បហារ	-១%	១.០៥៤	១.០១១	(១.០១១)
អត្រាយឺតយ៉ាវ	១០%	(២.២៣១)	(២.១៣៧)	២.១៣៧
អត្រាយឺតយ៉ាវ	-១០%	២.៥៩៤	២.៤៩៣	(២.៤៩៣)
អត្រាមរណៈភាព	១០%	១.៣២៩	២.២៥០	(២២៥០)
អត្រាមរណៈភាព	-១០%	(១.៤៤៨)	(១.៣៤០)	១.៣៤០

១៩.បំណុលកិច្ចសន្យាធានារ៉ាប់រង (ត)

បំណុលរយៈពេលវែង(ត)

ការវិភាគរំញោច (ត)

២០២៤				
ធានារ៉ាប់រងទូទៅ (រាប់បញ្ចូលការធានារ៉ាប់រងអាយុជីវិតជាក្រុម)				
ការបាត់បង់អតិបរិមា	២.៥%	១.២០៧.៩៣៩	៩៨២.២៧៩	(៩៨២.២៧៩)
ការបាត់បង់អតិបរិមា	-២.៥%	(១.២០៧.៩៣៩)	(៩៨២.២៧៩)	៩៨២.២៧៩
ធានារ៉ាប់រងអាយុជីវិត				
អត្រាអប្បហារ	០.៥%	(១.៨៥១)	(១.៧០៨)	១.៧០៨
អត្រាអប្បហារ	-០.៥%	១.៩២៩	១.៧៨១	(១.៧៨១)
អត្រាយឺតយ៉ាវ	១%	(២.៩១៣)	(២.៧៣៥)	២.៧៣៥
អត្រាយឺតយ៉ាវ	-១%	៣.១២៥	២.៩៣៨	(២.៩៣៨)
អត្រាមរណៈភាព	១០%	៨.០០៦	៧.៣៩៨	(៧.៣៩៨)
អត្រាមរណៈភាព	-១០%	(៨.០១២)	(៧.៤០៣)	៧.៤០៣

២០.គណនីធានារ៉ាប់រងត្រូវទូទាត់

	ក្រុមហ៊ុនរួម និងក្រុមហ៊ុន			
	២០២៥		*២០២៤*	
	ដុល្លារអាម៉េរិក	*ពាន់រៀល*	*ដុល្លារអាម៉េរិក*	*ពាន់រៀល*
កិច្ចសន្យាធានារ៉ាប់រងមិនមែនអាយុជីវិត				
ការធានារ៉ាប់រងបន្ត	១.៧៥៩.៥២៨	៧.០៦០.៩៨៦	៣.៩៨៣.៦៩៤	១៦.០៣៤.៣៦៨
កិច្ចសន្យាធានារ៉ាប់រង	៤.៩៩៤.៣១៨	២០.០៤២.១៩៨	៥.៧៤៦.១៧៣	២៣.១២៨.៣៤៧
	៦.៧៥៣.៨៤៦	**២៧.១០៣.១៨៤**	**៩.៧២៩.៨៦៧**	**៣៩.១៦២.៧១៥**
កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត				
ការធានារ៉ាប់រងបន្ត	៦.៣៧២	២៥.៥៧១	១០.២៤០	៤១.២១៦
កិច្ចសន្យាធានារ៉ាប់រង	១៣៧.៣០១	៥៥០.៩៨៩	៣៣៨.០៣៦	១.៣៦០.៥៩៥
	១៤៣.៦៧៣	**៥៧៦.៥៦០**	**៣៤៨.២៧៦**	**១.៤០១.៨១១**
	៦.៨៩៧.៥១៩	**២៧.៦៧៩.៧៤៤**	**១០.០៧៨.១៤៣**	**៤០.៥៦៤.៥២៦**

២១.ចំណូលផ្សេងៗ

	២០២៥		២០២៤	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ក្រុមហ៊ុនរួម				
កម្រៃសេវាកម្មត្រូវបង់	៤៩.៨៨៩	២០០.២០៥	៥៧.១០០	២២៩.៨២៨
ចំណាយថ្លៃទឹកភ្លើងបង្គរ	៦.៧៩១	២៧.២៥២	១.២៦៣	៥.០៨៤
ផ្សេងៗ	១៣១.៩៩៨	៥២៩.៧០៦	១២.៤១៥	៤៩.៩៦៩
	១៨៨.៦៧៨	**៧៥៧.១៦៣**	**៧០.៧៧៨**	**២៨៤.៨៨១**
ក្រុមហ៊ុន				
កម្រៃសេវាកម្មត្រូវបង់	៤៣.១៣៩	១៧៣.១១៧	៤៨.៣០០	១៩៤.៤០៨
ចំណាយថ្លៃទឹកភ្លើងបង្គរ	១.៣៣៩	៥.៣៧៣	១.២៦៣	៥.០៨៣
ផ្សេងៗ	១៤១	៥៦៧	៦៩៩	២.៨១៣
	៤៤.៦១៩	**១៧៩.០៥៧**	**៥០.២៦២**	**២០២.៣០៤**

២២.ពន្ធ

(ក) អត្រាពន្ធត្រូវអនុវត្ត

យោងតាមច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនរួម និងក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូល ដូចខាងក្រោម៖

ការធានារ៉ាប់រងមិនមែនអាយុជីវិត

- ពន្ធលើប្រាក់ចំណូលមានអត្រា ៥% ទៅលើបុព្វលាភដុលទទួលបាននៅក្នុងឆ្នាំសារពើពន្ធ ដែលទាក់ទងទៅនឹងការធានារ៉ាប់រង ឬការធានារ៉ាប់រងបន្តនៃហានិភ័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អត្រាពន្ធ ៥% លើបុព្វលាភផ្ទេរឱ្យក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវប្រមូលពីក្រុមហ៊ុនធានារ៉ាប់រងបន្តមកវិញ ដែលចំនួនពន្ធនេះក្រុមហ៊ុនបានបង់ជូនអគ្គនាយកដ្ឋានពន្ធដារ ជំនួសក្រុមហ៊ុនធានារ៉ាប់រងបន្តរួចហើយ។
- ពន្ធលើប្រាក់ចំណូលមានអត្រា ២០% នៃប្រាក់ចំណេញជាប់ពន្ធ ដែលមិនមែនជាសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត (ចំណូលមិនមែនធានារ៉ាប់រង ឬចំណូលមិនមែនធានារ៉ាប់រងបន្ត)។

ការធានារ៉ាប់រងអាយុជីវិត

- ពន្ធលើប្រាក់ចំណូលមានអត្រា ២០% នៃប្រាក់ចំណូលជាប់ពន្ធ ឬពន្ធអប្បបរមាតាមអត្រា ១% នៃផលរបរសរុបដោយយកតាមអត្រាពន្ធមួយណាមានចំនួនធំជាង។
- ពន្ធអប្បបរមាត្រូវបានគណនាតាមអត្រា ១% នៃផលរបរប្រចាំឆ្នាំ (ចំណូលបុព្វលាភធានារ៉ាប់រងអាយុជីវិតនិងចំណូលពាក់ព័ន្ធ និងចំណូលពីសកម្មភាពអាជីវកម្មផ្សេងទៀត)។

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុនរួម និងក្រុមហ៊ុន ត្រូវឆ្លងកាត់ការពិនិត្យដោយ អគ្គនាយកដ្ឋានពន្ធដារ។ ដោយសារតែការអនុវត្តច្បាប់ពន្ធ និងបទប្បញ្ញត្តិចំពោះប្រតិបត្តិការមានច្រើនប្រភេទ ងាយនឹងមានការបកស្រាយខុសៗគ្នា ទៅលើចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ អាចត្រូវបានផ្លាស់ប្តូរនៅពេលក្រោយការធ្វើអធិការកិច្ចចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារកម្ពុជា។

២២.ពន្ធ (ត)

(ខ) ចំណាយពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលតាមអត្រា ៥% នៃបុព្វលាភធានារ៉ាប់រង

	ក្រុមហ៊ុនរួមនិងក្រុមហ៊ុន មិនមែនអាយុជីវិត			
	២០២៥		*២០២៤*	
	ដុល្លារអាមេរិក	*ពាន់រៀល*	*ដុល្លារអាមេរិក*	*ពាន់រៀល*
ពន្ធលើបុព្វលាភដុល ៥%	១.០២៨.៩១០	៤.១២៦.៩៥៨	៩៦៣.១១១	៣.៩២០.៨២៥
ពន្ធប្រមូលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត (*)	(២២១.៤០២)	(៨៨៨.០៤៣)	(២០២.១៦២)	(៨២៣.០០២)
	៨០៧.៥០៨	**៣.២៣៨.៩១៥**	**៧៦០.៩៤៩**	**៣.០៩៧.៨២៣**

(*) ពន្ធប្រមូលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តមានអត្រា ៥% នៃបុព្វលាភរ៉ាប់រងបន្តដែលបានផ្ទេរចេញសរុប ដែលត្រូវទទួលពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ទាក់ទងនឹងការធានារ៉ាប់រងបន្តនៅក្រៅប្រទេស។

ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធលើប្រាក់ចំណូល និងចំណេញតាមគណនេយ្យ៖

	ក្រុមហ៊ុនរួម				
	មិនមែនអាយុជីវិត	*អាយុជីវិត*	*មិនមែនធានារ៉ាប់រង*	*សរុប*	
	ដុល្លារអាមេរិក	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ដុល្លារអាមេរិក*	*ពាន់រៀល*
២០២៥					
បុព្វលាភដុល	២០.៥៧៨.៦៦៨	៣៧៧.០០៤	-	២០.៩៥៥.៦៧២	៨៤.០៥៣.២០០
បុព្វលាភដែលបានផ្ទេរចេញទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត	(៤.៧១២.១៨៥)	(១៧.៦៩០)	-	(៤.៧២៩.៨៧៥)	(១៨.៩៧១.៥២៩)
ចំណូលបុព្វលាភសុទ្ធ	**១៥.៨៦៦.៤៨៣**	**៣៥៩.៣១៤**	-	**១៦.២២៥.៧៩៧**	**៦៥.០៨១.៦៧១**
ចំណេញ/(ខាត) មុនគិតពន្ធលើប្រាក់ចំណូល	១.២២១.០៨៧	៤៧៥.៦៤១	(២៤៦.០៥៦)	១.៤៥០.៦៧២	៥.៨១៨.៦៤៥
ពន្ធលើប្រាក់ចំណូល ៥% នៃបុព្វលាភដុល	៧៩៣.៣២៤	-	-	៧៩៣.៣២៤	៣.១៨២.០២៣
ពន្ធលើប្រាក់ចំណូល ២០% នៃចំណេញ/(ខាត)	-	៩៥.១២៤	(៤៩.២១១)	៤៥.៩១៣	១៨៤.១៧៣
	៧៩៣.៣២៤	**៩៥.១២៤**	**(៤៩.២១១)**	**៨៣៩.២៣៧**	**៣.៣៦៦.១៩៦**
ផលប៉ះពាល់ពន្ធនៃ៖					
ខុសគ្នាអចិន្ត្រៃយ៍	-	-	៣៧.២៦០	៣៧.២៦០	១៤៩.៤៥២
ពន្ធពន្យារដែលមិនបានទទួលស្គាល់	-	-	៣៤.០៥១	៣៤.០៥១	១៣៦.៥៧៨
ចំណែកពន្ធអប្បបរមាដែលលើសពីពន្ធលើប្រាក់ចំណូល	-	-	១.៥៥៦	១.៥៥៦	៦.២៤១
ផ្សេងៗ	១៤.១៨៤	-	-	១៤.១៨៤	៥៦.៨៩១
ចំណាយពន្ធលើប្រាក់ចំណូល	**៨០៧.៥០៨**	**៩៥.១២៤**	**២៣.៦៥៦**	**៩២៦.២៨៨**	**៣.៧១៥.៣៥៨**

២២.ពន្ធ (ត)

(ខ) ចំណាយពន្ធលើប្រាក់ចំណូល (ត)

ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធលើប្រាក់ចំណូល និងចំណេញតាមគណនេយ្យ៖ (ត)

	ក្រុមហ៊ុនរួម				
	មិនមែនអាយុជីវិត	អាយុជីវិត	មិនមែនធានារ៉ាប់រង	សរុប	
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
២០២៤					
បុព្វលាភដុល	១៩.២៦២.២០៧	៦៤៩.០៩៣	-	១៩.៩១១.៣០០	៨១.០៥៨.៨០២
បុព្វលាភដែលបានផ្ទេរចេញទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត	(៤.៣៣៩.៥៦៥)	(២៨.៦៩១)	-	(៤.៣៦៨.២៥៦)	(១៧.៧៦៦.៨៨៦)
ចំណូលបុព្វលាភសុទ្ធ	១៤.៩២២.៦៤២	៦២០.៤០២	-	១៥.៥៤៣.០៤៤	៦៣.២៩២.០១៦
ចំណេញ/(ខាត) មុនគិតពន្ធលើប្រាក់ចំណូល	១.៧៣៣.៥២៧	៤៣៧.២៣១	(១៨២.០៦២)	១.៩៨៨.៦៩៦	៨.០៩៥.៩៨២
ពន្ធលើប្រាក់ចំណូល ៥% នៃបុព្វលាភដុល	៧៤៦.១៣២	-	-	៧៤៦.១៣២	៣.០៣៧.៥០៤
ពន្ធលើប្រាក់ចំណូល ២០% នៃចំណេញ/(ខាត)	-	៨៧.៤៤៦	(៣៦.៤១២)	៥១.០៣៤	២០៧.៧៥៥
	៧៤៦.១៣២	៨៧.៤៤៦	(៣៦.៤១២)	៧៩៧,១៦៦	៣,២៤៥,២៦៣
ផលប៉ះពាល់ពន្ធនៃ៖					
ខុសគ្នាអចិន្ត្រៃយ៍			២.៩១៦	២.៩១៦	១១.៨៧០
